# សុត្តន្តបិដក ខុទ្ទកនិកាយ

# ធម្មបទបាលី-ប្រែ

ជាទីរលឹករបស់ខ្ញុំ ភិរម្យ រតនសារី បកិណ្ណការាមិក

ក្នុងព្រះពុទ្ធសករាជ ២៥៦១ ឆ្នាំ២០១៨

# មាតិកា


| | |
|---|---|
| ១. យមកវគ្គ | ១ |
| ២. អប្បមាទវគ្គ | ៩ |
| ៣. ចិត្តវគ្គ | ១៣ |
| ៤. បុប្ផ វគ្គ | ១៦ |
| ៥. ពាល វគ្គ | ២២ |
| ៦. បណ្ឌិត វគ្គ | ២៧ |
| ៧. អរហន្តវគ្គ | ៣១ |
| ៨. សហស្សវគ្គ | ៣៥ |
| ៩. បាបវគ្គ | ៤១ |
| ១០. ទណ្ឌវគ្គ | ៤៧ |
| ១១. ជរាវគ្គ | ៥២ |
| ១២. អត្តវគ្គ | ៥៦ |
| ១៣. លោកវគ្គ | ៥៩ |
| ១៤. ពុទ្ធវគ្គ | ៦៣ |
| ១៥. សុខវគ្គ | ៦៩ |
| ១៦. បិយវគ្គ | ៧៣ |
| ១៧. កោធវគ្គ | ៧៧ |
| ១៨. មលវគ្គ | ៨២ |
| ១៩. ធម្មដ្ឋវគ្គ | ៨៩ |

២០. មគ្គវគ្គ ៩៥
២១. បកិណ្ណកវគ្គ ១០១
២២. និរយវគ្គ ១០៦
២៣. នាគវគ្គ ១១១
២៤. តណ្ហាវគ្គ ១១៧
២៥. ភិក្ខុវគ្គ ១២៨
២៦. ព្រាហ្មណវគ្គ ១៣៦

# រតនត្តយប្បណាមគាថា

ធម្មបទំ នយោ ពុទ្ធោ, នរទេវាន ទេសយិ;

សព្វទុក្ខប្បហានាយ, តំ តីហិ សាទរំ នមេ។១

ព្រះសម្ពុទ្ធព្រះអង្គជាអ្នកដឹងច្បាស់នូវធម្មបទ ទ្រង់សម្ដែងហើយ ដល់មនុស្សនិងទេវតាទាំងឡាយ ដើម្បីការលះបង់នូវទុក្ខទាំងអស់; ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះពុទ្ធអង្គនោះ ដោយកាយវាចាចិត្តទាំងបី ដោយគោរព។

ធម្មបទំ សុអក្ខាតំ, សត្តេ នីយតិ វដ្ដតោ;

សព្វទុក្ខប្បហានាយ, តំ តីហិ សាទរំ នមេ។២

ព្រះធម៌គឺធម្មបទ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយប្រពៃ តែងតែនាំចេញនូវសត្វទាំងឡាយ អំពីវដ្ដៈ ដើម្បីការលះបង់នូវទុក្ខទាំងអស់; ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ដោយកាយវាចាចិត្តទាំងបី ដោយគោរព។

ធម្មបទំ ធរោ សង្ឃោ, សម្មទេវ បដិបជ្ជតិ;

សព្វទុក្ខប្បហានាយ, តំ តីហិ សាទរំ នមេ។៣

ព្រះសង្ឃលោកទ្រទ្រង់នូវធម្មបទ តែងប្រតិបត្តិដោយល្អពិតមែន ដើម្បីការលះបង់នូវជាតិទុក្ខ; ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃនោះ ដោយកាយវាចាចិត្តទាំងបីដោយគោរព។

# ខុទ្ទកនិកាយ
# ធម្មបទបាលី-ប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

## ១. យមកវគ្គ

**១. មនោបុព្វង្គមា ធម្មា, មនោសេដ្ឋា មនោមយា;**
**មនសា ចេ បទុដ្ឋេន, ភាសតិ វា ករោតិ វា;**
**តតោ នំ ទុក្ខមន្វេតិ, ចក្កំវ វហតោ បទំ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត, បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត), ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលទៅតាមដានស្នាមជើងគោកំពុងអូសទៅ។

**២. មនោបុព្វង្គមា ធម្មា, មនោសេដ្ឋា មនោមយា;**
**មនសា ចេ បសន្នេន, ភាសតិ វា ករោតិ វា;**
**តតោ នំ សុខមន្វេតិ, ឆាយាវ អនុបាយិនី។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត, បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត), ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ។

**៣. អក្កោច្ឆិ មំ អវធិ មំ, អជិនិ មំ អហាសិ មេ;**
**យេ ច តំ ឧបនយ្ហន្តិ, វេរំ តេសំ ន សម្មតិ។**

បើជនទាំងឡាយណា ចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះបានជេរអញ, អ្នកឯណោះបានវាយអញ, អ្នកឯណោះបានផ្ចាញ់អញ, អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ (ដូច្នេះ) ពៀររបស់ជនទាំងឡាយ មិនរំងាប់ឡើយ ។

**៤. អក្កោច្ឆិ មំ អវធិ មំ, អជិនិ មំ អហាសិ មេ;**
**យេ ច តំ នូបនយ្ហន្តិ, វេរំ តេសូបសម្មតិ។**

តែជនទាំងឡាយណា មិនចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះបានជេរអញ, អ្នកឯណោះបានវាយអញ, អ្នកឯណោះបានផ្ចាញ់អញ, អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ (ដូច្នេះ) ពៀររបស់ជនទាំងឡាយ ទើបរំងាប់បាន ។

**៥. ន ហិ វេរេន វេរានិ, សម្មន្តីធ កុទាចនំ;**
**អវេរេន ច សម្មន្តិ, ឯស ធម្មោ សនន្តនោ។**

ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរំងាប់ដោយពៀរឡើយ, ពៀរទាំងឡាយ តែងរំងាប់ ដោយមិនមានពៀរ ។

**៦. បរេ ច ន វិជានន្តិ, មយមេត្ថ យមាមសេ;**
**យេ ច តត្ថ វិជានន្តិ, តតោ សម្មន្តិ មេធគា។**

ជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរំងាប់អំពីជនទាំងឡាយនោះ ។

**៧. សុភានុបស្សឹ វិហរន្តំ, ឥន្ទ្រិយេសុ អសំវុតំ;**
**ភោជនម្ហិ អមត្តញ្ញុំ, កុសីតំ ហីនវីរិយំ;**
**តំ វេ បសហតី មារោ, វាតោ រុក្ខំវ ទុព្វលំ។**

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់នូវបុគ្គលនោះឯង ដូចខ្យល់គ្របសង្កត់ដើមឈើទុព្វលដូច្នោះ។

**៨. អសុភានុបស្សឹ វិហរន្តំ, ឥន្ទ្រិយេសុ សុសំវុតំ;**
**ភោជនម្ហិ ច មត្តញ្ញុំ, សទ្ធំ អារទ្ធវីរិយំ;**
**តំ វេ នប្បសហតិ មារោ, វាតោ សេលំវ បព្វតំ។**

ឯបុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន

មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារ រមែងគ្រប សង្កត់នូវបុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្ម តាន់មិនបានដូច្នោះ ។

**៩. អនិក្កសាវោ កាសាវំ, យោ វត្ថំ បរិទហិស្សតិ;**
**អបេតោ ទមសច្ចេន, ន សោ កាសាវមរហតិ។**

អ្នកណានៅមានទឹកចត់គឺរាគាទិក្កិលេស (ក្នុងសន្ដាន) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀកដណ្ដប់សំពត់កាសាវៈ, អ្នកនោះ មិនគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈឡើយ។

**១០. យោ ច វន្តកសាវស្ស, សីលេសុ សុសមាហិតោ;**
**ឧបេតោ ទមសច្ចេន, ស វេ កាសាវមរហតិ។**

លុះតែអ្នកណាមានទឹកចត់គឺរាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិ-សីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ, អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈបាន។

**១១. អសារេ សារមតិនោ, សារេ ចាសារទស្សិនោ;**
**តេ សារំ នាធិគច្ឆន្តិ, មិច្ឆាសង្កប្បគោចរា។**

ជនទាំងឡាយ ដែលយល់ឃើញថាជាធម៌មានខ្លឹម ក្នុងធម៌មិនមានខ្លឹមផង ដែលយល់ឃើញថាជាធម៌មិនមាន

ខ្លឹម ក្នុងធម៌មានខ្លឹមផង ពួកគេមានសេចក្ដីត្រិះរិះខុសជាគោចរ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ។

**១២. សារញ្ច សារតោ ញត្វា, អសារញ្ច អសារតោ;**
**តេ សារំ អធិគច្ឆន្តិ, សម្មាសង្កប្បគោចរា។**

ជនទាំងឡាយ បានដឹងនូវធម៌មានខ្លឹមថាជាធម៌មានខ្លឹមផង នូវធម៌មិនមានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ពួកគេមានសេចក្ដីត្រិះរិះត្រូវជាគោចរ ទើបបាននូវធម៌ដែលមានខ្លឹម។

**១៣. យថា អគារំ ទុច្ឆន្នំ, វុដ្ឋី សមតិវិជ្ឈតិ;**
**ឯវំ អភាវិតំ ចិត្តំ, រាគោ សមតិវិជ្ឈតិ។**

ផ្ទះដែលគេប្រក់ខ្ជីខ្ជាហើយ, តំណក់ទឹកភ្លៀង រមែងលេចស្រោចបាន យ៉ាងណាមិញ; ចិត្តដែលគេមិនអប់រំហើយ, រាគៈ រមែងលេចស្រោចបាន ក៏យ៉ាងនោះឯង ។

**១៤. យថា អគារំ សុឆន្នំ, វុដ្ឋី ន សមតិវិជ្ឈតិ;**
**ឯវំ សុភាវិតំ ចិត្តំ, រាគោ ន សមតិវិជ្ឈតិ។**

ផ្ទះដែលគេប្រក់ល្អហើយ, តំណក់ទឹកភ្លៀង មិនលេចស្រោចបានទេ យ៉ាងណាមិញ; ចិត្តដែលគេបានអប់រំហើយ, រាគៈមិនលេចស្រោចបានទេ ក៏យ៉ាងនោះឯង។

**១៥. ឥធ សោចតិ បេច្ច សោចតិ,**
**បាបការី ឧភយត្ថ សោចតិ;**
**សោ សោចតិ សោ វិហញ្ញតិ,**
**ទិស្វា កម្មកិលិដ្ឋមត្តនោ។**

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយ ក្នុងលោកនេះផង សោកស្តាយក្នុងលោកខាងមុខផង គឺសោកស្តាយ ក្នុងលោកទាំងពីរ, គេបានឃើញនូវអំពើដ៏សៅហ្មង របស់ខ្លួនហើយ រមែងសោកស្តាយ គេរមែងក្តៅក្រហាយ ។

**១៦. ឥធ មោទតិ បេច្ច មោទតិ,**
**កតបុញ្ញោ ឧភយត្ថ មោទតិ;**
**សោ មោទតិ សោ បមោទតិ,**
**ទិស្វា កម្មវិសុទ្ធិមត្តនោ។**

បុគ្គលអ្នកធ្វើបុណ្យ តែងរីករាយ ក្នុងលោកនេះផង រីករាយក្នុងលោកខាងមុខផង គឺរីករាយ ក្នុងលោកទាំងពីរ, គេបានឃើញនូវអំពើដ៏បរិសុទ្ធរបស់ខ្លួនហើយ រមែងរីករាយ គេរមែងស្រស់ស្រាយ ។

**១៧. ឥធ តប្បតិ បេច្ច តប្បតិ, បាបការី ឧភយត្ថ តប្បតិ;**
**បាបំ មេ កតន្តិ តប្បតិ, ភិយ្យោ តប្បតិ ទុគ្គតឹ គតោ។**

បុគ្គលអ្នកធ្វើបាប តែងក្តៅក្រហាយ ក្នុងលោកនេះផង

ក្តៅក្រហាយ ក្នុងលោកខាងមុខផង គឺក្តៅក្រហាយក្នុងលោកទាំងពីរ, គេក្តៅក្រហាយ ដោយគិតឃើញថា "បាបអញបានធ្វើហើយ" លុះទៅកាន់ទុគ្គតិហើយ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

**១៨. ឥធ នន្ទតិ បេច្ច នន្ទតិ, កតបុញ្ញោ ឧភយត្ថ នន្ទតិ;**
**បុញ្ញំ មេ កតន្តិ នន្ទតិ, ភិយ្យោ នន្ទតិ សុគ្គតឹ គតោ។**

បុគ្គលអ្នកធ្វើបុណ្យ តែងត្រេកអរ ក្នុងលោកនេះផង ត្រេកអរ ក្នុងលោកខាងមុខផង គឺត្រេកអរ ក្នុងលោកទាំងពីរ, គេត្រេកអរ ដោយគិតឃើញថា "បុណ្យអញបានធ្វើហើយ" លុះទៅកាន់សុគតិហើយ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

**១៩. ពហុម្បិ ចេ សំហិត ភាសមានោ,**
**ន តក្ករោ ហោតិ នរោ បមត្តោ;**
**គោបោវ គាវោ គណយំ បរេសំ,**
**ន ភាគវា សាមញ្ញស្ស ហោតិ។**

បើនរជនកាលពោលនូវព្រះពុទ្ធវចនៈសូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមព្រះពុទ្ធវចនៈនោះ រមែងជាអ្នកមិនមានចំនែកនៃសាមញ្ញផល (ផលរបស់សមណៈ) ដូចអ្នករក្សាគោកាលរាប់គោ ប្រគល់ឲ្យអ្នកដទៃហើយ

(ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស[1])ដូច្នោះឯង ។

**២០. អប្បម្បិ ចេ សំហិត ភាសមានោ,**
**ធម្មស្ស ហោតី អនុធម្មចារី;**
**រាគញ្ច ទោសញ្ច បហាយ មោហំ,**
**សម្មប្បជានោ សុវិមុត្តចិត្តោ;**
**អនុបាទិយានោ ឥធ វា ហុរំ វា,**
**ស ភាគវា សាមញ្ញស្ស ហោតិ។**

បើនរជនកាលពោលនូវព្រះពុទ្ធវចនៈ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់នូវរាគៈទោសៈនិងមោហៈ ជាអ្នកដឹងនូវធម៌ដែលកំណត់តាមហេតុ មានចិត្តផុតស្រឡះហើយដោយល្អ មិនមានសេចក្តីប្រកាន់មាំ ក្នុងលោកនេះនិងលោកខាងមុខ នរ-ជននោះ ទើបជាអ្នកមានចំនែកនៃសាមញ្ញផល។

**យមកវគ្គោ បឋមោ និដ្ឋិតោ។**

យមកវគ្គ ទី១ ចប់ ។

---

1 បញ្ចគោរស ប្រែថា រសដែលកើតអំពីរសនៃទឹកដោះគោ ៥មុខ គឺខីរៈ ទឹកដោះស្រស់១ ទធិ ទឹកដោះជូរ១ តក្កៈ ទឹកដោះជូរឡើងពពុះ១ នវនីតៈ ទឹកដោះខាប់១ សប្បិ ទឹកដោះថ្លា១ ។ វចនានុក្រម, ទីឃនិកាយ សីលក្ខន្ធវគ្គ បោដ្ឋបាទសូត្រ រួមនឹងតតិយបារាជិកអដ្ឋកថា។

# ២. អប្បមាទវគ្គ

**២១. អប្បមាទោ អមតបទំ, បមាទោ មច្ចុនោ បទំ;**
**អប្បមត្តា ន មីយន្តិ, យេ បមត្តា យថា មតា។**

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់, សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់, ពួកជនដែលមិនប្រមាទឈ្មោះថាមិនស្លាប់, ពួកជនដែលប្រមាទ ទុកដូចជាមនុស្សស្លាប់ទៅហើយ។

**២២. ឯតំ វិសេសតោ ញត្វា, អប្បមាទម្ហិ បណ្ឌិតា;**
**អប្បមាទេ បមោទន្តិ, អរិយានំ គោចរេ រតា។**

ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា(ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយ ក្នុងសេចក្តីមិនប្រមាទ, ត្រេកអរហើយ ក្នុងធម៌ជាទីគោចរ របស់ព្រះអរិយៈទាំងឡាយ។

**២៣. តេ ឈាយិនោ សាតតិកា, និច្ចំ ទឡ្ហបរក្កមា;**
**ផុសន្តិ ធីរា និព្វានំ, យោគក្ខេមំ អនុត្តរំ។**

បណ្ឌិតទាំងនោះ មានការសំឡឹងពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកប្រាជ្ញ តែងពាល់ត្រូវនូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត។

**២៤. ឧដ្ឋានវតោ សតីមតោ, សុចិកម្មស្ស និសម្មការិនោ;**
**សញ្ញតស្ស ធម្មជីវិនោ, អប្បមត្តស្ស យសោភិវឌ្ឍតិ។**

យសរមែងចំរើនក្រៃលែង ដល់បុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង មានស្មារតី មានការងារស្អាតល្អ មានការពិចារណារួចហើយទើបធ្វើ មានការសង្រួម រស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ។

**២៥. ឧដ្ឋានេនប្បមាទេន, សញ្ញមេន ទមេន ច;**
**ទីបំ កយិរាថ មេធាវី, យំ ឱឃោ នាភិកីរតិ។**

អ្នកប្រាជ្ញគប្បីសាងកោះ (គឺអរហត្តផល) ជាកោះដែលជំនន់(គឺកិលេស)ជន់ពន្លិចមិនបាន ដោយសេចក្ដីប្រឹងប្រែងផង ដោយសេចក្ដីមិនប្រមាទផង ដោយការសង្រួមក្នុងសីលផង ដោយការទូន្មាននូវឥន្ទ្រិយផង។

**២៦. បមាទមនុយុញ្ជន្តិ, ពាលា ទុម្មេធិនោ ជនា;**
**អប្បមាទញ្ច មេធាវី, ធនំ សេដ្ឋំវ រក្ខតិ។**

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្ដីប្រមាទ, ចំនែកអ្នកប្រាជ្ញ តែងរក្សានូវសេចក្ដីមិនប្រមាទ ដូចទ្រព្យដ៏ប្រសើរថ្លៃថ្លា។

**២៧. មា បមាទមនុយុញ្ជេថ, មា កាមរតិសន្ថវំ;**
**អប្បមត្តោ ហិ ឈាយន្តោ, បប្បោតិ វិបុលំ សុខំ។**

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ, ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយក្នុងកាមឡើយ; ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្តីសុខដ៏ទូលាយ ។

**២៨. បមាទំ អប្បមាទេន, យទា នុទតិ បណ្ឌិតោ;**
**បញ្ញាបាសាទមារុយ្ហ, អសោកោ សោកិនិំ បជំ;**
**បព្វតដ្ឋោវ ភុម្មដ្ឋេ, ធីរោ ពាលេ អវេក្ខតិ។**

កាលណា បណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ, កាលណោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញា ជាអ្នកមិនសោក រមែងឃើញនូវពួកសត្វដែលមានសោក, ធីរជន តែងឃើញនូវពួកជនពាលដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលនូវពួកជនដែលឋិតនៅលើផែនដីដូច្នោះឯង ។

**២៩. អប្បមត្តោ បមត្តេសុ, សុត្តេសុ ពហុជាគរោ;**
**អពលស្សំវ សីឃស្សោ, ហិត្វា យាតិ សុមេធសោ។**

បណ្ឌិតមានប្រាជ្ញាមុះមុត កាលបើពួកបុគ្គលកំពុងតែប្រមាទ លោកមិនប្រមាទ, កាលបើពួកបុគ្គលកំពុងតែដេកលក់ លោកភ្ញាក់រលឹកច្រើន, លោករមែងលះបង់ទៅចោលនូវបុគ្គលបែបនោះ ដូចសេះលឿនដែលទៅ

ចោលនូវសេះដែលមិនមានកំលាំងដូច្នោះឯង ។

**៣០. អប្បមាទេន មឃវា, ទេវានំ សេដ្ឋតំ គតោ;**
**អប្បមាទំ បសំសន្តិ, បមាទោ គរហិតោ សទា។**

មាឃមាណពមានឈ្មោះថាមឃៈ ដល់នូវភាពជាអ្នកប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ, អ្នកប្រាជ្ញទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ, ត្មះតិះដៀលសេចក្តីប្រមាទ សព្វៗកាល ។

**៣១. អប្បមាទរតោ ភិក្ខុ, បមាទេ ភយទស្សិ វា;**
**សំយោជនំ អណុំ ថូលំ, ឌហំ អគ្គីវ គច្ឆតិ។**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូចទាំងធំ ដូចភ្លើងដុតកំទេច ទាំងតូចទាំងធំដូច្នោះឯង។

**៣២. អប្បមាទរតោ ភិក្ខុ, បមាទេ ភយទស្សិ វា;**
**អភព្វោ បរិហានាយ, និព្វានស្សេវ សន្តិកេ។**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថាឋិតនៅក្នុងជិតនៃព្រះនិព្វាន។

**អប្បមាទវគ្គោ ទុតិយោ និដ្ឋិតោ។**

អប្បមាទវគ្គ ទី២ ចប់ ។

## ៣. ចិត្តវគ្គ

**៣៣. ផន្ទនំ ចបលំ ចិត្តំ, ទុរក្ខំ ទុន្និវារយំ;**
**ឧជុំ ករោតិ មេធាវី, ឧសុការោវ តេជនំ។**

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញពត់ព្រួញឲ្យត្រង់បាន។

**៣៤. វារិជោវ ថលេ ខិត្តោ, ឱកមោកតឧព្ភតោ;**
**បរិផន្ទតិទំ ចិត្តំ, មារធេយ្យំ បហាតវេ។**

ចិត្តនេះ ដែលបុគ្គលលើកឡើងចាកទីអាល័យ (គឺកាមគុណ៥) បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីអាល័យគឺទឹក បោះទៅលើគោកដូច្នោះឯង។

**៣៥. ទុន្និគ្គហស្ស លហុនោ, យត្ថកាមនិបាតិនោ;**
**ចិត្តស្ស ទមថោ សាធុ, ចិត្តំ ទន្តំ សុខាវហំ។**

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច, (ព្រោះថា) ចិត្តដែលទូន្មានបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

**៣៦. សុទុទ្ទសំ សុនិបុណំ, យត្ថកាមនិបាតិនំ;**
**ចិត្តំ រក្ខេថ មេធាវី, ចិត្តំ គុត្តំ សុខាវហំ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលឃើញបានដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ, (ព្រោះថា)ចិត្តដែលរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

**៣៧. ទូរង្គមំ ឯកចរំ, អសរីរំ គុហាសយំ;**
**យេ ចិត្តំ សញ្ញមេស្សន្តិ, មោក្ខន្តិ មារពន្ធនា។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប៤ ជាទីអាស្រ័យនៅ, អ្នកទាំងឡាយនោះឯង រមែងរួចផុតចាកចំណងនៃមារ ។

**៣៨. អនវដ្ឋិតចិត្តស្ស, សទ្ធម្មំ អវិជានតោ;**
**បរិប្លវបសាទស្ស, បញ្ញា ន បរិបូរតិ។**

បញ្ញារមែងមិនបរិបូណ៌ដល់អ្នកមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ។

**៣៩. អនវស្សុតចិត្តស្ស, អនន្វាហតចេតសោ;**
**បុញ្ញបាបបហីនស្ស, នត្ថិ ជាគរតោ ភយំ។**

ភ័យរមែងមិនមាន ដល់អ្នកមានចិត្តមិនទទឹកដោយរាគៈ

មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនិង បាបលះចោលហើយ ភ្ញាក់រលឹកជានិច្ច។

**៤០. កុម្ភូបមំ កាយមិមំ វិទិត្វា, នគរូបមំ ចិត្តមិទំ ឋបេត្វា;**
**យោធេថ មារំ បញ្ញាវុធេន, ជិតញ្ច រក្ខេ អនិវេសនោ សិយា។**

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះ ថាដូចជាក្អម, គប្បី បិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ ហើយច្បាំងនឹងមារ ដោយអាវុធគឺបញ្ញា, គប្បីរក្សានូវជម្នះដែលឈ្នះហើយ គប្បីជាអ្នកមិននៅជំអក់(ក្នុងសមាបត្តិ)។

**៤១. អចិរំ វតយំ កាយោ, បឋវឹ អធិសេស្សតិ;**
**ឆុទ្ធោ អបេតវិញ្ញាណោ, និរត្ថំវ កលិង្គរំ។**

កាយនេះ មិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅ ប្រាសហើយជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់ នៅលើផែនដី ដូចជាអង្កត់អុសរកប្រយោជន៍គ្មាន។

**៤២. ទិសោ ទិសំ យំ តំ កយិរា, វេរី វា បន វេរិនំ;**
**មិច្ឆាបណិហិតំ ចិត្តំ, បាបិយោ នំ តតោ ករេ។**

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រលេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តី វិនាសណាមួយដល់គ្នា, ចិត្តដែលបុគ្គលតម្កល់ទុកខុស ហើយ រមែងធ្វើនូវបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែង ជាង

វិនាសនោះទៅទៀត។

**៤៣. ន តំ មាតា បិតា កយិរា, អញ្ញេ វាបិ ច ញាតកា;**
**សម្មាបណិហិតំ ចិត្តំ, សេយ្យសោ នំ តតោ ករេ។**

មាតា បិតា ឬក៏ពួកជនដទៃជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន, (ចំនែកខាង) ចិត្តដែលបុគ្គលតម្កល់ទុកត្រូវហើយ រមែងធ្វើនូវបុគ្គលនោះ ឲ្យប្រសើរក្រៃលែង ជាងហេតុនោះទៅទៀត។

**ចិត្តវគ្គោ តតិយោ និដ្ឋិតោ។**

ចិត្តវគ្គ ទី៣ ចប់ ។

## ៤. បុប្ផវគ្គ

**៤៤. កោ ឥមំ បឋវឹ វិចេស្សតិ, យមលោកញ្ច ឥមំ សទេវកំ;**
**កោ ធម្មបទំ សុទេសិតំ, កុសលោ បុប្ផមិវ បចេស្សតិ។**

អ្នកណានឹងដឹងច្បាស់ នូវផែនដីគឺអត្តភាពនេះផង នូវយមលោកគឺអបាយភូមិ៤ផង នូវមនុស្សលោកនេះ ព្រមទាំងទេវលោកផង, អ្នកណានឹងដឹងច្បាស់ នូវចំនែកនៃធម៌ ដែលតថាគតសំដែងហើយដោយប្រពៃ ដូចមាលាការដែលឈ្លាសវៃ ដឹងហើយជ្រើសរើសយកតែផ្កាល្អប៉ុណ្ណោះ។

**៤៥. សេខោ បឋវឹ វិចេស្សតិ, យមលោកញ្ច ឥមំ សទេវកំ;**
**សេខោ ធម្មបទំ សុទេសិតំ, កុសលោ បុប្ផមិវ បចេស្សតិ។**

សេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះផង នូវយមលោកគឺអបាយភូមិ៤ផង នូវមនុស្សលោកនេះ ព្រមទាំងទេវលោកផង, សេក្ខបុគ្គល នឹងដឹងច្បាស់ នូវចំនែកនៃធម៌ ដែលតថាគតសំដែងហើយដោយប្រពៃ ដូចមាលាការដែលឈ្លាសវៃ ដឹងហើយ ជ្រើសរើសយកតែផ្កាល្អប៉ុណ្ណោះ។

**៤៦. ផេណូបមំ កាយមិមំ វិទិត្វា, មរីចិធម្មំ អភិសម្ពុធានោ;**
**ឆេត្វាន មារស្ស បបុប្ផកានិ, អទស្សនំ មច្ចុរាជស្ស គច្ឆេ។**

ភិក្ខុកាលដឹងច្បាស់នូវកាយនេះ ថាដូចជាដុំពពុះទឹក ដឹងច្បាស់ នូវកាយនេះ ថាមានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវកម្រងផ្កានៃមារគឺវដ្តៈ៣ ហើយទៅកាន់ទីជាទីមិនឃើញនៃមច្ចុរាជ។

**៤៧. បុប្ផានិ ហេវ បចិនន្តំ, ព្យាសត្តមានសំ នរំ;**
**សុត្តំ គាមំ មហោឃោវ, មច្ចុ អាទាយ គច្ឆតិ។**

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកទៅនូវនរជន ដែលកំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ មានចិត្តជាប់ជំពាក់ដោយអាការៈផ្សេងៗនុ៎ះឯង ដូចទឹកជំនន់ដ៏ធំ ដែលក្មួច

នាំយកនូវអ្នកស្រុកកំពុងតែដេកលក់ដូច្នោះឯង ។

**៤៨. បុប្ផានិ ហេវ បចិនន្តំ, ព្យាសត្តមនសំ នរំ;**
**អតិត្តំយេវ* កាមេសុ, អន្តកោ កុរុតេ វសំ។**

អន្តកៈគឺសេចក្តីស្លាប់ តែងក្រុងនូវនរជន ដែលកំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ មានចិត្តជាប់ជំពាក់ដោយអាការៈផ្សេងៗ មិនទាន់ឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុ៎ះឯង ឲ្យឋិតនៅក្នុងអំនាចរបស់ខ្លួន ។

**៤៩. យថាបិ ភមរោ បុប្ផំ, វណ្ណគន្ធមហេឋយំ;**
**បលេតិ រសមាទាយ, ឯវំ គាមេ មុនី ចរេ។**

ដូចជាភូមរា(សត្វក្រេបផ្កា) មិនធ្វើផ្កាដែលមានពណ៌ និងក្លិនឲ្យវិនាស ក្រេបយកតែរស ហើយហើរទៅ យ៉ាងណា, អ្នកប្រាជ្ញត្រាច់ទៅ (ដើម្បីភិក្ខា)ក្នុងស្រុក (មិនធ្វើសទ្ធានិងទ្រព្យនៃត្រកូលឲ្យវិនាស) ក៏យ៉ាងនោះឯង។

**៥០. ន បរេសំ វិលោមានិ, ន បរេសំ កតាកតំ;**
**អត្តនោវ អវេក្ខេយ្យ, កតានិ អកតានិ ច។**

ពាក្យអាក្រក់របស់ពួកជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ, កិច្ចដែលធ្វើហើយនិងមិនទាន់ធ្វើ របស់ពួកជនដទៃ បុគ្គលមិនគួរចាំឃ្លាំមើលទេ; បុគ្គលគួរពិនិត្យមើលតែកិច្ចការងារទាំងឡាយដែលហើយ និងនៅមិនទាន់ធ្វើ

របស់ខ្លួនឯងវិញ។

**៥១. យថាបិ រុចិរំ បុប្ផំ, វណ្ណវន្តំ អគន្ធកំ;**
**ឯវំ សុភាសិតា វាចា, អផលា ហោតិ អកុព្វតោ។**

ដូចជាផ្កាល្អ បរិបូណ៌ដោយពណ៌ តែគ្មានក្លិន យ៉ាងណា, វាចាដែលបុគ្គលពោលល្អហើយ ជាគុណជាតិមិនមានផល ដល់បុគ្គលដែលមិនធ្វើតាម ក៏យ៉ាងនោះឯង ។

**៥២. យថាបិ រុចិរំ បុប្ផំ, វណ្ណវន្តំ សុគន្ធកំ;**
**ឯវំ សុភាសិតា វាចា, សផលា ហោតិ កុព្វតោ។**

ដូចជាផ្កាល្អ បរិបូណ៌ដោយពណ៌ មានក្លិនក្រអូប យ៉ាងណា, វាចាដែលបុគ្គលពោលល្អហើយ ជាគុណជាតិមានផល ដល់បុគ្គលដែលធ្វើតាម ក៏យ៉ាងនោះឯង ។

**៥៣. យថាបិ បុប្ផរាសិម្ហា, កយិរា មាលាគុណេ ពហូ;**
**ឯវំ ជាតេន មច្ចេន, កត្តព្វំ កុសលំ ពហុំ។**

ដូចជាមាលាការចេះធ្វើសំណុំកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗគ្នា)ឲ្យច្រើន យ៉ាងណា, កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន ក៏យ៉ាងនោះឯង ។

**៥៤. ន បុប្ផគន្ធោ បដិវាតមេតិ,**
**ន ចន្ទនំ តគរមល្លិកា;**
**សតញ្ច គន្ធោ បដិវាតមេតិ,**

**សព្វា ទិសា សប្បុរិសោ បវាយតិ។**

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន, ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន, ចំណែកក្លិន របស់សប្បុរសទាំងឡាយ ទើបផ្សាយទៅច្រាសខ្យល់បាន គឺក្លិនរបស់សប្បុរស រមែងផ្សាយទៅបានគ្រប់ទិសទាំងអស់។

**៥៥. ចន្ទនំ តគរំ វាបិ, ឧប្បលំ អថ វស្សិកី;**
**ឯតេសំ គន្ធជាតានំ, សីលគន្ធោ អនុត្តរោ។**

ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាឧប្បលក្តី ក្លិនផ្កាម្លិះក្តី ក្លិននៃសីល ជាគុណជាតប្រសើរបំផុតជាងក្លិនទាំងនុ៎ះ។

**៥៦. អប្បមត្តោ អយំ គន្ធោ, យ្វាយំ តគរចន្ទនំ;**
**យោ ច សីលវតំ គន្ធោ, វាតិ ទេវេសុ ឧត្តមោ។**

ក្លិនខ្លឹមក្រស្នានិងក្លិនខ្លឹមចន្ទន៍ឯណា ក្លិននេះ ក្រអូបមានប្រមាណតិច, ចំណែកក្លិនរបស់បុគ្គលអ្នកមានសីលទាំងឡាយឯណា ក្លិននោះ ទើបក្រអូបលើសលប់ផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន។

**៥៧. តេសំ សម្បន្នសីលានំ, អប្បមាទវិហារិនំ;**
**សម្មទញ្ញា វិមុត្តានំ, មារោ មគ្គំ ន វិន្ទតិ។**

មារាធិរាជ (ទុកជាស្វែងរក) ក៏មិនជួបនូវផ្លូវ របស់ពួកលោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្ដីមិនប្រមាទ អ្នកដឹងច្បាស់តាមហេតុ រួចស្រឡះហើយ[2] ។

**៥៨. យថា សង្ការឋានស្មឹ, ឧជ្ឈិតស្មឹ មហាបថេ;**
**បទុមំ តត្ថ ជាយេថ, សុចិគន្ធំ មនោរមំ។**
**៥៩. ឯវំ សង្ការភូតេសុ, អន្ធភូតេ បុថុជ្ជនេ;**
**អតិរោចតិ បញ្ញាយ, សម្មាសម្ពុទ្ធសាវកោ។**

ផ្កាឈូក ទុកជាដុះក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្ដេចមិញ, បណ្ដាជនទាំងឡាយ ដូចគំនរសំរាមកើតហើយ សាវករបស់សម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតនូវបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ ដោយបញ្ញា (របស់ខ្លួន) ក៏ដូច្នោះឯង។

**បុប្ផវគ្គោ ចតុត្ថោ និដ្ឋិតោ។**

បុប្ផវគ្គ ទី៤ ចប់ ។

---

2 រួចស្រឡះហើយ ដោយវិមុត្តិទាំង៥នេះ គឺតទង្គវិមុត្តិ១ វិក្ខម្ភនវិមុត្តិ១ សមុច្ឆេទវិមុត្តិ១ បដិបស្សទ្ធិវិមុត្តិ១ និស្សរណវិមុត្តិ១ ។ តព្វណ្ណនានិងវណ្ណនារបស់ពួកសូត្រដទៃទៀត។

# ៥. ពាលវគ្គ

**៦០. ទីឃា ជាគរតោ រត្តិ, ទីឃំ សន្តស្ស យោជនំ;**
**ទីឃោ ពាលាន សំសារោ, សទ្ធម្មំ អវិជានតំ។**

រាត្រីយូរ សំរាប់អ្នកភ្ញាក់(ដេកមិនលក់), យោជន៍វែងឆ្ងាយ សំរាប់អ្នកនឿយហត់, សំសារវែងឆ្ងាយ សំរាប់ពួកបុគ្គលពាល អ្នកមិនដឹងនូវព្រះសទ្ធម្ម។

**៦១. ចរញ្ចេ នាធិគច្ឆេយ្យ, សេយ្យំ សទិសមត្តនោ;**
**ឯកចរិយំ ទឡ្ហំ កយិរា, នត្ថិ ពាលេ សហាយតា។**

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហាយតាគុណមិនមានក្នុងបុគ្គលពាលឡើយ។

**៦២. បុត្តា មត្ថិ ធនម្មត្ថិ, ឥតិ ពាលោ វិហញ្ញតិ;**
**អត្តា អត្តនោ នត្ថិ, កុតោ បុត្តា កុតោ ធនំ។**

បុគ្គលពាលតែងព្រួយលំបាក (ដោយតណ្ហា)ថា "កូនទាំងឡាយ របស់អញមាន, ទ្រព្យរបស់អញមាន"; តាមដែលពិត សូម្បីខ្លួនរបស់ខ្លួន ក៏មិនមាន; កូនទាំងឡាយនឹងមានមកអំពីណា, ទ្រព្យនឹងមានមកអំពីណា ។

**៦៣. យោ ពាលោ មញ្ញតី ពាល្យំ, បណ្ឌិតោ វាបិ តេន សោ;**
**ពាលោ ច បណ្ឌិតមានី, ស វេ ពាលោតិ វុច្ចតិ។**

អ្នកណា ជាបុគ្គលពាល ដឹងនូវភាពនៃខ្លួនថាជាពាល, អ្នកនោះ នឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងនូវខ្លួនថាជាពាលនោះ; ចំណែកអ្នកណា ជាបុគ្គលពាល មានសេចក្តីប្រកាន់ខ្លួនថាជាបណ្ឌិត, អ្នកនោះឯង គឺគេហៅថា ពាល មែន។

**៦៤. យាវជីវម្បិ ចេ ពាលោ, បណ្ឌិតំ បយិរុបាសតិ;**
**ន សោ ធម្មំ វិជានាតិ, ទព្វី សូបរសំ យថា។**

បុគ្គលពាល បើចូលទៅអង្គុយជិតបណ្ឌិត សូម្បីអស់មួយជីវិត ក៏គេឥតដឹងធម៌(អ្វីឲ្យច្បាស់លាស់ឡើយ) ដូចវែកដែលឥតដឹងរសសម្លដូច្នោះឯង ។

**៦៥. មុហុត្តមបិ ចេ វិញ្ញូ, បណ្ឌិតំ បយិរុបាសតិ;**
**ខិប្បំ ធម្មំ វិជានាតិ, ជិវ្ហា សូបរសំ យថា។**

វិញ្ញូជន បើចូលទៅអង្គុយជិតបណ្ឌិត សូម្បីតែមួយរំពេច ក៏អាចដឹងធម៌បាន ដោយឆាប់រហ័ស ដូចអណ្តាតដែលអាចដឹងរសសម្លបានភ្លាមដូច្នោះឯង ។

**៦៦. ចរន្តិ ពាលា ទុម្មេធា, អមិត្តេនេវ អត្តនា;**
**ករោន្តា បាបកំ កម្មំ, យំ ហោតិ កដុកប្ផលំ។**

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនឯងដូចជាសត្រូវ តែងដើរធ្វើតែកម្មលាមក ជាអំពើមានផលក្តៅក្រហាយ។

**៦៧. ន តំ កម្មំ កតំ សាធុ, យំ កត្វា អនុតប្បតិ;**
**យស្ស អស្សុមុខោ រោទំ, វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ឬមានមុខទទឹងដោយទឹកភ្នែក ស្រែកយំទទួលផលនៃកម្មណា, កម្មដែលគេធ្វើហើយនោះ ជាអំពើមិនល្អឡើយ ។

**៦៨. តញ្ច កម្មំ កតំ សាធុ, យំ កត្វា នានុតប្បតិ;**
**យស្ស បតីតោ សុមនោ, វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តសប្បាយទទួលផលនៃកម្មណា, កម្មដែលគេធ្វើហើយនោះឯង ជាអំពើល្អមែន។

**៦៩. មធុវា មញ្ញតី ពាលោ, យាវ បាបំ ន បច្ចតិ;**
**យទា ច បច្ចតិ បាបំ, ពាលោ ទុក្ខំ និគច្ឆតិ។**

បាបមិនទាន់ឲ្យផលត្រឹមណា, ជនពាលតែងសំគាល់នូវបាបនោះថា ដូចទឹកឃ្មុំ; លុះក្នុងកាលណា បាបឲ្យផល, ជនពាលទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលនោះ។

**៧០. មាសេ មាសេ កុសគ្គេន, ពាលោ ភុញ្ជេយ្យ ភោជនំ;**
**ន សោ សង្ខាតធម្មានំ, កលំ អគ្ឃតិ សោឡសឹ។**

ជនពាលទុកជាបរិភោគ ដោយចុងស្បូវ រាល់ៗខែ, គេក៏មិនដល់មួយចំណិតនៃចំនែកទី១៦ (ដែលគេបែងចែកហើយអស់១៦លើក) របស់បុគ្គលទាំងឡាយអ្នកមានធម៌បានដឹង ឬបានពិចារណាហើយឡើយ។

**៧១. ន ហិ បាបំ កតំ កម្មំ, សជ្ជុ ខីរំវ មុច្ចតិ;**
**ឌហន្តំ ពាលមន្វេតិ, ភស្មច្ឆន្នោវ បាវកោ។**

បាបកម្មដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច)ដូច្នោះ, តែបាបកម្មនោះ រមែងតាមដុតជនពាល ដូចរងើកភ្លើងដែលបិទបាំងដោយផេះដូច្នោះ។

**៧២. យាវទេវ អនត្ថាយ, ញត្តំ ពាលស្ស ជាយតិ;**
**ហន្តិ ពាលស្ស សុក្កំសំ, មុទ្ធំ អស្ស វិបាតយំ។**

ការចេះដឹង កើតឡើងដល់ជនពាល គ្រាន់តែសេចក្តីវិនាសប៉ុណ្ណោះ រមែងញុំាងមុទ្ធៈគឺបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំនែកធម៌ស គឺកុសល របស់ជនពាលនោះ ។

**៧៣. អសន្តំ ភាវនមិច្ឆេយ្យ, បុរេក្ខារញ្ច ភិក្ខុសុ;**
**អាវាសេសុ ច ឥស្សរិយំ, បូជា បរកុលេសុ ច។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន(ក្នុងខ្លួន)ផង នូវបរិវារក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ

ក្នុងអាវាសទាំងឡាយផង នូវការបូជាក្នុងពួកត្រកូលដទៃផង។

**៧៤. មមេវ កត មញ្ញន្តុ, គិហីបព្វជិតា ឧភោ;**
**មមេវាតិវសា អស្សុ, កិច្ចាកិច្ចេសុ កិស្មិចិ;**
**ឥតិ ពាលស្ស សង្កប្បោ, ឥស្សា មានោ ច វឌ្ឍតិ។**

ភិក្ខុពាលតែងមានសេចក្ដីត្រិះរិះថា "គ្រហស្ថនិងបព្វជិតទាំងពីរពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយព្រោះអាស្រ័យអញប៉ុណ្ណោះ, អំនាចដ៏ក្រៃលែង របស់អញ ចូរមានក្នុងបណ្ដាកិច្ចតូចកិច្ចធំ កិច្ចណាមួយ" (កាលបើយ៉ាងនេះ) ឥស្សានិងមានះ រមែងចំរើន។

**៧៥. អញ្ញា ហិ លាភូបនិសា, អញ្ញា និព្វានគាមិនី;**
**ឯវមេតំ អភិញ្ញាយ, ភិក្ខុ ពុទ្ធស្ស សាវកោ;**
**សក្ការំ នាភិនន្ទេយ្យ, វិវេកមនុព្រូហយេ។**

បដិបទាអាស្រ័យនូវលាភផ្សេង បដិបទាជាដំនើរទៅកាន់ព្រះនិព្វានផ្សេង, ភិក្ខុជាសាវករបស់ព្រះពុទ្ធ បានដឹងនូវហេតុនុ៎ះយ៉ាងនេះហើយ មិនគប្បីត្រេកអរ ចំពោះលាភសក្ការៈ គប្បីញុំាងវិវេកឲ្យចំរើនដោយលំដាប់។

**ពាលវគ្គោ បញ្ចមោ និដ្ឋិតោ។**

ពាលវគ្គ ទី៥ ចប់ ។

# ៦. បណ្ឌិតវគ្គ

**៧៦. និធីនំវ បវត្តារំ, យំ បស្សេ វជ្ជទស្សិនំ;**
**និគ្គយ្ហវាទឹ មេធាវឹ, តាទិសំ បណ្ឌិតំ ភជេ;**
**តាទិសំ ភជមានស្ស, សេយ្យោ ហោតិ ន បាបិយោ។**

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិនចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ, គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា)កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

**៧៧. ឱវទេយ្យានុសាសេយ្យ, អសព្ភា ច និវារយេ;**
**សតញ្ហិ សោ បិយោ ហោតិ, អសតំ ហោតិ អប្បិយោ។**

បណ្ឌិតតែងទូន្មានប្រៀនប្រដៅ តែងហាមឃាត់ចាកអកុសលធម៌, បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់ពួកសប្បុរស មិនជាទីស្រលាញ់របស់ពួកអសប្បុរសទេ។

**៧៨. ន ភជេ បាបកេ មិត្តេ, ន ភជេ បុរិសាធមេ;**
**ភជេថ មិត្តេ កល្យាណេ, ភជេថ បុរិសុត្តមេ។**

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

**៧៩. ធម្មបីតិ សុខំ សេតិ, វិប្បសន្នេន ចេតសា;**

**អរិយប្បវេទិតេ ធម្មេ, សទា រមតិ បណ្ឌិតោ។**

បណ្ឌិតដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ ដែលព្រះអរិយៈប្រកាសទុកហើយ គ្រប់ពេល ។

**៨០. ឧទកញ្ហិ នយន្តិ នេត្តិកា, ឧសុការា នមយន្តិ តេជនំ;**
**ទារុំ នមយន្តិ តច្ឆកា, អត្តានំ ទមយន្តិ បណ្ឌិតា។**

ធម្មតាពួកអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, ពួកអ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់), ពួកអ្នកចាំងឈើ តែងចាំងឈើ, ឯពួកបណ្ឌិត តែងទូន្មានខ្លួន ។

**៨១. សេលោ យថា ឯកឃនោ, វាតេន ន សមីរតិ;**
**ឯវំ និន្ទាបសំសាសុ, ន សមិញ្ជន្តិ បណ្ឌិតា។**

ភ្នំថ្មតាន់ មិនកម្រើកព្រោះខ្យល់ ដូចម្ដេចមិញ, បណ្ឌិតទាំងឡាយ ក៏មិនកម្រើក ព្រោះពាក្យតិះដៀលនិងពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

**៨២. យថាបិ រហទោ គម្ភីរោ, វិប្បសន្នោ អនាវិលោ;**
**ឯវំ ធម្មានិ សុត្វាន, វិប្បសីទន្តិ បណ្ឌិតា។**

អន្លង់ទឹកជ្រៅ ជាទឹកថ្លា មិនល្អក់ យ៉ាងណា, បណ្ឌិតទាំងឡាយ បើបានស្ដាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួន ក៏យ៉ាងនោះដែរ ។

**៨៣. សព្វត្ថ វេ សប្បុរិសា ចជន្តិ,**
**ន កាមកាមា លបយន្តិ សន្តោ;**
**សុខេន ផុដ្ឋា អថ វា ទុខេន,**
**ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ។**

ពួកសប្បុរស តែងលះ (ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង (មានបញ្ចក្ខន្ធជាដើម), ពួកសប្បុរសមិនពោល ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការៈឡើងចុះឡើយ ។

**៨៤. ន អត្តហេតុ ន បរស្ស ហេតុ,**
**ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ;**
**ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ,**
**ស សីលវា បញ្ញវា ធម្មិកោ សិយា។**

បណ្ឌិតតែងមិនធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសមិទ្ធិ ដើម្បីខ្លួន ដោយអធម៌ឡើយ បុគ្គលនោះ គួរជាអ្នកមានសីល អ្នកមានបញ្ញា អ្នកមានធម៌ ។

**៨៥. អប្បកា តេ មនុស្សេសុ, យេ ជនា បារគាមិនោ;**
**អថាយំ ឥតរា បជា, តីរមេវានុធាវតិ។**

**៨៦. យេ ច ខោ សម្មទក្ខាតេ, ធម្មេ ធម្មានុវត្តិនោ;**
**តេ ជនា បារមេស្សន្តិ, មច្ចុធេយ្យំ សុទុត្តរំ។**

បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយគឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច, ចំនែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ)។ ពួកជនណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ដែលតថាគតសំដែងទុកហើយដោយប្រពៃ, ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់ត្រើយគឺព្រះនិព្វាន ។

**៨៧. កណ្ហំ ធម្មំ វិប្បហាយ, សុក្កំ ភាវេថ បណ្ឌិតោ;**
**ឱកា អនោកមាគម្ម, វិវេកេ យត្ថ ទូរមំ។**
**៨៨. តត្រាភិរតិមិច្ឆេយ្យ, ហិត្វា កាមេ អកិញ្ចនោ;**
**បរិយោទបេយ្យ អត្តានំ, ចិត្តក្លេសេហិ បណ្ឌិតោ។**
**៨៩. យេសំ សម្ពោធិយង្គេសុ, សម្មា ចិត្តំ សុភាវិតំ;**
**អាទានបដិនិស្សគ្គេ, អនុបាទាយ យេ រតា;**
**ខីណាសវា ជុតិមន្តោ, តេ លោកេ បរិនិព្វុតា។**

បណ្ឌិតគប្បីលះបង់ធម៌ខ្មៅ ចេញចាកអាល័យគឺកាមគុណ អាស្រ័យនូវព្រះនិព្វាន គឺធម្មជាតមិនមានអាល័យចម្រើនតែធម៌ស, គប្បីលះបង់កាមទាំងឡាយចេញ ជា

អ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេក (គឺព្រះនិព្វាន) ដែលពួកសត្វត្រេកអរបាន ដោយកម្រ នោះ គប្បីញ៉ាំងខ្លួនឲ្យផូរផង់ ចាកគ្រឿងសៅហ្មងចិត្ត ។

ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរក្នុងការលះបង់នូវសេចក្តីប្រកាន់មាំ, បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានក្នុងលោក។

**បណ្ឌិតវគ្គោ ឆដ្ឋោ និដ្ឋិតោ។**

បណ្ឌិតវគ្គ វគ្គទី ៦ ចប់ ។

## ៧. អរហន្តវគ្គ

**៩០. គតទ្ធិនោ វិសោកស្ស, វិប្បមុត្តស្ស សព្វធិ;**

**សព្វគន្ថប្បហីនស្ស, បរិឡាហោ ន វិជ្ជតិ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម) មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួងលះបង់ហើយ។

**៩១. ឧយ្យុញ្ជន្តិ សតីមន្តោ, ន និកេតេ រមន្តិ តេ;**

**ហំសាវ បល្លលំ ហិត្វា, ឱកមោកំ ជហន្តិ តេ។**

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងព្យាយាម (ក្នុងឈានាទិគុណដែលខ្លួនសម្រេចហើយ ដោយការនឹកជាដើម) មិនត្រេកអរក្នុងទីនៅអាស្រ័យ, ពួកលោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចពួកហង្សលះបង់ភក់ហើរទៅដូច្នោះ។

**៩២. យេសំ សន្និចយោ នត្ថិ, យេ បរិញ្ញាតភោជនា;**
**សុញ្ញតោ អនិមិត្តោ ច, វិមោក្ខោ យេសំ គោចរោ;**
**អាកាសេ វ សកុន្តានំ, គតិ តេសំ ទុរន្នយា។**

ពួកជនណា មិនមានសេចក្តីសន្សំ, ពួកជនណាកំណត់ដឹងភោជនហើយ, ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ; គតិគឺដំណើរ របស់ពួកជននោះៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

**៩៣. យស្សាសវា បរិក្ខីណា, អាហារេ ច អនិស្សិតោ;**
**សុញ្ញតោ អនិមិត្តោ ច, វិមោក្ខោ យស្ស គោចរោ;**
**អាកាសេ វ សកុន្តានំ, បទំ តស្ស ទុរន្នយំ។**

ជនណា អស់អាសវៈហើយ, ទាំងមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ក្នុងអាហារ, ជនណា មានសុញ្ញតវិមោក្ខ

អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ; ដំនើរ របស់ជននោះ គេកម្រដឹងបាន ដូចដំនើរនៃពួកសត្វ ស្លាបឰដ៏អាកាស ដូច្នោះ ។

**៩៤. យស្សិន្ទ្រិយានិ សមថង្គតានិ,**
**អស្សា យថា សារថិនា សុទន្តា;**
**បហីនមានស្ស អនាសវស្ស,**
**ទេវាបិ តស្ស បិហយន្តិ តាទិនោ។**

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រំងាប់ ដូចសេះ ដែលនាយសារថីហ្វឹកហ្វឺនបានល្អហើយ សូម្បី ទេវតានិងមនុស្សទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គល មានចិត្តនឹងធឹង មិនញាប់ញ័រ ។

**៩៥. បថវិសមោ នោ វិរុជ្ឈតិ, ឥន្ទខិលុបមោ តាទិ សុព្វតោ;**
**រហទោវ អបេតកទ្ទមោ, សំសារា ន ភវន្តិ តាទិនោ។**

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្ត នឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាក ភក់, សំសារទាំងឡាយនៃភិក្ខុបែបនោះ រមែងមិនមាន។

**៩៦. សន្តំ តស្ស មនំ ហោតិ, សន្តា វាចា ច កម្ម ច;**
**សម្មទញ្ញា វិមុត្តស្ស, ឧបសន្តស្ស តាទិនោ។**

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោកដែលដឹងតាមហេតុ រួចផុតស្រឡះហើយ (ចាករាគាទិក្កិលេស) ជាអ្នកស្ងប់រំងាប់ ដូច្នោះ ។

**៩៧. អស្សទ្ធោ អកតញ្ញូ ច, សន្ធិច្ឆេទោ ច យោ នរោ;**
**ហតាវកាសោ វន្តាសោ, ស វេ ឧត្តមបោរិសោ។**

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងតគឺវដ្តសំសារផង មានឱកាស(គឺការកើត) កំចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាបុរសដ៏ឧត្តម។

**៩៨. គាមេ វា យទិ វារញ្ញេ, និន្នេ វា យទិ វា ថលេ;**
**យត្ថ អរហន្តោ វិហរន្តិ, តំ ភូមិរាមណេយ្យកំ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។

**៩៩. រមណីយានិ អរញ្ញានិ, យត្ថ ន រមតី ជនោ;**
**វីតរាគា រមិស្សន្តិ, ន តេ កាមគវេសិនោ។**

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃទាំងឡាយ ដែលជាទីគួររីករាយទេ, តែពួកព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរ (ក្នុងព្រៃ

ទាំងឡាយបែបនោះ) ព្រោះថាពួកលោកមិនមែនជាអ្នកស្វែងរកកាមទេ ។

**អរហន្តវគ្គោ សត្តមោ និដ្ឋិតោ។**

អរហន្តវគ្គ វគ្គទី ៧ ចប់ ។

## ៨. សហស្សវគ្គ

**១០០. សហស្សមបិ ចេ វាចា, អនត្ថបទសំហិតា;**

**ឯកំ អត្ថបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។**

បើវាចាសូម្បីមួយពាន់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ (វាចានោះពុំប្រសើរឡើយ) បុគ្គលស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រំងាប់បាន បទមានប្រយោជន៍នោះសូម្បីតែ១បទ ក៏ឈ្មោះថាប្រសើរជាង។

**១០១. សហស្សមបិ ចេ គាថា, អនត្ថបទសំហិតា;**

**ឯកំ គាថាបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។**

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ (គាថានោះពុំប្រសើរឡើយ) បុគ្គលស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រំងាប់បាន, បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

**១០២. យោ ច គាថា សតំ ភាសេ, អនត្ថបទសំហិតា;**
**ឯកំ ធម្មបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។**

ក៏អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ (គាថាដែលអ្នកនោះពោលហើយនោះពុំប្រសើរទឡើយ) បុគ្គលស្តាប់បទនៃធម៌ណាហើយ រមែងស្ងប់រំងាប់បាន, បទនៃធម៌នោះសូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង។

**១០៣. យោ សហស្សំ សហស្សេន, សង្គាមេ មានុសេ ជិនេ;**
**ឯកញ្ច ជេយ្យមត្តានំ, ស វេ សង្គាមជុត្តមោ។**

អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម មួយពាន់ៗលើក (គឺមួយលាន), ចំនែកអ្នកណាឈ្នះខ្លួនម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ។

**១០៤. អត្តា ហវេ ជិតំ សេយ្យោ, យា ចាយំ ឥតរា បជា;**
**អត្តទន្តស្ស បោសស្ស, និច្ចំ សញ្ញតចារិនោ។**

**១០៥. នេវ ទេវោ ន គន្ធព្វោ, ន មារោ សហ ព្រហ្មុនា;**
**ជិតំ អបជិតំ កយិរា, តថារូបស្ស ជន្តុនោ។**

ខ្លួនហ្នឹងឯងដែលឈ្នះហើយ ប្រសើរជាង, ចំនែកពួក

សត្វក្រៅនេះ (ដែលឈ្នះហើយ មិនប្រសើរឡើយ); កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច; ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជម្នះ របស់បុរសមានសភាពដូច្នោះ ឲ្យត្រលប់ចាញ់វិញបានឡើយ។

**១០៦. មាសេ មាសេ សហស្សេន, យោ យជេថ សតំ សមំ;**
**ឯកញ្ច ភាវិតត្តានំ, មុហុត្តមបិ បូជយេ;**
**សាយេវ បូជនា សេយ្យោ, យញ្ចេ វស្សសតំ ហុតំ។**

អ្នកណា បូជា(លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ៗខែ អស់មួយរយឆ្នាំ, ចំនែកអ្នកណា គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់មួយរយឆ្នាំនោះ, ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

**១០៧. យោ ច វស្សសតំ ជន្តុ, អគ្គឹ បរិចរេ វនេ;**
**ឯកញ្ច ភាវិតត្តានំ, មុហុត្តមបិ បូជយេ;**
**សាយេវ បូជនា សេយ្យោ, យញ្ចេ វស្សសតំ ហុតំ។**

ក៏ជនណា គប្បីបម្រើភ្លើង ក្នុងព្រៃ អស់មួយរយឆ្នាំ, ចំនែកអ្នកណា លោតែបានបូជានូវព្រះអរិយបុគ្គលមួយ

អង្គ ដែលមានខ្លួនអប់រំហើយ សូម្បីតែមួយរំពេច, ការបូជារបស់អ្នកនោះឯង ប្រសើរជាង, ការបូជា អស់មួយរយឆ្នាំ របស់ជននោះ មិនប្រសើរទ្បើយ។

**១០៨. យំ កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ,**
**សំវច្ឆរំ យជេថ បុញ្ញបេក្ខោ;**
**សព្វម្បិ តំ ន ចតុភាគមេតិ,**
**អភិវាទនា ឧជ្ជុគតេសុ សេយ្យោ។**

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការៈបូជាធំតូចណាមួយ ក្នុងលោក អស់មួយរយឆ្នាំ, ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំនែកទី ៤ នៃការថ្វាយបង្គំ, ឯការថ្វាយបង្គំ ចំពោះព្រះអរិយបុគ្គលទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ មានផលប្រសើរជាង ។

**១០៩. អភិវាទនសីលិស្ស, និច្ចំ វុឌ្ឍាបចាយិនោ,**
**ចត្តារោ ធម្មា វឌ្ឍន្តិ, អាយុ វណ្ណោ សុខំ ពលំ។**

ធម៌ទាំងឡាយ៤ប្រការ គឺអាយុ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ១ កំលាំង១ រមែងចម្រើន អស់កាលជានិច្ចដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំ (ដល់ព្រះរតនត្រ័យ)ជាប្រក្រតី (និង)អ្នកដែលមានសេចក្តីគោរព

កោតក្រែង ដល់បុគ្គលដែលចម្រើនដោយគុណ មានសីលជាដើម (ឬដែលចម្រើនវ័យគឺចាស់ព្រឹទ្ធាចារ្យ)។

**១១០. យោ ច វស្សសតំ ជីវេ, ទុស្សីលោ អសមាហិតោ;**

**ឯកាហំ ជីវិតំ សេយ្យោ, សីលវន្តស្ស ឈាយិនោ។**

ក៏ជនណា គប្បីរស់នៅ អស់មួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនតាំងមាំ, ការរស់នៅតែមួយថ្ងៃ របស់អ្នកដែលមានសីល មានឈាន ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំរបស់ជននោះ ពុំប្រសើរទ្បើយ)។

**១១១. យោ ច វស្សសតំ ជីវេ, ទុប្បញ្ញោ អសមាហិតោ;**

**ឯកាហំ ជីវិតំ សេយ្យោ, បញ្ញវន្តស្ស ឈាយិនោ។**

ក៏ជនណា គប្បីរស់នៅ អស់មួយរយឆ្នាំ ជាមនុស្សមិនមានបញ្ញា មានចិត្តមិនតាំងមាំ, ការរស់នៅតែមួយថ្ងៃ របស់អ្នកដែលមានបញ្ញា មានឈាន ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំរបស់ជននោះ ពុំប្រសើរទ្បើយ)។

**១១២. យោ ច វស្សសតំ ជីវេ, កុសីតោ ហីនវីរិយោ;**

**ឯកាហំ ជីវិតំ សេយ្យោ, វីរិយំ អារភតោ ទឡ្ហំ។**

ក៏ជនណា គប្បីរស់នៅ អស់មួយរយឆ្នាំ ជាមនុស្សខ្ជិលមានព្យាយាមថោកថយ, ការរស់នៅតែមួយថ្ងៃ របស់អ្នក

ដែលប្រារព្ធព្យាយាមមាំមួន ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំរបស់ជននោះ មិនប្រសើរឡើយ)។

**១១៣. យោ ច វស្សសតំ ជីវេ, អបស្សំ ឧទយព្វយំ;**

**ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ ឧទយព្វយំ។**

ក៏បុគ្គលណា គប្បីរស់នៅ អស់មួយរយឆ្នាំ កាលមិនឃើញការកើតឡើងនិងការវិនាសទៅ(នៃបញ្ចក្ខន្ធ), ការរស់នៅតែមួយថ្ងៃ របស់អ្នកដែលឃើញការកើតឡើងនិងការវិនាសទៅ(នៃបញ្ចក្ខន្ធ) ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំរបស់បុគ្គលនោះ មិនប្រសើរឡើយ)។

**១១៤. យោ ច វស្សសតំ ជីវេ, អបស្សំ អមតំ បទំ;**

**ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ អមតំ បទំ។**

ក៏បុគ្គលណា គប្បីរស់នៅ អស់មួយរយឆ្នាំ កាលមិនឃើញបទដែលមិនស្លាប់ (គឺព្រះនិព្វាន), ការរស់នៅតែមួយថ្ងៃ របស់អ្នកដែលឃើញបទដែលមិនស្លាប់ ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំរបស់បុគ្គលនោះ មិនប្រសើរឡើយ)។

**១១៥. យោ ច វស្សសតំ ជីវេ, អបស្សំ ធម្មមុត្តមំ;**

**ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ ធម្មមុត្តមំ។**

ក៏បុគ្គលណា គប្បីរស់នៅ អស់មួយរយឆ្នាំ កាលមិន

ឃើញធម៌ដ៏ខ្ពង់ខ្ពស់(គឺលោកុត្តរធម៌), ការរស់នៅតែមួយថ្ងៃ របស់អ្នកដែលឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង, (ការរស់នៅអស់មួយរយឆ្នាំ របស់បុគ្គលនោះ មិនប្រសើរឡើយ)។

**សហស្សវគ្គោ អដ្ឋមោ និដ្ឋិតោ។**

សហស្សវគ្គ ទី៨ ចប់ ។

## ៩. បាបវគ្គ

**១១៦. អភិត្ថរេថ កល្យាណេ, បាបា ចិត្តំ និវារយេ;**
**ទន្ធំ ហិ ករោតោ បុញ្ញំ, បាបស្មឹ រមតី មនោ។**

បុគ្គល គួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

**១១៧. បាបញ្ចេ បុរិសោ កយិរា, ន នំ កយិរា បុនប្បុនំ;**
**ន តម្ហិ ឆន្ទំ កយិរាថ, ទុក្ខោ បាបស្ស ឧច្ចយោ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំមកនូវសេចក្តីទុក្ខ ។

**១១៨. បុញ្ញញ្ចេ បុរិសោ កយិរា, កយិរាថេនំ បុនប្បុនំ;**
**តម្ហិ ឆន្ទំ កយិរាថ, សុខោ បុញ្ញស្ស ឧច្ចយោ។**

បើបុរសធ្វើបុណ្យ គប្បីធ្វើបុណ្យនោះរឿយៗ គប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំមកនូវសេចក្ដីសុខ ។

**១១៩. បាបោបិ បស្សតី ភទ្រំ, យាវ បាបំ ន បច្ចតិ;**
**យទា ច បច្ចតី បាបំ, អថ បាបោ បាបានិ បស្សតិ។**

បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចម្រើនត្រឹមណោះ លុះកាលណាបាបឲ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

**១២០. ភទ្រោបិ បស្សតី បាបំ, យាវ ភទ្រំ ន បច្ចតិ;**
**យទា ច បច្ចតី ភទ្រំ, អថ ភទ្រោ ភទ្រានិ បស្សតិ។**

អំពើល្អមិនទាន់ឲ្យផលត្រឹមណា មនុស្សល្អក៏នៅតែឃើញបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អ ក្នុងកាលនោះ ។

**១២១. មាវមញ្ញេថ បាបស្ស, ន មត្តំ* អាគមិស្សតិ;**
**ឧទពិន្ទុនិបាតេន, ឧទកុម្ភោបិ បូរតិ;**
**ពាលោ បូរតិ[3] បាបស្ស, ថោកំ ថោកំបិ អាចិនំ។**

3 ខ. អាបូរតិ ពាលោ ។ *ឆ. មន្តំ ។ សូម្បីគាថាបន្ទាប់ពីនេះ ក៏ដូច្នេះដែរ។

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ; ប្រៀបដូចក្អមទឹក គង់ពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ (សូម្បីមួយតក់ៗ) យ៉ាងណា; បុគ្គលពាលកាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប ក៏យ៉ាងនោះដែរ ។

**១២២. មាវមញ្ញេថ បុញ្ញស្ស, ន មត្តំ អាគមិស្សតិ;**
**ឧទពិន្ទុនិបាតេន, ឧទកុម្ភោបិ បូរតិ;**
**ធីរោ បូរតិ បុញ្ញស្ស, ថោកំ ថោកំបិ អាចិនំ។**

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ; ប្រៀបដូចក្អមទឹក គង់ពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ (សូម្បីមួយតក់ៗ) យ៉ាងណា; អ្នកមានប្រាជ្ញាកាលសន្សំបុណ្យ សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបុណ្យ ក៏យ៉ាងនោះដែរ ។

**១២៣. វាណិជោវ ភយំ មគ្គំ, អប្បសត្ថោ មហទ្ធនោ;**
**វិសំ ជីវិតុកាមោវ, បាបានិ បរិវជ្ជយេ។**

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់ ចៀសវាងថ្នាំពិស ដូច្នោះដែរ ។

**១២៤. បាណិម្ហិ ចេ វណោ នាស្ស, ហរេយ្យ បាណិនា វិសំ;**
**នាព្វណំ វិសមន្វេតិ, នត្ថិ បាបំ អកុព្វតោ។**

បើដំបៅ មិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃបាន, (ព្រោះថា)ថ្នាំពិស មិនជ្រាបចូលទៅក្នុងបាតដៃដែលគ្មានដំបៅ យ៉ាងណា, បាបរមែងមិនមាន ដល់បុគ្គលអ្នកមិនធ្វើបាប ក៏យ៉ាងនោះដែរ ។

**១២៥. យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ,**
**សុទ្ធស្ស បោសស្ស អនង្គណស្ស;**
**តមេវ ពាលំ បច្ចេតិ បាបំ,**
**សុខុមោ រជោ បដិវាតំវ ខិត្តោ។**

បុគ្គលពាលណាប្រទូស្ត ចំពោះអ្នកមិនប្រទូស្តតប ដែលជាសត្វស្អាតមិនមានកំហុស មិនមានកិលេសដូចជាទីទួល, បាបរមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។

**១២៦. គព្ភមេកេ ឧប្បជ្ជន្តិ, និរយំ បាបកម្មិនោ;**
**សគ្គំ សុគតិនោ យន្តិ, បរិនិព្វន្តិ អនាសវា។**

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស, ពួកអ្នកធ្វើអំពើអាក្រក់ទៅកាន់នរក, ពួកអ្នកធ្វើអំពើល្អជាហេតុនៃសុគតិ ទៅកាន់ស្ថានសួគ៌, ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

**១២៧. ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ,**
**ន បព្វតានំ វិវរំ បវិស្ស;**
**ន វិជ្ជតី សោ ជគតិប្បទេសោ,**
**យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា។**

បុគ្គលឋិតនៅឰដ៏អាកាស ក៏មិនគប្បីរួចចាកបាបកម្ម; ឋិតនៅក្នុងកណ្តាលសមុទ្ទ ក៏មិនគប្បីរួចចាកបាបកម្ម; ចូលទៅកាន់ចន្លោះភ្នំទាំងឡាយ ហើយឋិតនៅ ក៏មិនគប្បីរួចចាកបាបកម្ម; ព្រោះថាបុគ្គលឋិតនៅក្នុងទីកន្លែងលើផែនដីណា គប្បីរួចចាកបាបកម្មបាន, ទីកន្លែងលើផែនដីនោះ មិនមានទេ ។

**១២៨. ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ,**
**ន បព្វតានំ វិវរំ បវិស្ស;**
**ន វិជ្ជតី សោ ជគតិប្បទេសោ,**
**យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ។**

សេចក្តីស្លាប់ មិនមែនមិនគប្បីគ្របសង្កត់ នូវបុគ្គលដែលឋិតនៅឰដ៏អាកាសទេ, មិនមែនមិនគប្បីគ្របសង្កត់ នូវបុគ្គល ដែលឋិតនៅក្នុងកណ្តាលសមុទ្ទទេ, មិនមែនមិនគប្បីគ្របសង្កត់ នូវបុគ្គលដែលចូលទៅកាន់ចន្លោះ

ភ្នំទាំងឡាយ ហើយឋិតនៅទេ; ព្រោះថាសេចក្ដីស្លាប់ មិនគប្បីគ្របសង្កត់ នូវបុគ្គលដែលឋិតនៅ ក្នុងទីកន្លែងលើផែនដីណា, ទីកន្លែងលើផែនដីនោះ មិនមានទេ ។

**បាបវគ្គោ នវមោ និដ្ឋិតោ។**

បាបវគ្គ ទី៩ ចប់ ។

## ១០. ទណ្ឌវគ្គ

**១២៩. សព្វេ តសន្តិ ទណ្ឌស្ស, សព្វេ ភាយន្តិ មច្ចុនោ;**
**អត្តានំ ឧបមំ កត្វា, ន ហនេយ្យ ន ឃាតយេ។**

សត្វទាំងអស់ សុទ្ធតែតក់ស្លុតចំពោះអាជ្ញា, សត្វទាំងអស់ សុទ្ធតែខ្លាចចំពោះសេចក្ដីស្លាប់, បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

**១៣០. សព្វេ តសន្តិ ទណ្ឌស្ស, សព្វេសំ ជីវិតំ បិយំ;**
**អត្តានំ ឧបមំ កត្វា, ន ហនេយ្យ ន ឃាតយេ។**

សត្វទាំងអស់ សុទ្ធតែតក់ស្លុតចំពោះអាជ្ញា, សត្វទាំងអស់ សុទ្ធតែមានជីវិតជាទីស្រលាញ់, បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

**១៣១. សុខកាមានិ ភូតានិ, យោ ទណ្ឌេន វិហឹសតិ;**

**អត្តនោ សុខមេសានោ, បេច្ច សោ ន លភតេ សុខំ។**

ជនណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា, ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ។

**១៣២. សុខកាមានិ ភូតានិ, យោ ទណ្ឌេន ន ហឹសតិ;**

**អត្តនោ សុខមេសានោ, បេច្ច សោ លភតេ សុខំ។**

ជនណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយដែលប្រាថ្នាសេចក្ដីសុខដោយអាជ្ញា, ជននោះលះលោកនេះទៅហើយ រមែងបានសេចក្ដីសុខ។

**១៣៣. មាវោច ផរុសំ កញ្ចិ, វុត្តា បដិវទេយ្យុ តំ;**

**ទុក្ខា ហិ សារម្ភកថា, បដិទណ្ឌា ផុសេយ្យុ តំ។**

អ្នក កុំបានពោលពាក្យអាក្រក់ នឹងបុគ្គលណាមួយឡើយ, ពួកគេដែលអ្នកស្ដីថាឲ្យហើយ គេគប្បីស្ដីថាតបមកអ្នកវិញ, ព្រោះថា ការពោលពាក្យប្រណាំងប្រជែងជាហេតុនាំឲ្យកើតទុក្ខ, អាជ្ញាតបទាំងឡាយ គប្បីប៉ះពាល់នូវអ្នក។

**១៣៤. សចេ នេរេសិ អត្តានំ, កំសោ ឧបហតោ យថា;**
**ឯស បត្តោសិ និព្វានំ, សារម្ភោ តេ ន វិជ្ជតិ។**

បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ)ដូច្នោះ អ្នកជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែងក៏លែងមានដែរ។

**១៣៥. យថា ទណ្ឌេន គោបាលោ, គាវោ បាជេតិ គោចរំ;**
**ឯវំ ជរា ច មច្ចុ ច, អាយុំ បាជេន្តិ បាណិនំ។**

គង្វាលគោ រមែងកៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយអាជ្ញា(គឺដំបងឬរំពាត់) យ៉ាងណាមិញ, ជរា (គឺសេចក្តីទ្រុឌទ្រោម) និងមច្ចុរាជ (គឺសេចក្តីស្លាប់) ក៏កៀងទៅនូវអាយុ របស់សត្វទាំងឡាយ យ៉ាងនោះឯង ។

**១៣៦. អថ បាបានិ កម្មានិ, ករំ ពាលោ ន ពុជ្ឈតិ;**
**សេហិ កម្មេហិ ទុម្មេធោ, អគ្គិទឌ្ឍោវ តប្បតិ។**

បុគ្គលពាលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនដឹងខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយដោយសារតែកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ដូច្នោះ។

**១៣៧. យោ ទណ្ឌេន អទណ្ឌេសុ, អប្បទុដ្ឋេសុ ទុស្សតិ;**
**ទសន្នមញ្ញតរំ ឋានំ, ខិប្បមេវ និគច្ឆតិ។**

**១៣៨. វេទនំ ផរុសំ ជានឹ, សរីរស្ស វ ភេទនំ;**

**គរុកំ វាបិ អាពាធំ, ចិត្តក្ខេបំ វ បាបុណេ។**

**១៣៩. រាជតោ វា ឧបសគ្គំ, អព្ភក្ខានំ វ ទារុណំ;**

**បរិក្ខយំ វ ញាតីនំ, ភោគានំ វ បភង្គុនំ ។**

**១៤០. អថ វាស្ស អគារានិ, អគ្គិ ឌហតិ បាវកោ;**

**កាយស្ស ភេទា ទុប្បញ្ញោ, និរយំ សោបបជ្ជតិ ។**

បុគ្គលណាប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញា មិនប្រទូស្តតប, បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្ដីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាងដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្ដីវិនាសទ្រព្យ ១ ការបែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ការក្រឡុកចិត្ត (ឆ្កួត) ១ ការរឹបជាន់អំពីស្ដេច ១ ការត្រូវគេពោលពាក្យបង្កាច់ដ៏អាក្រក់ ១ ការអស់ពួកញាតិរលីង (ដើម្បីជាទីពឹងនៃខ្លួន) ១ ការពុកផុយនៃភោគសម្បត្តិ ១ ភ្លើងនឹងឆេះបំផ្លាញ នូវផ្ទះរបស់បុគ្គលនោះ ១ លុះគេបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

**១៤១. ន នគ្គចរិយា ន ជដា ន បង្កា,**

**នានាសកា ថណ្ឌិលសាយិកា វា;**

**រជោជល្លំ ឧក្កុដិកប្បធានំ,**

**សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ។**

ការប្រព្រឹត្តអាក្រាតកាយ ការទុកសក់ ការដេកលើភក់ ការមិនបរិភោគបាយ ការដេកលើផែនដី ការប្រឡាក់ខ្លួនដោយធូលី និងការព្យាយាមអង្គុយច្រហោង (សីលព្វតនីមួយៗនេះ) មិនធ្វើបុគ្គលដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យ ឲ្យស្អាតបរិសុទ្ធបានទេ ។

**១៤២. អលង្កតោ ចេបិ សមំ ចរេយ្យ,**
**សន្តោ ទន្តោ និយតោ ព្រហ្មចារី;**
**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ,**
**សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ។**

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអាភរណៈ) តែគប្បីប្រព្រឹត្តស្មើ(ដោយកាយកម្មជាដើម) ជាអ្នកស្ងប់រំងាប់ (ចាករាគៈជាដើម) ទូន្មាន (នូវឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ, បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

**១៤៣. ហិរីនិសេធោ បុរិសោ, កោចិ លោកស្មិ វិជ្ជតិ;**
**យោ និទ្ទំ អបពោធេតិ, អស្សោ ភទ្រោ កសាមិវ។**

បុរសអ្នកកំចាត់បង់ នូវអកុសលវិតក្ក ដោយការខ្មាស

បាប មានតិចក្នុងលោក, បុគ្គលណាបន្ទោរបង់នូវការ ដេកលក់ ដូចសេះល្អខ្លាចរំពាត់ បុរសនោះ រកបាន ដោយក្រក្នុងលោក។

**១៤៤. អស្សោ យថា ភទ្រោ កសានិវិដ្ឋោ,**
**អាតាបិនោ សំវេគិនោ ភវាថ;**
**សទ្ធាយ សីលេន ច វីរិយេន ច,**
**សមាធិនា ធម្មវិនិច្ឆយេន ច;**
**សម្បន្នវិជ្ជាចរណា បតិស្សតា,**
**ជហិស្សថ ទុក្ខមិទំ អនប្បកំ។**

សេះល្អ ដែលសារថីទូន្មានដោយរំពាត់ តែងតក់ស្លុត យ៉ាងណា, អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុត យ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជានិងចរណៈដ៏ បរិបូណ៌ មានស្មារតីតំកល់មាំ នឹងលះបង់នូវទុក្ខប្រមាណ ច្រើននេះបានមិនខានឡើយ ។

**១៤៥. ឧទកំ ហិ នយន្តិ នេត្តិកា,**
**ឧសុការា នមយន្តិ តេជនំ;**
**ទារុំ នមយន្តិ តច្ឆកា,**

**អត្តានំ ទមយន្តិ សុព្វតា។**

ធម្មតាពួកអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, ពួកអ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់), ពួកអ្នកចាំងឈើ តែងចាំងឈើ, ឯពួកអ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

**ទណ្ឌវគ្គោ ទសមោ និដ្ឋិតោ។**

ទណ្ឌវគ្គ ទី១០ ចប់ ។

## ១១. ជរាវគ្គោ

**១៤៦. កោ នុ ហាសោ កិមានន្ទោ, និច្ចំ បជ្ជលិតេ សតិ;**
**អន្ធការេន ឱនទ្ធា, បទីបំ ន គវេសថ។**

កាលបើលោកសន្និវាសត្រូវភ្លើង១១កង មានរាគៈជាដើម ឆេះទ្រលោមជានិច្ច(យ៉ាងនេះ) ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល, អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ (ម្ដេចឡើយ) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា ។

**១៤៧. បស្ស ចិត្តកតំ ពិម្ពំ, អរុកាយំ សមុស្សិតំ;**
**អាតុរំ ពហុសង្កប្បំ, យស្ស នត្ថិ ធុវំ ឋិតិ។**

អត្តភាពណាមិនទៀតទាត់ឋិតថេរ អ្នកចូរមើលអត្តភាពនោះ ដែលកម្មធ្វើឲ្យវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ ផ្សំផ្គុំគ្នាហើយ ជា

អត្តភាពរសាប់រសល់ជានិច្ច ដែលមហាជន ត្រិះរិះដោយច្រើន។

**១៤៨. បរិជិណ្ណមិទំ រូបំ, រោគនិទ្ធំ បភង្គុរំ*;**
**ភិជ្ជតិ បូតិសន្ទេហោ, មរណន្តំ ហិ ជីវិតំ។**

រូបនេះគ្រាំគ្រាណាស់ហើយ ជាសំណាក់នៃរោគ ជារបស់ពុកផុយ រាងកាយដែលស្មើដោយរបស់ស្អុយ (នេះ) តែងតែបែកធ្លាយទៅ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

**១៤៩. យានិមានិ អបត្ថានិ, អលាពូនេវ សារទេ;**
**កាបោតកានិ អដ្ឋីនិ, តានិ ទិស្វាន កា រតិ។**

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរដូចម្តេច (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយ(មានសភាពបែបនេះ)នោះ ។

**១៥០. អដ្ឋីនំ នគរំ កតំ, មំសលោហិតលេបនំ;**
**យត្ថ ជរា ច មច្ចុ ច, មានោ មក្ខោ ច ឱហិតោ។**

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណគេ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកម្មធ្វើហើយ ឲ្យជានគរនៃឆ្អឹងទាំងឡាយ ដែល

លាបបូកដោយសាច់និងឈាម ។

**១៥១. ជីរន្តិ វេ រាជរថា សុចិត្តា,**
**អថោ សរីរម្បិ ជរំ ឧបេតិ;**
**សតញ្ច ធម្មោ ន ជរំ ឧបេតិ,**
**សន្តោ ហវេ សព្ភិ បវេទយន្តិ។**

រាជរថទាំងឡាយដ៏វិចិត្រល្អ ចេះតែគ្រាំគ្រាទៅ សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាទៅដែរ ឯធម៌សប្បុរសទាំងឡាយ មិនចូលដល់នូវសេចក្តីគ្រាំគ្រាឡើយ, ពួកសប្បុរស តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

**១៥២. អប្បស្សុតាយំ បុរិសោ, ពលិពទ្ទោវ ជីរតិ;**
**មំសានិ តស្ស វឌ្ឍន្តិ, បញ្ញា តស្ស ន វឌ្ឍតិ។**

បុរសអ្នកមានការស្តាប់ចេះដឹងតិច តែងចាស់(ឥតអំពើ) ដូចគោបម្រើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វា មិនចម្រើនឡើងឡើយ ។

**១៥៣. អនេកជាតិសំសារំ, សន្ធាវិស្សំ អនិព្វិសំ;**
**គហការំ គវេសន្តោ, ទុក្ខា ជាតិ បុនប្បុនំ។**

**១៥៤. គហការក ទិដ្ឋោសិ, បុន គេហំ ន កាហសិ;**
**សព្វា តេ ផាសុកា ភគ្គា, គហកូដំ វិសង្ខតំ;**
**វិសង្ខារគតំ ចិត្តំ, តណ្ហានំ ខយមជ្ឈគា។**

តថាគត កាលមិនទាន់បានជួបប្រទះ (ពោធិញាណ វរល់តែ)ស្វះស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សំសារវដ្ដ មានជាតិដ៏ច្រើន ការកើត នាំមកនូវទុក្ខរឿយៗ ។ នែជាងផ្ទះ តថាគតឃើញអ្នក ឯងហើយ, អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀត មិនបាន ឡើយ, ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់ តថាគត កាច់បំបាក់ចោលហើយ, ដំបូលផ្ទះគឺអវិជ្ជា ក៏តថាគត កំចាត់ចោលហើយ, ចិត្តរបស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជា គ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

**១៥៥. អចរិត្វា ព្រហ្មចរិយំ, អលទ្ធា យោព្វនេ ធនំ;**
**ជិណ្ណកោញ្ចាវ ឈាយន្តិ, ខីណមច្ឆេវ បល្លលេ។**

ពួកជនពាល មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅវ័យក្មេង រមែងសញ្ជប់សញ្ជឹង ដូចសត្វ ក្រៀលចាស់ សំកុកនៅក្នុងភក់ដែលអស់ត្រីហើយ។

**១៥៦. អចរិត្វា ព្រហ្មចរិយំ, អលទ្ធា យោព្វនេ ធនំ;**
**សេន្តិ ចាបាតិខីណាវ, បុរាណានិ អនុត្ថុនំ។**

ពួកជនពាល មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅវ័យក្មេង រមែងដេកថ្ងូរសោកស្ដាយទ្រព្យ

ចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្លោះ ។

**ជរាវគ្គោ ឯកាទសមោ និដ្ឋិតោ។**

ជរាវគ្គ ១១ ចប់ ។

## ១២. អត្តវគ្គ

**១៥៧. អត្តានញ្ចេ បិយំ ជញ្ញា, រក្ខេយ្យ នំ សុរក្ខិតំ;**
**តិណ្ណំ អញ្ញតរំ យាមំ, បដិជគ្គេយ្យ បណ្ឌិតោ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួន ទុកក្នុងវ័យទាំងបី វ័យណាមួយ ។

**១៥៨. អត្តានមេវ បឋមំ, បដិរូបេ និវេសយេ;**
**អថញ្ញមនុសាសេយ្យ, ន កិលិស្សេយ្យ បណ្ឌិតោ។**

បណ្ឌិតគួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន សឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

**១៥៩. អត្តានំ ចេ តថា កយិរា, យថញ្ញមនុសាសតិ;**
**សុទន្តោ វត ទមេថ, អត្តា ហិ កិរ ទុទ្ទមោ។**

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឯងឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថាខ្លួនកម្រទូន្មានបានពេក

ណាស់ ។

**១៦០. អត្តា ហិ អត្តនោ នាថោ, កោ ហិ នាថោ បរោ សិយា;**
**អត្តនា ហិ សុទន្តេន, នាថំ លភតិ ទុល្លភំ។**

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃគប្បីជាទីពឹងដូចម្តេចបាន ព្រោះថាបុគ្គលអ្នកមានខ្លួនទូន្មានល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

**១៦១. អត្តនា ហិ កតំ បាបំ, អត្តជំ អត្តសម្ភវំ;**
**អភិមត្ថតិ ទុម្មេធំ, វជិរំ វស្មមយំ[4] មណឹ។**

បាបដែលកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីបុគ្គលឥតប្រាជ្ញា ដូចពេជ្រ (ដែលកើតអំពីថ្ម) កាត់កែវមណី ដែលកើតអំពីថ្មដូច្នោះឯង ។

**១៦២. យស្ស អច្ចន្តទុស្សីល្យំ, មាលុវា សាលមិវោត្ថតំ;**
**ករោតិ សោ តថត្តានំ, យថា នំ ឥច្ឆតី ទិសោ។**

ភាពជាអ្នកទ្រុស្តសីលហួសហេតុពេក គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លិដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើគេឲ្យវិនាសដូច្នោះ ។

---

4 កាត់បទថា វជិរំ ឥវ អស្មមយំ។ ខ. វជិរំវម្ហយំ ។

**១៦៣. សុករានិ អសាធូនិ, អត្តនោ អហិតានិ ច;**
**យំ វេ ហិតញ្ច សាធុញ្ច, តំ វេ បរមទុក្ករំ។**

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ គឺជនពាលធ្វើបានដោយងាយ, កម្មណា ជាប្រយោជន៍ផង ល្អផង កម្មនុ៎ះឯង គឺជនពាលធ្វើបានដោយលំបាកបំផុត ។

**១៦៤. យោ សាសនំ អរហតំ, អរិយានំ ធម្មជីវិនំ;**
**បដិក្កោសតិ ទុម្មេធោ, ទិដ្ឋឹ និស្សាយ បាបិកំ;**
**ផលានិ កណ្ដកស្សេវ, អត្តឃាតាយ ផល្លតិ។**

បុគ្គលណា មិនមានប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ទើបជំទាស់នឹងពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយទ្រង់ជាព្រះអរហន្តដ៏ប្រសើរ ទ្រង់មានជីវិតរស់នៅដោយធម៌, ការជំទាស់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។

**១៦៥. អត្តនាវ កតំ បាបំ, អត្តនា សំកិលិស្សតិ;**
**អត្តនា អកតំ បាបំ, អត្តនាវ វិសុជ្ឈតិ;**
**សុទ្ធី អសុទ្ធិ បច្ចត្តំ, នាញ្ញោ អញ្ញំ វិសោធយេ។**

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងដោយខ្លួនឯង, អ្នកមិនធ្វើខ្លួនឯង តែងបរិសុទ្ធស្អាតដោយខ្លួនឯង; សេចក្ដី

បរិសុទ្ធនិងមិនបរិសុទ្ធ មានចំពោះខ្លួន, អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានទេ ។

**១៦៦. អត្តទត្ថំ បរត្ថេន, ពហុនាបិ ន ហាបយេ;**
**អត្តទត្ថមភិញ្ញាយ, សទត្ថបសុតោ សិយា។**

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

**អត្តវគ្គោ ទ្វាទសមោ និដ្ឋិតោ។**

អត្តវគ្គទី ១២ ចប់ ។

## ១៣. លោកវគ្គ

**១៦៧. ហីនំ ធម្មំ ន សេវេយ្យ, បមាទេន ន សំវសេ;**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ, ន សិយា លោកវឌ្ឍនោ។**

បុគ្គលមិនគួរសេពធម៌ថោកទាប, មិនគួរនៅដោយសេចក្ដីប្រមាទ, មិនគួសេពមិច្ឆាទិដ្ឋិ, មិនគួរជាមនុស្សចង្អៀតលោកឡើយ ។

**១៦៨. ឧត្តិដ្ឋេ នប្បមជ្ជេយ្យ, ធម្មំ សុចរិតំ ចរេ;**
**ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។**

បញ្ញិតមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួលទេ, បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យសុចរិត, អ្នកប្រព្រឹត្តធម៌ រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងបរលោកផង។

**១៦៩. ធម្មំ ចរេ សុចរិតំ, ន នំ ទុច្ចរិតំ ចរេ;**
**ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។**

បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យសុចរិត, មិនគប្បីប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ, អ្នកប្រព្រឹត្តធម៌ រមែងដេកជាសុខក្នុងលោកនេះផង ក្នុងបរលោកផង។

**១៧០. យថា បុព្វុឡកំ បស្សេ, យថា បស្សេ មរីចិកំ;**
**ឯវំ លោកំ អវេក្ខន្តំ, មច្ចុរាជា ន បស្សតិ។**

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញថ្ងៃបណ្តើរកូនយ៉ាងណា មច្ចុរាជរកមើលមិនឃើញ នូវអ្នកដែលពិចារណាខន្ធលោកជាដើម ក៏យ៉ាងនោះៗដែរ ។

**១៧១. ឯថ បស្សថិមំ លោកំ, ចិត្តំ រាជរថូបមំ;**
**យត្ថ ពាលា វិសីទន្តិ, នត្ថិ សង្គោ វិជានតំ។**

អ្នកទាំងឡាយ ចូរមកមើលលោកគឺអត្តភាពនេះ ដែលដូចជារាជរថដ៏វិចិត្រ; ពួកជនពាល រមែងលិចលង់ក្នុងអត្តភាពឯណា, សេចក្តីជាប់ជំពាក់ក្នុងអត្តភាពនោះរមែង

មិនមាន ដល់ពួកជនជាបណ្ឌិតដែលដឹងច្បាស់ទេ។

**១៧២. យោ ច បុព្វេ បមជ្ជិត្វា, បច្ឆា សោ នប្បមជ្ជតិ;**
**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺ ដូចព្រះច័ន្ទរះផុតចាកពពក។

**១៧៣. យស្ស បាបំ កតំ កម្មំ, កុសលេន បិធីយតិ;**
**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសល គឺអរហត្តមគ្គបាន, បុគ្គលនោះ ឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺ ដូចព្រះច័ន្ទរះផុតចាកពពក។

**១៧៤. អន្ធភូតោ អយំ លោកោ, តនុកេត្ថ វិបស្សតិ;**
**សកុណោ ជាលមុត្តោវ, អប្បោ សគ្គាយ គច្ឆតិ។**

លោកិយមហាជននេះ ជាមនុស្សងងឹត, បណ្ដាជនទាំងនេះ ជនតិចគ្នាណាស់ ពិចារណាឃើញច្បាស់ (ដោយអំនាចនៃត្រៃលក្ខណ៍) ជនតិចគ្នាតែងទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចផុត អំពីសំណាញ់ ។

**១៧៥. ហំសាទិច្ចបថេ យន្តិ, អាកាសេ យន្តិ ឥទ្ធិយា;**
**នីយន្តិ ធីរា លោកម្ហា, ជេត្វា មារំ សវាហិនិំ ។**

ពួកហង្សតែងហើរទៅ ក្នុងគន្លងផ្លូវព្រះអាទិត្យ, ពួកអ្នកមានឫទ្ធិតែងហោះទៅ ក្នុងអាកាសដោយឫទ្ធិ, ពួកអ្នកប្រាជ្ញផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈគឺតណ្ហាបានហើយ តែងចេញចាកលោក(គឺវដ្តៈនេះ)បាន ។

**១៧៦. ឯកំ ធម្មំ អតីតស្ស, មុសាវាទិស្ស ជន្តុនោ;**
**វិតិណ្ណបរលោកស្ស, នត្ថិ បាបំ អការិយំ។**

បុគ្គលប្រព្រឹត្តកន្លង (នូវពាក្យសច្ចៈ) ដែលជាធម៌ឯកនិយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថាមិនធ្វើអំពើបាប មិនមែនឡើយ ។

**១៧៧. ន វេ កទរិយា ទេវលោកំ វជន្តិ,**
**ពាលា ហវេ នប្បសំសន្តិ ទានំ;**
**ធីរោ ច ទានំ អនុមោទមានោ,**
**តេនេវ សោ ហោតិ សុខី បរត្ថ។**

ពួកបុគ្គលកំណាញ់ស្វិត មិនបានទៅកាន់ទេវលោកទេ, ពួកជនពាល មិនសរសើរទានឡើយ; ចំនែកអ្នកប្រាជ្ញកាលអនុមោទនាទាន(របស់ជនដទៃ) លោកជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ ព្រោះហេតុតែបុណ្យគឺ

ការអនុមោទនាទាននោះឯង ។

**១៧៨. បឋព្យា ឯករជ្ជេន, សគ្គស្ស គមនេន វា;**
**សព្វលោកាធិបច្ចេន, សោតាបត្តិផលំ វរំ។**

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

**លោកវគ្គោ តេរសមោ និដ្ឋិតា។**

លោកវគ្គ ទី១៣ ចប់ ។

## ១៤. ពុទ្ធវគ្គ

**១៧៩. យស្ស ជិតំ នាវជីយតិ,**
**ជិតមស្ស នោយាតិ កោចិ លោកេ;**
**តំ ពុទ្ធំ អនន្តគោចរំ,**
**អបទំ កេន បទេន នេស្សថ។**

ជ័យជំនះ របស់ព្រះពុទ្ធអង្គឯណា មិនត្រឡប់វិញ, កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះរបស់ព្រះពុទ្ធអង្គនោះ; នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ទ្រង់មានគោចររកទីបំផុតគ្មាន មិនមានកិលេស ដោយកិលេសម្តេចកើត។

**១៨០. យស្ស ជាលិនី វិសត្តិកា, តណ្ហា នត្ថិ កុហិញ្ចិ នេតវេ;**
**តំ ពុទ្ធំ អនន្តគោចរំ, អបទំ កេន បទេន នេស្សថ។**

តណ្ហា ដែលមានបណ្ដាញផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គឯណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ; នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ទ្រង់មានគោចររកទីបំផុតគ្មាន មិនមានកិលេស ដោយកិលេសម្ដេចកើត។

**១៨១. យេ ឈានបសុតា ធីរា, នេក្ខម្មូបសមេ រតា;**
**ទេវាបិ តេសំ បិហយន្តិ, សម្ពុទ្ធានំ សតីមតំ។**

ព្រះសម្ពុទ្ធទាំងឡាយឯណា ជាអ្នកប្រាជ្ញខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងព្រះនិព្វាន ជាទីស្ងប់រំងាប់កិលេស សូម្បីពួកទេវតានិងមនុស្ស ក៏ស្រលាញ់ចំពោះព្រះសម្ពុទ្ធទាំងឡាយនោះ ទ្រង់មានស្មារតី ។

**១៨២. កិច្ឆោ មនុស្សបដិលាភោ, កិច្ឆំ មច្ចាន ជីវិតំ;**
**កិច្ឆំ សទ្ធម្មស្សវនំ, កិច្ឆោ ពុទ្ធានមុប្បាទោ។**

ការត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក, ការរស់របស់សត្វទាំងឡាយ ជាការលំបាក, ការស្ដាប់នូវព្រះសទ្ធម្ម ជាការលំបាក, ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាការលំបាក។

**១៨៣. សព្វបាបស្ស អករណំ, កុសលស្សូបសម្បទា;**
**សចិត្តបរិយោទបនំ, ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនធ្វើនូវបាបទាំងពួង, កិរិយាបំពេញកុសល, កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់, ទាំងនេះជាពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធទាំងឡាយ ។

**១៨៤. ខន្តី បរមំ តបោ តិតិក្ខា,**
**និព្វានំ បរមំ វទន្តិ ពុទ្ធា;**
**ន ហិ បព្វជិតោ បរូបឃាតី,**
**ន[5] សមណោ ហោតិ បរំ វិហេឋយន្តោ។**

ខន្តីគឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម, ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម, អ្នកបួសដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិតទេ, អ្នកបួសដែលបៀតបៀនសត្វដទៃ មិនឈ្មោះថាសមណៈឡើយ ។

**១៨៥. អនូបវាទោ អនូបឃាតោ, បាតិមោក្ខេ ច សំវរោ;**
**មត្តញ្ញុតា ច ភត្តស្មិំ, បន្តញ្ច សយនាសនំ;**
**អធិចិត្តេ ច អាយោគោ, ឯតំ ពុទ្ធាន សាសនំ។**

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួម

---

5 ន-ស័ព្ទ ក្នុងទីដទៃ មិនឃើញមាន, ក្នុងនេះកាន់យកច្បាប់ឆដ្ឋសង្គាយនា។

ក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**១៨៦. ន កហាបណវស្សេន, តិត្តិ កាមេសុ វិជ្ជតិ;**
**អប្បស្សាទា ទុខា កាមា, ឥតិ វិញ្ញាយ បណ្ឌិតោ។**
**១៨៧. អបិ ទិព្វេសុ កាមេសុ, រតិំ សោ នាធិគច្ឆតិ;**
**តណ្ហក្ខយរតោ ហោតិ, សម្មាសម្ពុទ្ធសាវកោ។**

ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះភ្លៀងគឺរតនៈ៧ប្រការទេ, កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់យ៉ាងនេះហើយ ទើបលោកមិនបាននូវសេចក្តីត្រេកអរ ក្នុងកាមទាំងឡាយ សូម្បីជាទិព្វ ជាអ្នកត្រេកអរតែក្នុងធម៌ ជាគ្រឿងអស់ទៅនៃតណ្ហា និងជាសាវករបស់ព្រះសម្មាសម្ពុទ្ធមែន។

**១៨៨. ពហុំ វេ សរណំ យន្តិ, បព្វតានិ វនានិ ច;**
**អារាមរុក្ខចេត្យានិ, មនុស្សា ភយតជ្ជិតា។**
**១៨៩. នេតំ ខោ សរណំ ខេមំ, នេតំ សរណមុត្តមំ;**
**នេតំ សរណមាគម្ម, សព្វទុក្ខា បមុច្ចតិ។**

មនុស្សទាំងឡាយមានចំនួនច្រើន ត្រូវភ័យគំរាមហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនិង

ដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង; ទីពឹងនុ៎ះឯង មិនមែនជាទីពឹងដ៏ក្សេម, ទីពឹងនុ៎ះ មិនមែនជាទីពឹងដ៏ឧត្តមទេ; (ព្រោះថា) បុគ្គលអាស្រ័យនូវទីពឹងនុ៎ះហើយ មិនរួចស្រឡះ ចាកវដ្តទុក្ខទាំងពួងឡើយ ។

**១៩០. យោ ច ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ;**
**ចត្តារិ អរិយសច្ចានិ, សម្មប្បញ្ញាយ បស្សតិ។**
**១៩១. ទុក្ខំ ទុក្ខសមុប្បាទំ, ទុក្ខស្ស ច អតិក្កមំ;**
**អរិយំ ចដ្ឋង្គិកំ មគ្គំ, ទុក្ខូបសមគាមិនំ។**
**១៩២. ឯតំ ខោ សរណំ ខេមំ, ឯតំ សរណមុត្តមំ;**
**ឯតំ សរណមាគម្ម, សព្វទុក្ខា បមុច្ចតិ។**

លុះតែបុគ្គលណាយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរលឹក ឃើញច្បាស់នូវអរិយសច្ចទាំង៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច ជាទីកន្លងបង់នូវទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំនើរទៅកាន់ព្រះនិព្វាន ដែលជាទីរំងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ; ទីពឹងនេះឯង ទើបជាទីពឹងដ៏ក្សេម, ទីពឹងនេះឯង ទើបជាទីពឹងដ៏ឧត្តម; (ព្រោះថា) បុគ្គលអាស្រ័យនូវទីពឹងនេះហើយ ទើបរួចស្រឡះចាកវដ្តទុក្ខទាំងពួងបាន ។

**១៩៣. ទុល្លភោ បុរិសាជញ្ញោ, ន សោ សព្វត្ថ ជាយតិ;**
**យត្ថ សោ ជាយតិ ធីរោ, តំ កុលំ សុខមេធតិ។**

ព្រះសម្មាសម្ពុទ្ធជាបុរសអាជានេយ្យ រកបានដោយកម្រ, ព្រះអង្គមិនចេះតែកើតក្នុងទីទាំងពួងឡើយ; ព្រះអង្គជាអ្នកប្រាជ្ញ កើតក្នុងត្រកូលណា, ត្រកូលនោះ តែងដល់នូវសេចក្តីសុខ ។

**១៩៤. សុខោ ពុទ្ធានមុប្បាទោ, សុខា សទ្ធម្មទេសនា;**
**សុខា សង្ឃស្ស សាមគ្គី, សមគ្គានំ តបោ សុខោ។**

ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ, ការសម្តែងព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ, សេចក្តីព្រមព្រៀងគ្នា របស់សង្ឃឬពួកក្រុម នាំមកនូវសេចក្តីសុខ, សេចក្តីព្យាយាម របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ។

**១៩៥. បូជារហេ បូជយតោ, ពុទ្ធេ យទិ វ សាវកេ;**
**បបញ្ចសមតិក្កន្តេ, តិណ្ណសោកបរិទ្ទវេ។**

**១៩៦. តេ តាទិសេ បូជយតោ, និព្វុតេ អកុតោភយេ;**
**ន សក្កា បុញ្ញំ សង្ខាតុំ, ឥមេត្តមបិ កេនចិ។**

កាលបុគ្គលបូជាចំពោះបូជារហបុគ្គល គឺព្រះពុទ្ធ ឬពុទ្ធ-សាវក ដែលកន្លងផុតបបញ្ចធម៌ ដែលឆ្លងផុតសេចក្តី

សោកនិងសេចក្តីខ្សឹកខ្សួល ឬកាលបូជាចំពោះបូជារហ-
បុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ រលត់រាគា-
ទិក្កិលេសហើយ មិនមានភ័យអំពីទីណា បុគ្គលណាមួយ
មិនអាចរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណោះ
បានឡើយ ។

**ពុទ្ធវគ្គោ ចុទ្ទសមោ និដ្ឋិតោ។**

ពុទ្ធវគ្គទី ១៤ ចប់ ។

## ១៥. សុខវគ្គ

**១៩៧. សុសុខំ វត ជីវាម, វេរិនេសុ អវេរិនោ;**
**វេរិនេសុ មនុស្សេសុ, វិហរាម អវេរិនោ។**

យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានពៀរ កាលពួកមនុស្សអ្នកមានពៀរ យើងជាអ្នកមិនមានពៀរ ។

**១៩៨. សុសុខំ វត ជីវាម, អាតុរេសុ អនាតុរា;**
**អាតុរេសុ មនុស្សេសុ, វិហរាម អនាតុរា។**

យើង ជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សអ្នកមានសេចក្តីក្តៅ

ក្រហាយ យើងជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ ។

**១៩៩. សុសុខំ វត ជីវាម, ឧស្សុកេសុ អនុស្សុកា;**
**ឧស្សុកេសុ មនស្សេសុ, វិហរាម អនុស្សុកា។**

យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ(ក្នុងការស្វែងរក) រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានសេចក្ដីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ។

**២០០. សុសុខំ វត ជីវាម, យេសំ នោ នត្ថិ កិញ្ចនំ;**
**បីតិភក្ខា ភវិស្សាម, ទេវា អាភស្សរា យថា។**

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

**២០១. ជយំ វេរំ បសវតិ, ទុក្ខំ សេតិ បរាជិតោ;**
**ឧបសន្តោ សុខំ សេតិ, ហិត្វា ជយបរាជយំ។**

បុគ្គលអ្នកឈ្នះ ប្រទះនូវពៀរ, បុគ្គលអ្នកចាញ់តែងដេកជាទុក្ខ; ចំណែកបុគ្គលអ្នកស្ងប់រំងាប់ លះបង់ការឈ្នះនិងការចាញ់ចេញហើយ ទើបដេកជាសុខ។

**២០២. នត្ថិ រាគសមោ អគ្គិ, នត្ថិ ទោសសមោ កលិ;**
**នត្ថិ ខន្ធសមា ទុក្ខា, នត្ថិ សន្តិបរំ សុខំ។**

ភ្លើងស្មើដោយរាគៈ មិនមាន, ទោសកំហុសស្មើដោយទោសៈ មិនមាន, ទុក្ខទាំងឡាយស្មើដោយខន្ធមិនមាន,

សុខក្រៅពីសេចក្ដីស្ងប់ មិនមាន ។

**២០៣. ជិឃច្ឆា បរមា រោគា, សង្ខារា បរមា ទុខា;**
**ឯតំ ញត្វា យថាភូតំ, និព្វានំ បរមំ សុខំ។**

សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង, សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង, (អ្នកប្រាជ្ញ)ដឹងច្បាស់សេចក្ដីនុ៎ះ តាមពិតហើយ (រមែងធ្វើឲ្យច្បាស់) នូវព្រះនិព្វាន ដែលជាសុខយ៉ាងក្រៃលែង ។

**២០៤. អារោគ្យបរមា លាភា, សន្តុដ្ឋិបរមំ ធនំ;**
**វិស្សាសបរមា ញាតិ, និព្វានំ បរមំ សុខំ។**

លាភ មានការមិនមានរោគជាយ៉ាងក្រៃលែង, ទ្រព្យមានសេចក្ដីសន្ដោសជាយ៉ាងក្រៃលែង, ញាតិ មានសេចក្ដីស្និទ្ធស្នាលជាយ៉ាងក្រៃលែង, ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

**២០៥. បវិវេករសំ បិត្វា, រសំ ឧបសមស្ស ច;**
**និទ្ទរោ ហោតិ និប្បាបោ, ធម្មបីតិរសំ បិវំ។**

ភិក្ខុផឹកនូវរសវិវេកផង នូវរសព្រះនិព្វាន ជាទីស្ងប់រំងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ មិនមានសេចក្ដីសៅហ្មង។

**២០៦. សាហុ ទស្សនមរិយានំ, សន្និវាសោ សទា សុខោ;**
**អទស្សនេន ពាលានំ, និច្ចមេវ សុខី សិយា។**
**២០៧. ពាលសង្គតចារី ហិ, ទីឃមទ្ធាន សោចតិ;**
**ទុក្ខោ ពាលេហិ សំវាសោ, អមិត្តេនេវ សព្វទា;**
**ធីរោ ច សុខសំវាសោ, ញាតីនំវ សមាគមោ។**

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ, ការរួមនៅជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្ដីសុខ សព្វកាល, បុគ្គលគប្បីមានសេចក្ដីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ។ ព្រោះថា បុគ្គលអ្នកប្រព្រឹត្តត្រាច់ជាមួយនឹងជនពាល រមែងសោកស្ដាយ អស់កាលយូរអង្វែង, ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ សព្វកាល ដូចជាការនៅរួមជាមួយនឹងសត្រូវ, ចំនែកអ្នកប្រាជ្ញ មានការនៅរួមជាមួយគ្នាជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ។

**២០៨. តស្មា ហិ –**

**ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច,**
**ធោរយ្ហសីលំ វតវន្តមរិយំ;**
**តំ តាទិសំ សប្បុរិសំ សុមេធំ,**

**ភជេថ នក្ខត្តបថំវ ចន្ទិមា។**

ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះនោះ ឲ្យដូចព្រះចន្ទគប់នូវអាកាស ពោលគឺផ្លូវនក្ខត្តឫក្ស (ដែលប្រាសចាកមន្ទិល)។

**សុខវគ្គោ បណ្ណរសមោ និដ្ឋិតោ។**

សុខវគ្គ ទី១៥ ចប់ ។

## ១៦. បិយវគ្គ

**២០៩. អយោគេ យុញ្ជមត្តានំ, យោគស្មិញ្ច អយោជយំ;**
**អត្ថំ ហិត្វា បិយគ្គាហី, បិហេតត្តានុយោគិនំ។**
**២១០. មា បិយេហិ សមាគញ្ឆិ, អប្បិយេហិ កុទាចនំ;**
**បិយានំ អទស្សនំ ទុក្ខំ, អប្បិយានញ្ច ទស្សនំ។**

បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប និងមិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់បុគ្គលអ្នកដែលប្រកបតាមខ្លួន; កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិន

ស្រឡាញ់ ក្នុងកាលណាៗ ឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វនិងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វនិងសង្ខារដែលមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវសេចក្តីទុក្ខ ។

**២១១. តស្មា បិយំ ន កយិរាថ, បិយាបាយោ ហិ បាបកោ;**
**គន្ថា តេសំ ន វិជ្ជន្តិ, យេសំ នត្ថិ បិយាប្បិយំ។**

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វនិងសង្ខារឲ្យជាទីស្រឡាញ់ទេ, ព្រោះថាការព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ ជាសភាពអាក្រក់; ការស្រឡាញ់និងការស្អប់ មិនមានដល់ពួកជនណា កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

**២១២. បិយតោ ជាយតី សោកោ, បិយតោ ជាយតី ភយំ;**
**បិយតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះ ចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

**២១៣. បេមតោ ជាយតី សោកោ, បេមតោ ជាយតី ភយំ;**
**បេមតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោក កើតអំពីភាពនៃសេចក្តីស្រឡាញ់ ភ័យកើតអំពីភាពនៃសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកភាពនៃសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

**២១៤. រតិយា ជាយតី សោកោ, រតិយា ជាយតី ភយំ;**
**រតិយា វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

**២១៥. កាមតោ ជាយតី សោកោ, កាមតោ ជាយតី ភយំ;**
**កាមតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះ ចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

**២១៦. តណ្ហាយ ជាយតី សោកោ, តណ្ហាយ ជាយតី ភយំ;**
**តណ្ហាយ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាល

បើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

**២១៧. សីលទស្សនសម្បន្នំ, ធម្មដ្ឋំ សច្ចវេទិនំ;**
**អត្តនោ កម្ម កុព្វានំ, តំ ជនោ កុរុតេ បិយំ។**

ជន តែងធ្វើបុគ្គលដែលបរិបូណ៌ដោយសីល និងការឃើញត្រូវ ឋិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះឲ្យជាទីស្រឡាញ់ ។

**២១៨. ឆន្ទជាតោ អនក្ខាតេ, មនសា ច ផុដោ សិយា;**
**កាមេសុ ច អប្បដិពទ្ធចិត្តោ, ឧទ្ធំសោតោតិ វុច្ចតិ។**

ភិក្ខុអ្នកមានសេចក្តីពេញចិត្ត ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបាន គប្បីជាអ្នកបំពេញដោយមគ្គ-ចិត្តនិងផលចិត្ត(ខាងក្រោម)ផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមទាំងឡាយផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅក្នុងខាងលើ ។

**២១៩. ចិរប្បវាសិំ បុរិសំ, ទូរតោ សោត្ថិមាគតំ;**
**ញាតិមិត្តា សុហជ្ជា ច, អភិនន្ទន្តិ អាគតំ។**

**២២០. តថេវ កតបុញ្ញម្បិ, អស្មា លោកា បរំ គតំ;**
**បុញ្ញានិ បដិគណ្ហន្តិ, បិយំ ញាតីវ អាគតំ។**

ពួកញាតិក្តី មិត្រក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរស

ដែលនៅឃ្លាតគ្នាអស់កាលយូរ មកអំពីចំងាយ ដោយសិរីសួស្តីមកដល់ហើយ ដូចម្តេចមិញ, បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយទទួលបុរសជាទីស្រឡាញ់ ទើបមកដល់ដូច្នោះឯង ។

**បិយវគ្គោ សោឡសមោ និដ្ឋិតោ។**

បិយវគ្គ ទី១៦ ចប់ ។

## ១៧. កោធវគ្គ

**២២១. កោធំ ជហេ វិប្បជហេយ្យ មានំ,**
**សំយោជនំ សព្វមតិក្កមេយ្យ;**
**តំ នាមរូបស្មិមសជ្ជមានំ,**
**អកិញ្ចនំ នានុបតន្តិ ទុក្ខា។**

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ, គួរលះបង់មានះចេញ, គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ, ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គលដែលមិនជំពាក់ ក្នុងនាមនិងរូបមិនមានកិលេសគ្រឿងកង្វល់នោះឡើយ។

**២២២. យោ វេ ឧប្បតិតំ កោធំ, រថំ ភន្តំវ ធារយេ;**
**តមហំ សារថឹ ព្រូមិ, រស្មិគ្គាហោ ឥតរោ ជនោ។**

បុគ្គលណាឃាត់សេចក្ដីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន, តថាគតហៅ បុគ្គលនោះថាជាសារថី, ជនក្រៅពីនេះគ្រាន់តែជាអ្នក កាន់ខ្សែបរ (មិនមែនសារថីឡើយ) ។

**២២៣. អក្កោធេន ជិនេ កោធំ, អសាធុំ សាធុនា ជិនេ;**
**ជិនេ កទរិយំ ទានេន, សច្ចេនាលិកវាទិនំ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ, គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស, គប្បីផ្ចាញ់ មនុស្សកំណាញ់ដោយការឲ្យ, គប្បីផ្ចាញ់មនុស្សនិយាយ ពាក្យមិនពិតដោយពាក្យពិត។

**២២៤. សច្ចំ ភណេ ន កុជ្ឈេយ្យ, ទជ្ជា អប្បស្មិ[6] យាចិតោ;**
**ឯតេហិ តីហិ ឋានេហិ, គច្ឆេ ទេវាន សន្តិកេ។**

បុគ្គលគួរពោលពាក្យពិត១ មិនគួរក្រោធ១ កាលគេសុំ វត្ថុសូម្បីមានតិចក៏គួរឲ្យ(តាមតិច)១ (ព្រោះថា) បុគ្គល គប្បីទៅកើត ក្នុងសំណាក់ទេវតាទាំងឡាយបាន ដោយ (បណ្ដា)ហេតុទាំង៣នោះ (សូម្បីហេតុតែមួយ)។

**២២៥. អហឹសកា យេ មុនយោ, និច្ចំ កាយេន សំវុតា;**
**តេ យន្តិ អច្ចុតំ ឋានំ, យត្ថ គន្ត្វា ន សោចរេ។**

6 ខ. អប្បស្មិ។

ជនទាំងឡាយណាជាអ្នកប្រាជ្ញមិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច, ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ។

**២២៦. សទា ជាគរមានានំ, អហោរត្តានុសិក្ខិនំ;**
**និព្វានំ អធិមុត្តានំ, អត្ថំ គច្ឆន្តិ អាសវា។**

អាសវៈទាំងឡាយ របស់បុគ្គលអ្នកភ្ញាក់រលឹកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ។

**២២៧. បោរាណមេតំ អតុល, នេតំ អជ្ជតនាមិវ;**
**និន្ទន្តិ តុណ្ហិមាសីនំ, និន្ទន្តិ ពហុភាណិនំ;**
**មិតភាណិម្បិ និន្ទន្តិ, នត្ថិ លោកេ អនិន្ទិតោ។**

ម្នាលអតុលៈ ការតិះដៀលនិងការសរសើរនេះ ជារបស់បុរាណ, លោកធម៌នេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយតែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន, និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន, និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន, (អ្នកណាៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ។

**២២៨. ន ចាហុ ន ច ភវិស្សតិ, ន ចេតរហិ វិជ្ជតិ;**
**ឯកន្តំ និន្ទិតោ បោសោ, ឯកន្តំ វា បសំសិតោ។**

បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយតែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ។

**២២៩. យំ ចេ វិញ្ញូ បសំសន្តិ, អនុវិច្ច សុវេ សុវេ;**
**អច្ឆិន្នវុត្តិំ មេធាវិំ, បញ្ញាសីលសមាហិតំ។**

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ៗថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញានិងសីល។

**២៣០. នេក្ខំ ជម្ពោនទស្សេវ, កោ តំ និន្ទិតុមរហតិ;**
**ទេវាបិ នំ បសំសន្តិ, ព្រហ្មុនាបិ បសំសិតោ។**

អ្នកណា គួរដើម្បីនឹងនិន្ទាបុគ្គល ដែលដូចជាឆ្នោរនៃមាសជម្ពោនទនោះបាន សូម្បីទេវតានិងមនុស្សទាំងឡាយក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរដែរ។

**២៣១. កាយប្បកោបំ រក្ខេយ្យ, កាយេន សំវុតោ សិយា;**
**កាយទុច្ចរិតំ ហិត្វា, កាយេន សុចរិតំ ចរេ។**

បុគ្គលគប្បីរក្សានូវការកម្រើកកាយ, គប្បីសង្រួមកាយ, គប្បីលះបង់កាយទុច្ចរិត, គប្បីប្រព្រឹត្តកាយសុចរិត។

**២៣២. វចីបកោបំ រក្ខេយ្យ, វាចាយ សំវុតោ សិយា;**
**វចីទុច្ចរិតំ ហិត្វា, វាចាយ សុចរិតំ ចរេ។**

បុគ្គលគប្បីរក្សានូវការកម្រើកវាចា, គប្បីសង្រួមវាចា, គប្បីលះបង់វចីទុច្ចរិត, គប្បីប្រព្រឹត្តវចីសុចរិត។

**២៣៣. មនោបកោបំ រក្ខេយ្យ, មនសា សំវុតោ សិយា;**
**មនោទុច្ចរិតំ ហិត្វា, មនសា សុចរិតំ ចរេ។**

បុគ្គលគប្បីរក្សានូវការកម្រើកចិត្ត, គប្បីសង្រួមចិត្ត, គប្បីលះបង់មនោទុច្ចរិត, គប្បីប្រព្រឹត្តមនោសុចរិត។

**២៣៤. កាយេន សំវុតា ធីរា, អថោ វាចាយ សំវុតា;**
**មនសា សំវុតា ធីរា, តេ វេ សុបរិសំវុតា។**

អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ, លោកអ្នកប្រាជ្ញទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ។

**កោធវគ្គោ សត្តរសមោ និដ្ឋិតោ។**

កោធវគ្គ ទី១៧ ចប់ ។

## ១៨. មលវគ្គ

**២៣៥. បណ្ឌុបលាសោវ ទានិសិ,**
**យមបុរិសាបិ ច តេ ឧបដ្ឋិតា;**
**ឧយ្យោគមុខេ ច តិដ្ឋសិ,**
**បាថេយ្យម្បិ ច តេ ន វិជ្ជតិ។**

ខ្លួនអ្នកក្នុងឥឡូវនេះ ជាបុគ្គលប្រៀបដូចស្លឹកឈើទុំមានពណ៌លឿង, បុរស(ជាបំរើ)នៃយមរាជ (គឺមរណៈ) សោត ក៏ប្រាកដដល់អ្នកហើយ, អ្នកជាបុគ្គលឋិតនៅក្នុងប្រធាននៃសេចក្ដីសាបសូន្យ, ស្បៀងគឺកុសលរបស់អ្នកសោត ក៏គ្មាន។

**២៣៦. សោ ករោហិ ទីបមត្តនោ,**
**ខិប្បំ វាយម បណ្ឌិតោ ភវ;**
**និទ្ធន្តមលោ អនង្គណោ,**
**ទិព្វំ អរិយភូមិមេហិសិ ។**

អ្នកឯងចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនចុះ, ចូរអ្នកតាំងព្យាយាមរួតរះ ចូរជាអ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ), អ្នក (កាលធ្វើយ៉ាង់នេះ) នឹងជាបុគ្គលមានមន្ទិល (គឺរាគៈជាដើម) ខ្ជាត់ចេញ មិនមានទីទួលគឺកិលេស ហើយនឹងដល់នូវអរិយភូមិដ៏ជាទិព្វ។

**២៣៧. ឧបនីតវយោ ច ទានិសិ,**
**សម្បយាតោសិ យមស្ស សន្តិកេ;**
**វាសោ តេ នត្ថិ អន្តរា,**
**បាថេយ្យម្បិ ច តេ ន វិជ្ជតិ។**

ឥឡូវនេះ ខ្លួនអ្នកមានវ័យកន្លងអស់ហើយ ជាអ្នករៀបដំនើរទៅកាន់សម្នាក់យមរាជ, មួយទៀត ទីសំចតក្នុងចន្លោះមិនមានដល់អ្នកទេ, សូម្បីស្បៀងក៏មិនមានដល់អ្នក។

**២៣៨. សោ ករោហិ ទីបមត្តនោ, ខិប្បំ វាយម បណ្ឌិតោ ភវ;**
**និទ្ធន្តមលោ អនង្គណោ, ន បុន ជាតិជរំ ឧបេហិសិ។**

អ្នកឯងចូរធ្វើនូវទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ, បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ។

**២៣៩. អនុបុព្វេន មេធាវី, ថោកំ ថោកំ ខណេ ខណេ;**
**កម្មារោ រជតស្សេវ, និទ្ធមេ មលមត្តនោ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់នូវមន្ទិលរបស់ខ្លួន បន្តិចម្តងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះ

ស្នឹងឬច្រែះរបស់មាសដូច្នោះ។
**២៤០. អយសាវ មលំ សមុដ្ឋិតំ, តតុដ្ឋាយ[7] តមេវ ខាទតិ;**
**ឯវំ អតិធោនចារិនំ, សានិ កម្មានិ នយន្តិ ទុគ្គតឹ។**
ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ, កម្មទាំងឡាយរបស់ខ្លួនតែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញា ជាគ្រឿងជម្រះចិត្តឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះដែរ។
**២៤១. អសជ្ឈាយមលា មន្តា, អនុដ្ឋានមលា ឃរា;**
**មលំ វណ្ណស្ស កោសជ្ជំ, បមាទោ រក្ខតោ មលំ។**
មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល, ផ្ទះទាំងឡាយមានការមិនថែទាំជាមន្ទិល, សេចក្តីខ្ជិលជាមន្ទិលនៃពណ៌សម្បុរ, សេចក្តីប្រមាទជាមន្ទិលនៃបុគ្គលរក្សា។
**២៤២. មលិត្ថិយា ទុច្ចរិតំ, មច្ឆេរំ ទទតោ មលំ;**
**មលា វេ បាបកា ធម្មា, អស្មិំ លោកេ បរម្ហិ ច។**
ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី, សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ, ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះនិងលោកខាងមុខ។
**២៤៣. តតោ មលា មលតរំ, អវិជ្ជា បរមំ មលំ;**

---

7 មកពី តតោ ឧដ្ឋាយ។ ខ.ស្យា.សី. តទុដ្ឋាយ ។

**ឯតំ មលំ បហន្ត្វាន, និម្មលា ហោថ ភិក្ខវោ។**

ធម្មជាតជាមន្ទិលដ៏លើសលប់ ជាងមន្ទិលទាំងឡាយ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរជាអ្នកមិនមានមន្ទិល។

**២៤៤. សុជីវំ អហិរិកេន, កាកសូរេន ធំសិនា;**

**បក្ខន្ទិនា បគព្ភេន, សំកិលិដ្ឋេន ជីវិតំ។**

បុគ្គលអ្នកមិនមានសេចក្ដីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កម្ចាត់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃ្នើសឃ្នង ជាមនុស្សសៅហ្មង រស់នៅដោយងាយ។

**២៤៥. ហិរីមតា ច ទុជ្ជីវំ, និច្ចំ សុចិគវេសិនា;**

**អលីនេនាប្បគព្ភេន, សុទ្ធាជីវេន បស្សតា។**

ចំនែកបុគ្គលអ្នកមានសេចក្ដីអៀនខ្មាស ស្វែងរកអំពើល្អជានិច្ច មិនទ្បេះទ្បោះ មិនឃ្នើសឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក។

**២៤៦. យោ បាណមតិបាតេតិ, មុសាវាទញ្ច ភាសតិ;**

**លោកេ អទិន្នមាទិយតិ, បរទារញ្ច គច្ឆតិ។**

**២៤៧. សុរាមេរយបានញ្ច, យោ នរោ អនុយុញ្ជតិ;**

**ឥធេវមេសោ លោកស្មឹ, មូលំ ខណតិ អត្តនោ។**

ជនណាៗ សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ផឹកទឹកសុរានិងមេរ័យផង, ជននោះៗឯង ឈ្មោះថាគាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត។

**២៤៨. ឯវំ ភោ បុរិស ជានាហិ, បាបធម្មា អសញ្ញតា;**
**មា តំ លោភោ អធម្មោ ច, ចិរំ ទុក្ខាយ រន្ធយុំ។**

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះ ថាជនទាំងឡាយ មានធម៌ដ៏លាមក មិនជាអ្នកសង្រួមយ៉ាងនេះ, លោភៈនិងទោសៈ(អធម៌) ចូរកុំបៀតបៀនអ្នកឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ។

**២៤៩. ទទាតិ វេ យថាសទ្ធំ, យថាបសាទនំ ជនោ;**
**តត្ថ យោ មង្កុតោ ហោតិ[8], បរេសំ បានភោជនេ;**
**ន សោ ទិវា វា រត្តិំ វា, សមាធឹ អធិគច្ឆតិ។**

ជនរមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា, បុគ្គលណាជាអ្នកអៀនខ្មាស ចំពោះទឹកនិងភោជនទាំងឡាយ របស់អ្នកទាំងឡាយដទៃ, ជននោះ រមែងមិនបានសមាធិចិត្ត

---

8 ឆ.បា. តត្ថ យោ មង្កុ ភវតិ។ ឆ.អដ្ឋ. តត្ថ យោ ច មង្កុ ហោតិ ។

ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ។

**២៥០. យស្ស ចេតំ សមុច្ឆិន្នំ, មូលឃច្ចំ សមូហតំ;**
**ស វេ ទិវា វា រត្តឹ វា, សមាធឹ អធិគច្ឆតិ។**

លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណាបានផ្តាច់ផ្តិល ដកឡើងធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្តក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់។

**២៥១. នត្ថិ រាគសមោ អគ្គិ, នត្ថិ ទោសសមោ គហោ;**
**នត្ថិ មោហសមំ ជាលំ, នត្ថិ តណ្ហាសមា នទី។**

ភ្លើងស្មើដោយរាគៈមិនមាន, ការចាប់ស្មើដោយទោសៈ មិនមាន, បណ្តាញស្មើដោយមោហៈមិនមាន, ស្ទឹងស្មើ ដោយតណ្ហាមិនមាន។

**២៥២. សុទស្សំ វជ្ជមញ្ញេសំ, អត្តនោ បន ទុទ្ទសំ;**
**បរេសំ ហិ សោ វជ្ជានិ, ឱបុនាតិ យថា ភុសំ;**
**អត្តនោ បន ឆាទេតិ, កលឹវ កិតវា សឋោ។**

ទោស របស់ជនដទៃឃើញបានដោយងាយ, ចំនែក ទោស របស់ខ្លួនឃើញបានដោយលំបាក, ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ, តែថារមែងបិទបាំងទោស របស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាពដោយវត្ថុ

សំរាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ។

**២៥៣. បរវជ្ជានុបស្សិស្ស, និច្ចំ ឧជ្ឈានសញ្ញិនោ;**

**អាសវា តស្ស វឌ្ឍន្តិ, អារា សោ អាសវក្ខយា។**

កាលបុគ្គលគយឃ្លាំមើលទោស របស់បុគ្គលដទៃជាប្រក្រតី មានការសំគាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ច, អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន, បុគ្គលនោះ ឈ្មោះថានៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ។

**២៥៤. អាកាសេវ បទំ នត្ថិ, សមណោ នត្ថិ ពាហិរេ;**

**បបញ្ចាភិរតា បជា, និប្បបញ្ចា តថាគតា។**

ស្នាមជើងក្នុងអាកាសមិនមាន, សមណៈក្នុងសាសនាខាងក្រៅមិនមាន, ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ, ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ។

**២៥៥. អាកាសេវ បទំ នត្ថិ, សមណោ នត្ថិ ពាហិរេ;**

**សង្ខារា សស្សតា នត្ថិ, នត្ថិ ពុទ្ធានមិញ្ជិតំ។**

ស្នាមជើងក្នុងអាកាសមិនមាន, សមណៈក្នុងសាសនាខាងក្រៅ មិនមាន, សង្ខារទាំងឡាយជារបស់ទៀង មិនមាន, កិលេសជាគ្រឿងញាប់ញ័ររបស់ព្រះពុទ្ធទាំងឡាយ

មិនមានឡើយ។

**មលវគ្គោ អដ្ឋារសមោ និដ្ឋិតោ។**

មលវគ្គ ទី១៨ ចប់ ។

## ១៩. ធម្មដ្ឋវគ្គ

**២៥៦. ន តេន ហោតិ ធម្មដ្ឋោ, យេនត្ថំ សាហសា នយេ;**
**យោ ច អត្ថំ អនត្ថញ្ច, ឧភោ និច្ឆេយ្យ បណ្ឌិតោ។**
**២៥៧. អសាហសេន ធម្មេន, សមេន នយតី បរេ;**
**ធម្មស្ស គុត្តោ មេធាវី, ធម្មដ្ឋោតិ បវុច្ចតិ។**

បុគ្គលកាត់សេចក្ដីដោយអាក្រក់ ដោយហេតុណា, ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ; លុះត្រាតែបុគ្គលណាជាបណ្ឌិតកាត់សេចក្ដីទាំងពីរគឺសេចក្ដីពិតនិងសេចក្ដីមិនពិត ណែនាំជនទាំងឡាយដទៃដោយមិនអាក្រក់ តាមធម៌ តាមសមគួរ (ដល់ទោស) បុគ្គលនោះឈ្មោះថាជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថាអ្នកតាំងនៅក្នុងធម៌ ។

**២៥៨. ន តេន បណ្ឌិតោ ហោតិ, យាវតា ពហុ ភាសតិ;**
**ខេមី អវេរី អភយោ, បណ្ឌិតោតិ បវុច្ចតិ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា

ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ, លុះត្រាតែបុគ្គលដែលមានសេចក្ដីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថាបណ្ឌិតបាន។

**២៥៩. ន តាវតា ធម្មធរោ, យាវតា ពហុ ភាសតិ;**
**យោ ច អប្បម្បិ សុត្វាន, ធម្មំ កាយេន បស្សតិ;**
**ស វេ ធម្មធរោ ហោតិ, យោ ធម្មំ នប្បមជ្ជតិ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ, លុះត្រាតែបុគ្គលណា ស្ដាប់ពុទ្ធវចនៈសូម្បីមានប្រមាណតិច ហើយឃើញធម៌ ដោយនាមកាយគឺចិត្តបាន, បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌; បុគ្គលណាមិនប្រមាទធម៌, បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌។

**២៦០. ន តេន ថេរោ សោ ហោតិ, យេនស្ស បលិតំ សិរោ;**
**បរិបក្កោ វយោ តស្ស, មោឃជិណ្ណោតិ វុច្ចតិ។**

**២៦១. យម្ហិ សច្ចញ្ច ធម្មោ ច, អហឹសា សំយមោ ទមោ;**
**ស វេ វន្តមលោ ធីរោ, ថេរោឥតិ បវុច្ចតិ[១]។**

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណាឈ្មោះថា

---

[១] ឱ. ស្យា. សោ ថេរោតិ បវុច្ចតិ ។

ជាថេរៈដោយហេតុនោះ មិនទាន់បានទេ, វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថាចាស់ជាមោឃៈ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនឯងផង មានក្នុងបុគ្គលណា, បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាថេរៈ។

**២៦២. ន វាក្ករណមត្តេន, វណ្ណបោក្ខរតាយ វា;**
**សាធុរូបោ នរោ ហោតិ, ឥស្សុកី មច្ឆរី សឋោ។**
**២៦៣. យស្ស ចេតំ សមុច្ឆិន្នំ, មូលឃច្ចំ សមូហតំ;**
**ស វន្តទោសោ មេធាវី, សាធុរូបោតិ វុច្ចតិ។**

បុគ្គលមានសេចក្តីប្រស្សា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថាជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ(ល្អ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ។ លុះត្រាតែទោសជាតមានឫស្សាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិល ដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ, បុគ្គលនោះ ជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាជាមនុស្សល្អបាន។

**២៦៤. ន មុណ្ឌកេន សមណោ, អព្វតោ អលិកំ ភណំ;**
**ឥច្ឆាលោភសមាបន្នោ, សមណោ កិំ ភវិស្សតិ។**
**២៦៥. យោ ច សមេតិ បាបានិ, អណុំ ថូលានិ សព្វសោ;**
**សមិតត្តា ហិ បាបានំ, សមណោតិ បវុច្ចតិ។**

បុគ្គលមិនបានឈ្មោះថាជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ, បុគ្គលអ្នកមិនមានសីលវ័តនិងធុតង្គវ័ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្ដីប្រាថ្នានិងលោភៈ ឈ្មោះថាជាសមណៈដូចម្ដេចបាន។

លុះត្រាតែបុគ្គលណា រំងាប់បាបទាំងឡាយ ទាំងតូចទាំងធំដោយប្រការទាំងពួងបាន ទើបហៅថាសមណៈ ព្រោះបាបទាំងឡាយដែលបុគ្គលនោះរំងាប់បានហើយ។

**២៦៦. ន តេន ភិក្ខុ សោ ហោតិ, យាវតា ភិក្ខតេ បរេ;**
**វិស្សំ ធម្មំ សមាទាយ, ភិក្ខុ ហោតិ ន តាវតា។**
**២៦៧. យោធ បុញ្ញញ្ច បាបញ្ច, ពាហេត្វា ព្រហ្មចរិយវា;**
**សង្ខាយ លោកេ ចរតិ, ស វេ ភិក្ខូតិ វុច្ចតិ។**

បុគ្គលណាដើរសុំជនទាំងឡាយដទៃ ដោយហេតុត្រឹមណា, បុគ្គលនោះមិនទាន់បានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមនោះទេ, បុគ្គលសមាទានធម៌ជាពិស ឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមតែការដើរសុំប៉ុណ្ណោះ មិនទាន់

បានទេ។ លុះត្រាតែបុគ្គលណាក្នុងលោកនេះ បន្សាត់បុណ្យនិងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោក ដោយសេចក្តីចេះដឹង, បុគ្គលនោះឯង ទើបហៅថាជាភិក្ខុ។

**២៦៨. ន មោនេន មុនី ហោតិ, មូឡ្ហរូបោ អវិទ្ទសុ;**
**យោ ច តុលំវ បគ្គយ្ហ, វរមាទាយ បណ្ឌិតោ។**
**២៦៩. បាបានិ បរិវជ្ជេតិ, ស មុនី តេន សោ មុនិ;**
**យោ មុនាតិ ឧភោ លោកេ, មុនិ តេន បវុច្ចតិ។**

បុគ្គលមានសេចក្តីវង្វេងជាធម្មតា មិនមានការចេះដឹងមិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ, លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាន់យកធម៌ដ៏ប្រសើរវៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីង ហើយថ្លឹងដូច្នោះ បុគ្គលនោះទើបឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន, បុគ្គលណាដឹងប្រយោជន៍ទាំងពីរក្នុងលោកបុគ្គលនោះ ទើបហៅថាមុនីដោយហេតុនោះ។

**២៧០. ន តេន អរិយោ ហោតិ, យេន បាណានិ ហឹសតិ;**
**អហឹសា សព្វបាណានំ, អរិយោតិ បវុច្ចតិ។**

បុគ្គលបៀតបៀនពួកសត្វ ដោយហេតុណា មិនឈ្មោះថាជាអរិយៈដោយហេតុនោះទេ, បុគ្គលដែលតថាគត

ហៅថាអរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង។

**២៧១. ន សីលព្វតមត្តេន, ពាហុសច្ចេន វា បន;**
**អថ វា សមាធិលាភេន, វិវិត្តសយនេន វា។**

**២៧២. ផុសាមិ នេក្ខម្មសុខំ, អបុថុជ្ជនសេវិតំ;**
**ភិក្ខុ វិស្សាសមាបាទិ, អប្បត្តោ អាសវក្ខយំ។**

ម្នាលភិក្ខុ ឈ្មោះថាភិក្ខុ បើនៅមិនទាន់ដល់នូវការអស់អាសវៈទេ មិនគប្បីដល់នូវសេចក្តីស្និទ្ធស្នាល (គឺកុំអាលទុកចិត្ត) ដោយគុណត្រឹមតែចតុប្បារិសុទ្ធិសីលឬធុតង្គវ័ត ឬថាដោយភាពជាអ្នកចេះដឹងច្រើន (គឺការរៀនចាំព្រះត្រៃបិដក) ឬថាដោយការបានសមាធិ (គឺសមាបត្តិ៨) ឬក៏ដោយការដេកក្នុងទីស្ងាត់ ពុំនោះសោត ដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញពាល់ត្រូវនេក្ខម្មសុខ (សុខដែលប្រាសចាកកាម គឺអនាគាមិសុខ) ដែលបុថុជ្ជនមិនដែលជួបប្រសព្វដូច្នេះឡើយ។

**ធម្មដ្ឋវគ្គោ ឯកូនវីសតិមោ និដ្ឋិតោ។**

ធម្មដ្ឋវគ្គ ទី១៩ ចប់ ។

# ២០. មគ្គវគ្គ

**២៧៣. មគ្គានដ្ឋង្គិកោ សេដ្ឋោ, សច្ចានំ ចតុរោ បទា;**
**វិរាគោ សេដ្ឋោ ធម្មានំ, ទ្វិបទានញ្ច ចក្ខុមា។**
**២៧៤. ឯសេវ មគ្គោ នត្ថញ្ញោ, ទស្សនស្ស វិសុទ្ធិយា;**
**ឯតញ្ហិ តុម្ហេ បដិបជ្ជថ, មារស្សេតំ បមោហនំ។**
**២៧៥. ឯតញ្ហិ តុម្ហេ បដិបន្នា, ទុក្ខស្សន្តំ ករិស្សថ;**
**អក្ខាតោ វោ មយា មគ្គោ, អញ្ញាយ សល្លកន្តនំ។**
**២៧៦. តុម្ហេហិ កិច្ចមាតប្បំ, អក្ខាតារោ តថាគតា;**
**បដិបន្នា បមោក្ខន្តិ, ឈាយិនោ មារពន្ធនា។**

ផ្លូវមានអង្គ៨ ប្រសើរជាងផ្លូវទាំងឡាយ, បទគឺអរិយសច្ចៈ៤ ប្រសើរជាងសច្ចៈទាំងឡាយ, វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ, ព្រះតថាគតទ្រង់មានចក្ខុ (៥ [10] ) ប្រសើរជាងពួកសត្វទ្វេបាទ និងអរូបធម៌ទាំងឡាយ។ ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធ នៃទស្សនៈ (គឺមគ្គនិងផល), ផ្លូវដទៃ មិនមានទេ, ព្រោះហេតុនោះ

---

10 ចក្ខុ៥ គឺមំសចក្ខុ =ព្រះនេត្រសាច់ធម្មតា១ ទិព្វចក្ខុ =ព្រះនេត្រដូចជាទិព្វ១ បញ្ញាចក្ខុ =ព្រះនេត្រគឺបញ្ញា ឬបញ្ញាដូចព្រះនេត្រ១ ពុទ្ធចក្ខុ =បញ្ញាដឹងសត្វដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង១ សមន្តចក្ខុ =សព្វញ្ញុតញ្ញាណ១ ។ ខុ.មហានិ. ៦៦/២២០។

អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ, ផ្លូវនោះ ជាផ្លូវញុំាងមារឲ្យវង្វេង។ អ្នកទាំងឡាយដើរទៅកាន់ផ្លូវនោះហើយអាចនឹងធ្វើឲ្យផុតទុក្ខបាន។ ផ្លូវនេះហើយដែលតថាគតដឹងថាជាផ្លូវកម្ចាត់បង់កូនសរ ប្រាប់ដល់អ្នកទាំងឡាយ, សេចក្តីព្យាយាម អ្នកទាំងឡាយគប្បីធ្វើ (ឥឡូវនេះឯង) ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់, ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន។

**២៧៧. សព្វេ សង្ខារា អនិច្ចាតិ, យទា បញ្ញាយ បស្សតិ;**
**អថ និព្វិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។**

កាលណា បុគ្គលយល់ឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង មិនទៀង, កាលនោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ, នេះ ជាផ្លូវនៃវិសុទ្ធិ (គឺព្រះនិព្វាន)។

**២៧៨. សព្វេ សង្ខារា ទុក្ខាតិ, យទា បញ្ញាយ បស្សតិ;**
**អថ និព្វិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។**

កាលណា បុគ្គលយល់ឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងជាទុក្ខ, កាលនោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ, នេះជាផ្លូវនៃវិសុទ្ធិ (គឺព្រះនិព្វាន)។

**២៧៩. សព្វេ ធម្មា អនត្តាតិ, យទា បញ្ញាយ បស្សតិ;**
**អថ និព្វិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។**

កាលណា បុគ្គលយល់ឃើញដោយបញ្ញាថា ធម៌ទាំងឡាយទាំងពួង ជាអនត្តា, កាលនោះ រមែងនឿយណាយក្នុងសេចក្ដីទុក្ខ, នេះ ជាផ្លូវនៃវិសុទ្ធិ (គឺព្រះនិព្វាន)។

**២៨០. ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ,**
**យុវា ពលី អាលសិយំ ឧបេតោ;**
**សំសន្នសង្កប្បមនោ កុសីតោ,**
**បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ។**

បុគ្គលនៅក្មេង មានកំលាំង ទាស់តែប្រកប ដោយសេចក្ដីខ្ជិលច្រអូស មិនប្រឹងប្រែងក្នុងកាលដែលគួរប្រឹងប្រែងមានសេចក្ដីត្រិះរិះ ក្នុងចិត្តលិចចុះក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល រមែងមិនបានផ្លូវនៃបញ្ញាឡើយ។

**២៨១. វាចានុរក្ខី មនសា សុសំវុតោ,**
**កាយេន ច អកុសលំ ន កយិរា[11];**
**ឯតេ តយោ កម្មបថេ វិសោធយេ,**
**អារាធយេ មគ្គមិសិប្បវេទិតំ។**

បុគ្គល គប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អដោយចិត្ត,

11 ឆ. កាយេន ច នាកុសលំ កយិរា។

ទាំងមិនគប្បីធ្វើអកុសលដោយកាយ, បុគ្គលគប្បីជម្រះកម្មបថទាំង៣នេះ និងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អសម្តែងទុកហើយ។

**២៨២. យោគា វេ ជាយតី ភូរិ, អយោគា ភូរិសង្ខយោ;**
**ឯតំ ទ្វេធាបថំ ញត្វា, ភវាយ វិភវាយ ច;**
**តថាត្តានំ និវេសេយ្យ, យថា ភូរិ បវឌ្ឍតិ។**

ប្រាជ្ញារមែងកើតអំពីការប្រកប (ក្នុងអារម្មណ៍កម្មដ្ឋាន ៣៨), សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប; អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកបទាំងពីរនេះ ថាជាគន្លងនៃសេចក្តីចម្រើន និងសេចក្តីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួនទុក ដោយប្រការនោះ។

**២៨៣. វនំ ឆិន្ទថ មា រុក្ខំ, វនតោ ជាយតី ភយំ;**
**ឆេត្វា វនញ្ច វនថញ្ច, និព្វនា ហោថ ភិក្ខវោ។**

**២៨៤. យាវ ហិ វនថោ ន ឆិជ្ជតិ,**
**អណុមត្តោបិ នរស្ស នារិសុ;**
**បដិពទ្ធមនោវ តាវ សោ,**
**វច្ឆោ ខីរបកោវ មាតរិ។**

អ្នកទាំងឡាយចូរកាត់នូវព្រៃគឺកិលេសចេញ, ចូរកុំកាត់

នូវដើមឈើ, (ព្រោះថា) ភ័យកើតអំពីព្រៃគឺកិលេស; ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកាត់ នូវព្រៃគឺកិលេសផង នូវកិលេសដូចដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកមិនមានព្រៃគឺកិលេសឡើយ។ ព្រោះថា កិលេសដូចដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារីដរាបណា, នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ។

**២៨៥. ឧច្ឆិន្ទ សិនេហមត្តនោ,**
**កុមុទំ សារទិកំវ បាណិនា;**
**សន្តិមគ្គមេវ ព្រូហយ,**
**និព្វានំ សុគតេន ទេសិតំ។**

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទ ដែលកើតក្នុងសរទកាល ដោយដៃ, អ្នកចូរបណ្តុះនូវផ្លូវសន្តិសុខតែម្យ៉ាង, (ព្រោះថា) ព្រះនិព្វានគឺព្រះសុគតទ្រង់សម្តែងទុកហើយ។

**២៨៦. ឥធ វស្សំ វសិស្សាមិ, ឥធ ហេមន្តគិម្ហិសុ;**
**ឥតិ ពាលោ វិចិន្តេតិ, អន្តរាយំ ន ពុជ្ឈតិ។**

ជនពាលរមែងគិតខុសថា "អញនឹងនៅទីនេះ អស់វស្សានរដូវ, អញនឹងនៅទីនេះ អស់ហេមន្តរដូវ និងគិម្ហរដូវ" មិនដឹងច្បាស់សេចក្តីអន្តរាយនៃជីវិត។

**២៨៧. តំ បុត្តបសុសម្មត្តំ, ព្យាសត្តមនសំ នរំ;**
**សុត្តំ គាមំ មហោឃោវ, មច្ចុ អាទាយ គច្ឆតិ។**

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកទៅនូវនរជន អ្នកស្រវឹងជ្រប់ក្នុងកូននិងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ដោយអាការៈផ្សេងៗនុ៎ះឯង ដូចទឹកជំនន់ដ៏ធំ ដែលកួចនាំយកនូវអ្នកស្រុកកំពុងតែដេកលក់ដូច្នោះឯង ។

**២៨៨. ន សន្តិ បុត្តា តាណាយ, ន បិតា នាបិ ពន្ធវា;**
**អន្តកេនាធិបន្នស្ស, នត្ថិ ញាតីសុ តាណតា។**

**២៨៩. ឯតមត្ថវសំ ញត្វា, បណ្ឌិតោ សីលសំវុតោ;**
**និព្វានគមនំ មគ្គំ, ខិប្បមេវ វិសោធយេ។**

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង, មាតាបិតា ក៏មិនមានដើម្បីជាទីពឹង, ផៅពង្សក៏មិនមានដើម្បីជាទីពឹង; សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមានឡើយ។ បណ្ឌិតដឹងអំនាចប្រយោជន៍ហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វាន ឲ្យបាន។

**មគ្គវគ្គោ វីសតិមោ និដ្ឋិតោ។**

មគ្គវគ្គ ទី២០ ចប់ ។

## ២១. បកិណ្ណកវគ្គ

**២៩០. មត្តាសុខបរិច្ចាគា, បស្សេ ចេ វិបុលំ សុខំ;**
**ចជេ មត្តាសុខំ ធីរោ, សម្បស្សំ វិបុលំ សុខំ។**

បុគ្គលបើឃើញសេចក្ដីសុខដ៏ធំទូលាយ ព្រោះតែលះបង់សុខល្មមប្រមាណ, អ្នកមានប្រាជ្ញាកាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ។

**២៩១. បរទុក្ខូបធានេន, អត្តនោ សុខមិច្ឆតិ;**
**វេរសំសគ្គសំសដ្ឋោ, វេរា សោ ន បរិមុច្ចតិ។**

ជនប្រាថ្នាសេចក្ដីសុខដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ, ជននោះឈ្មោះថាច្រឡូកច្របល់ហើយ ដោយការជាប់ជំពាក់ គឺពៀររមែងមិនរួចចាកពៀរទេ។

**២៩២. យញ្ហិ កិច្ចំ តទបវិទ្ធំ, អកិច្ចំ បន កយីរតិ[12];**
**ឧន្នឡានំ បមត្តានំ, តេសំ វឌ្ឍន្តិ អាសវា។**

**២៩៣. យេសញ្ច សុសមារទ្ធា, និច្ចំ កាយគតា សតិ;**
**អកិច្ចំ តេ ន សេវន្តិ, កិច្ចេ សាតច្ចការិនោ;**

---

12 ឆ. យញ្ហិ កិច្ចំ អបវិទ្ធំ, អកិច្ចំ បន កយិរតិ (ជ្ជ. ករីយតិ)។

**សតានំ សម្បជានានំ, អត្ថំ គច្ឆន្តិ អាសវា។**

របស់ណាដែលខ្លួនគួរធ្វើរបស់នោះ ពួកភិក្ខុណាលះបង់ចោលហើយ, តែរបស់មិនគួរធ្វើ ត្រឡប់ជាធ្វើវិញ, អាសវៈទាំងឡាយ តែងចម្រើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្ដីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ។ លុះតែសតិប្រព្រឹត្តទៅក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ; អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិមានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ។

**២៩៤. មាតរំ បិតរំ ហន្ត្វា, រាជានោ ទ្វេ ច ខត្តិយេ;**
**រដ្ឋំ សានុចរំ ហន្ត្វា, អនីឃោ យាតិ ព្រាហ្មណោ។**
**២៩៥. មាតរំ បិតរំ ហន្ត្វា, រាជានោ ទ្វេ ច សោត្ថិយេ;**
**វេយគ្ឃបញ្ចមំ ហន្ត្វា, អនីឃោ យាតិ ព្រាហ្មណោ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិដូចស្ដេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចដែនប្រព្រឹត្តទៅមួយអន្លើដោយបុរសអ្នកដើរតាមគឺស្មៀនផង រមែង

បានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ។

**២៩៦. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ ពុទ្ធគតា សតិ។**

សតិរបស់ពួកជនណា ដែលប្រព្រឹត្តទៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ, ពួកជននោះ ឈ្មោះថាសាវករបស់ព្រះគោតម រមែងភ្ញាក់រលឹក ដោយល្អ សព្វកាល។

**២៩៧. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ ធម្មគតា សតិ។**

សតិរបស់ពួកជនណា ដែលប្រព្រឹត្តទៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ, ពួកជននោះ ឈ្មោះថាសាវករបស់ព្រះគោតម រមែងភ្ញាក់រលឹក ដោយប្រពៃ សព្វកាល។

**២៩៨. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ សង្ឃគតា សតិ។**

សតិ របស់ពួកជនណា ដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ, ពួកជននោះ ឈ្មោះថាសាវករបស់ព្រះគោតម រមែងភ្ញាក់រលឹក ដោយប្រពៃ សព្វកាល។

**២៩៩. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ កាយគតា សតិ។**

សតិរបស់ពួកជនណា ដែលប្រព្រឹត្តទៅក្នុងកាយ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ, ពួកជននោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រលឹក ដោយប្រពៃសព្វកាល។

**៣០០. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, អហឹសាយ រតោ មនោ។**

ចិត្តរបស់ជនពួកណា ដែលត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃទាំងយប់, ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រលឹក ដោយប្រពៃសព្វកាល។

**៣០១. សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, ភាវនាយ រតោ មនោ។**

ចិត្តរបស់ជនពួកណា ដែលត្រេកអរហើយ ក្នុងមេត្តាភាវនា ទាំងថ្ងៃទាំងយប់, ជនពួកនោះ ឈ្មោះថាសាវករបស់ព្រះគោតមរមែងភ្ញាក់រលឹកដោយប្រពៃសព្វកាល។

**៣០២. ទុប្បព្វជ្ជំ ទុរភិរមំ, ទុរាវាសា ឃរា ទុខា;**
**ទុក្ខោសមានសំវាសោ, ទុក្ខានុបតិតទ្ធគូ;**

**តស្មា ន ចទ្ធគូ សិយា, ន ច ទុក្ខានុបតិតោ សិយា។**

ការចេញបួសបាន ជាទុក្ខ, ការត្រេកអរក្នុងធម៌ដែលអ្នកបួសត្រូវបំពេញ ជាទុក្ខ, ផ្ទះទាំងឡាយ ដែលពួកគ្រហស្ថនៅត្រូវធម៌ ជាទុក្ខ, ការនៅរួមជាមួយនឹងអ្នកដែលចាំតែរករឿង ជាទុក្ខ, អ្នកដើរផ្លូវឆ្ងាយគឺវដ្តៈ ត្រូវទុក្ខធ្លាក់ជាប់តាម; ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវទុក្ខធ្លាក់ជាប់តាមផង។

**៣០៣. សទ្ធោ សីលេន សម្បន្នោ, យសោភោគសមប្បិតោ;**
**យំ យំ បទេសំ ភជតិ, តត្ថ តត្ថេវ បូជិតោ។**

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយសនិងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

**៣០៤. ទូរេ សន្តោ បកាសេន្តិ, ហិមវន្តោវ បព្វតោ;**
**អសន្តេត្ថ ន ទិស្សន្តិ, រត្តឹ ខិត្តា យថា សរា។**

ពួកសប្បុរសរមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ ពួកអសប្បុរស(ទុកជាឋិតនៅ)ក្នុងទីជិត ក៏រមែងមិនប្រាកដដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់។

**៣០៥. ឯកាសនំ ឯកសេយ្យំ, ឯកោ ចរមតន្ទិតោ;**
**ឯកោ ទមយមត្តានំ, វនន្តេ រមិតោ សិយា។**

បុគ្គលគួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់។

**បកិណ្ណកវគ្គោ ឯកវីសតិមោ និដ្ឋិតោ។**

បកិណ្ណកវគ្គ ទី២១ ចប់ ។

## ២២. និរយវគ្គ

**៣០៦. អភូតវាទី និរយំ ឧបេតិ,**
**យោ វាបិ* កត្វា ន ករោមិ ចាហ;**
**ឧភោបិ តេ បេច្ច សមា ភវន្តិ,**
**និហីនកម្មា មនុជា បរត្ថ។**

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយនិយាយថាអញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរកជនទាំងពីរនាក់ ដែលមានអំពើទាបថោក (ស្មើគ្នា)នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត។

**៣០៧. កាសាវកណ្ឋា ពហវោ, បាបធម្មា អសញ្ញតា;**
**បាបា បាបេហិ កម្មេហិ, និរយំ តេ ឧបបជ្ជរេ។**

ពួកបុគ្គលបាបច្រើននាក់ ដែលមានកព័ន្ធព័ទ្ធដោយ

សំពត់កាសាវៈ តែ(ប្រព្រឹត្ត)ធម៌ដ៏លាមក មិនបានសង្រួម ពួកបុគ្គលបាបទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយដ៏លាមកនោះ។

**៣០៨. សេយ្យោ អយោគុឡោ ភុត្តោ, តត្តោ អគ្គិសិខូបមោ;**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ, រដ្ឋបិណ្ឌមសញ្ញតោ។**

បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែកដែលកំពុងក្តៅមានពណ៌ដូចអណ្តាតភ្លើងវិញ ប្រសើរជាងបព្វជិតទ្រុស្តសីល មិនសង្រួមបរិភោគដុំបាយរបស់អ្នកដែន នឹងប្រសើរដូចម្តេចបាន។

**៣០៩. ចត្តារិ ឋានានិ នរោ បមត្តោ,**
**អាបជ្ជតិ បរទារូបសេវី;**
**អបុញ្ញលាភំ ន និកាមសេយ្យំ,**
**និន្ទំ តតីយំ និរយំ ចតុត្ថំ។**

**៣១០. អបុញ្ញលាភោ ច គតី ច បាបិកា,**
**ភីតស្ស ភីតាយ រតី ច ថោកិកា;**
**រាជា ច ទណ្ឌំ គរុកំ បណេតិ,**
**តស្មា នរោ បរទារំ ន សេវេ។**

នរជនអ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ៤ គឺទី១ ការបានរបស់

មិនមែនជាបុណ្យ, ទី២ ការដេកមិនបានតាមប្រាថ្នា, ទី៣ ការតិះដៀល, ទី៤ ការធ្លាក់នរក។ (ហេតុនៃសេចក្តីទុក្ខ៤យ៉ាងផ្សេងទៀត) គឺការបានរបស់មិនជាបុណ្យ១ មានគតិអាក្រក់១ តម្រេករបស់បុរសអ្នកខ្លាចជាមួយនឹងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ។

**៣១១. កុសោ យថា ទុគ្គហិតោ, ហត្ថមេវានុកន្តតិ;**
**សាមញ្ញំ ទុប្បរាមដ្ឋំ, និរយាយុបកឌ្ឍតិ។**

ស្បូវភ្លាំងដែលបុគ្គលកាន់មិនល្អ រមែងមុតដៃ យ៉ាងណាមិញ, ភាពជាសមណៈ ដែលបព្វជិតកាន់មិនល្អហើយ រមែងទាញបព្វជិតនោះទៅនរក ក៏យ៉ាងនោះឯង។

**៣១២. យំ កិញ្ចិ សិថិលំ កម្មំ, សំកិលិដ្ឋញ្ច យំ វតំ;**
**សង្កស្សរំ ព្រហ្មចរិយំ, ន តំ ហោតិ មហប្ផលំ។**

កម្មណាមួយដែលធូរថយក្តី វ័តណាមួយ ដែលសៅហ្មងក្តី ព្រហ្មចរិយៈ ដែលបុគ្គលរលឹកដោយសេចក្តីរង្កៀសក្តី កម្មទាំង៣នោះ ជារបស់មិនមានផលច្រើនឡើយ។

**៣១៣. កយិរា ចេ កយិរាថេនំ, ទឡ្ហមេនំ បរក្កមេ;**
**សិថិលោ ហិ បរិព្វាជោ, ភិយ្យោ អាកិរតេ រជំ។**

បើបុគ្គលធ្វើគប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថាសមណធម៌ជាគ្រឿងរៀរចាកកិលេសធូរថយ រមែងរោយធូលីគឺរាគៈជាដើមដល់បុគ្គលដោយក្រៃលែង។

**៣១៤. អកតំ ទុក្កដំ សេយ្យោ, បច្ឆា តប្បតិ ទុក្កដំ;**
**កតញ្ច សុកតំ សេយ្យោ, យំ កត្វា នានុតប្បតិ។**

អំពើអាក្រក់ដែលបុគ្គលមិនធ្វើប្រសើរជាង, (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ, បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ, អំពើនោះ ជាអំពើល្អ, បើបុគ្គលធ្វើហើយ ឈ្មោះថាបុគ្គលប្រសើរ។

**៣១៥. នគរំ យថា បច្ចន្តំ, គុត្តំ សន្តរពាហិរំ;**
**ឯវំ គោបេថ អត្តានំ, ខណោ វោ មា ឧបច្ចគា;**
**ខណាតីតា ហិ សោចន្តិ, និរយម្ហិ សមប្បិតា។**

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា, អ្នកទាំងឡាយគួររក្សាខ្លួនយ៉ាងនោះ, កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ; ព្រោះថា ជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយ ក្នុងនរកមីរដេរដាស។

**៣១៦. អលជ្ជិតាយេ លជ្ជន្តិ, លជ្ជិតាយេ ន លជ្ជរេ;**
**មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតឹ។**

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងវត្ថុដែលមិនគួរខ្មាស រមែងមិនខ្មាសក្នុងវត្ថុដែលគួរខ្មាស តែងទៅកាន់ទុគ្គតិ។

**៣១៧. អភយេ ភយទស្សិនោ, ភយេ ចាភយទស្សិនោ;**
**មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតឹ។**

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ ដែលយល់ឃើញថាជាវត្ថុដែលគួរខ្លាច ក្នុងវត្ថុដែលមិនគួរខ្លាចផង យល់ឃើញវត្ថុ ដែលមិនគួរខ្លាចថាជាវត្ថុដែលគួរខ្លាចផង តែងទៅកាន់ទុគ្គតិ។

**៣១៨. អវជ្ជេ វជ្ជមតិនោ, វជ្ជេ ចាវជ្ជទស្សិនោ;**
**មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតឹ។**

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ ដែលយល់ឃើញថាជាវត្ថុមានទោស ក្នុងវត្ថុដែលមិនមានទោសផង យល់ឃើញថាជាវត្ថុមិនមានទោស ក្នុងវត្ថុដែលមានទោសផង សត្វទាំងនោះតែងទៅកាន់ទុគ្គតិ។

**៣១៩. វជ្ជញ្ច វជ្ជតោ ញត្វា, អវជ្ជញ្ច អវជ្ជតោ;**
**សម្មាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ សុគ្គតឹ។**

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងវត្ថុដែលមានទោសថាជាវត្ថុមានទោសផង ដឹងវត្ថុមិនមានទោសថាជាវត្ថុមិនមានទោសផង តែងទៅកាន់សុគតិ។

**និរយវគ្គោ ទ្វាវីសតិមោ និដ្ឋិតោ។**

និរយវគ្គ ទី២២ ចប់ ។

## ២៣. នាគវគ្គ

**៣២០. អហំ នាគោវ សង្គាមេ, ចាបតោ[13] បតិតំ សរំ;**
**អតិវាក្យំ តិតិក្ខិស្សំ, ទុស្សីលោ ហិ ពហុជ្ជនោ។**

តថាគតនឹងអត់ទ្រាំចំពោះពាក្យល្មើល ដូចដំរីកាលអត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថាជនទ្រុស្តសីលមានច្រើននាក់ណាស់។

**៣២១. ទន្តំ នយន្តិ សមិតិំ, ទន្តំ រាជាភិរូហតិ;**
**ទន្តោ សេដ្ឋោ មនុស្សេសុ, យោតិវាក្យំ តិតិក្ខតិ។**

ពួកជន តែងនាំវាហនៈ ដែលទូន្មានហើយ ទៅកាន់ទីប្រជុំ, ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ, បណ្តាមនុស្សទាំងឡាយ មនុស្សណាអត់សង្កត់នឹងពាក្យល្មើសបាន, មនុស្សនោះ ជាអ្នកមានខ្លួនទូន្មាន

13 ខ.ស្យា. ចាបាតោ។ បទានុ. ចាប អការន្ត បុំលិង្គ។ យកតាមច្បាប់ឆដ្ឋ។

ហើយ ឈ្មោះថាជាបុគ្គលប្រសើរបំផុត។

**៣២២. វរមស្សតរា ទន្តា, អាជានីយា ច[14] សិន្ធវា;**

**កុញ្ជរា ច* មហានាគា, អត្តទន្តោ តតោ វរំ។**

ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលបង្ហាត់បានហើយ រាប់ថាជាសត្វដ៏ប្រសើរ, ចំនែកបុគ្គលដែលមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងអស់នោះទៅទៀត។

**៣២៣. ន ហិ ឯតេហិ យានេហិ, គច្ឆេយ្យ អគតំ ទិសំ;**

**យថាត្តនា សុទន្តេន, ទន្តោ ទន្តេន គច្ឆតិ។**

បុគ្គលទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថាទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងនោះឡើយ។

**៣២៤. ធនបាលកោ នាម កុញ្ជរោ,**

**កដុកប្បភេទនោ ទុន្និវារយោ;**

**ពទ្ធោ កពឡំ ន ភុញ្ជតិ,**

**សុមរតិ នាគវនស្ស កុញ្ជរោ។**

ដំរី ឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយ

---

14 * ខ. វ ។ តាមសព្វមានអត្ថសមុច្ច័យ ប្រើ ច ច្រើនេជាង ស្យា. ក៏ប្រើ ច។

ហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យចងភ្ជាប់មិនស៊ីស្មៅទេ ព្រោះរលឹកដល់ព្រៃខ្មឹងដែលដំរីនោះធ្លាប់នៅ។

**៣២៥. មិទ្ធី យទា ហោតិ មហគ្ឃសោ ច,**
**និទ្ទាយិតា សម្បរិវត្តសាយី;**
**មហាវរាហោវ និវាបបុដ្ឋោ,**
**បុនប្បុនំ គព្ភមុបេតិ មន្ទោ។**

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះននៀលផង ដូចជ្រូកស្រុកដែលបុគ្គលចិញ្ចឹមដោយសូករភត្ត, កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយៗ។

**៣២៦. ឥទំ បុរេ ចិត្តមចារិ ចារិកំ,**
**យេនិច្ឆកំ យត្ថកាមំ យថាសុខំ;**
**តទជ្ជហំ និគ្គហេស្សាមិ យោនិសោ,**
**ហត្ថិប្បភិន្នំ វិយ អង្កុសគ្គហោ។**

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិកតាមអាការៈដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយ ក្នុងថ្ងៃនេះ អញនឹងសង្កត់

សង្កិនចិត្តនោះ ដោយឧបាយដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ។

**៣២៧. អប្បមាទរតា ហោថ, សចិត្តមនុរក្ខថ;**
**ទុគ្គា ឧទ្ធរថត្តានំ, បង្កេ សន្នោវ កុញ្ជរោ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ, ចូររក្សាចិត្តរបស់ខ្លួន, ចូររើខ្លួនចេញចាកភក់គឺកិលេសដែលឆ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់រើខ្លួនឲ្យរួចបាន។

**៣២៨. សចេ លភេថ និបកំ សហាយំ,**
**សទ្ធឹ ចរំ សាធុវិហារិធីរំ;**
**អភិភុយ្យ សព្វានិ បរិស្សយានិ,**
**ចរេយ្យ តេនត្តមនោ សតីមា។**

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតីគ្របសង្កត់សេចក្តីអន្តរាយ ទាំងពួងហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង។

**៣២៩. នោ ចេ លភេថ និបកំ សហាយំ,**
**សទ្ធឹ ចរំ សាធុវិហារិធីរំ;**

**រាជាវ រដ្ឋំ វិជិតំ បហាយ,**

**ឯកោ ចរេ មាតង្គរញ្ញេវ នាគោ។**

បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំមានគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯងវិញ ដូចព្រះរាជាលះបង់រដ្ឋដែលទ្រង់ឈ្នះហើយស្តេចទៅតែឯកអង្គ ពុំនោះសោតដូចដំរីឈ្មោះមាតង្គៈដែលលះហ្វូងត្រាច់ទៅតែឯកឯង ក្នុងព្រៃដូច្នោះដែរ។

**៣៣០. ឯកស្ស ចរិតំ សេយ្យោ,**

**នត្ថិ ពាលេ សហាយតា;**

**ឯកោ ចរេ ន ច បាបានិ កយិរា,**

**អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ។**

ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតិប្រសើរបំផុត (ព្រោះថា)សហាយតាគុណ រមែងមិនមានក្នុងជនពាលឡើយ, បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូងត្រាច់ទៅតែឯកឯង ក្នុង

ព្រៃ ដូច្នោះដែរ។

**៣៣១. អត្ថម្ហិ ជាតម្ហិ សុខា សហាយា,**
**តុដ្ឋី សុខា យា ឥតរីតរេន;**
**បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ,**
**សព្វស្ស ទុក្ខស្ស សុខំ បហានំ។**

កាលបើសេចក្តីត្រូវការកើតឡើងហើយ សម្លាញ់ទាំងឡាយ ជាសុខ, សេចក្តីត្រេកអរ តាមមានតាមបាន ជាសុខ, បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត, ការលះបង់ទុក្ខទាំងអស់ ជាសុខ។

**៣៣២. សុខា មត្តេយ្យតា លោកេ, អថោ បេត្តេយ្យតា សុខា;**
**សុខា សាមញ្ញតា លោកេ, អថោ ព្រហ្មញ្ញតា សុខា។**

ការប្រតិបត្តិល្អក្នុងមាតា ជាសុខក្នុងលោក, ការប្រតិបត្តិល្អក្នុងបិតា ក៏ជាសុខក្នុងលោក, ការប្រតិបត្តិល្អក្នុងអ្នកបួស ក៏ជាសុខក្នុងលោក, ការប្រតិបត្តិល្អ ក្នុងព្រះពុទ្ធព្រះបច្ចេកពុទ្ធនិងពុទ្ធសាវក ក៏ជាសុខ ក្នុងលោក។

**៣៣៣. សុខំ យាវ ជរា សីលំ, សុខា សទ្ធា បតិដ្ឋិតា;**
**សុខោ បញ្ញាយ បដិលាភោ, បាបានំ អករណំ សុខំ។**

សីល នាំសេចក្តីសុខមកឲ្យដរាបដល់ចាស់ជរា, សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ ជាសុខ, ការបានចំពោះនូវ

បញ្ញា ក៏ជាសុខ, ការមិនធ្វើបាបទាំងឡាយ ក៏ជាសុខ។

**នាគវគ្គោ តេវីសតិមោ និដ្ឋិតោ។**

នាគវគ្គ ទី២៣ ចប់ ។

## ២៤. តណ្ហាវគ្គ

**៣៣៤. មនុជស្ស បមត្តចារិនោ, តណ្ហា វឌ្ឍតិ មាលុវា វិយ;**
**សោ បលវេតី ហុរា ហុរំ, ផលមិច្ឆំវ វនស្មិ* វានរោ។**

តណ្ហា តែងចម្រើនដល់មនុស្ស អ្នកមានការប្រព្រឹត្តដោយសេចក្ដីប្រមាទជាប្រក្រតី ដូចវល្លិ៍រួបរឹតដើមឈើហើយចម្រើនឡើង, បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វាកាលប្រាថ្នាផ្លែឈើ ក៏លោតទៅក្នុងព្រៃដូច្នោះដែរ។

**៣៣៥. យំ ឯសា សហតី ជម្មី, តណ្ហា លោកេ វិសត្តិកា;**
**សោកា តស្ស បវឌ្ឍន្តិ, អភិវឌ្ឍំវ[15] ពីរណំ។**

តណ្ហានុ៎ះជាទោសជាតិដ៏លាមកផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា, សេចក្ដីសោកស្ដាយ តែងចម្រើនឡើង ដល់បុគ្គលនោះ ដូចស្បូវរណ្ដាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្រាំហើយ ពន្លកលូត

15 ឆ. អភិវដ្ឋំវ, ស្យា. អភិវុដ្ឋំវ, កត្ថចិ. អភិវដ្ឍំវ, អភិវុឌ្ឍំវ។

លេចឡើងដូច្នោះដែរ។

**៣៣៦. យោ ចេតំ សហតេ ជម្មឹ, តណ្ហំ លោកេ ទុរច្ចយំ;**
**សោកា តម្ហា បបតន្តិ, ឧទពិន្ទុវ បោក្ខរា។**

ចំនែកជនណាគ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោកដែលគេឆ្លងបានដោយកម្រនោះ, សេចក្តីសោកស្តាយតែងធ្លាក់ចេញចាកជននោះឯង ដូចតំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូកដូច្នោះដែរ។

**៣៣៧. តំ វោ វទាមិ ភទ្ទំ វោ, យាវន្តេត្ថ សមាគតា;**
**តណ្ហាយ មូលំ ខណថ, ឧសីរត្ថោវ ពីរណំ;**
**មា វោ នឡំវ សោតោវ, មារោ ភញ្ជិ បុនប្បុនំ។**

ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ, អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំគ្នាក្នុងទីនេះ, សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះរូបចុះ, អ្នកទាំងឡាយ ចូររំលើងឫសតណ្ហាចោលចេញដូចបុគ្គលអ្នកត្រូវការដោយស្បូវភ្លាំង គាស់ស្បូវរណ្តាសចោលចេញដូច្នោះ, មារ[16] កុំរុករានអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ។

---

16 ក្នុងទីនេះ បានដល់កិលេសមារ១ មច្ចុមារ១ ទេវបុត្តមារ១ ។ អដ្ឋកថា។

**៣៣៨. យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ,**
**ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ;**
**ឯវម្បិ តណ្ហានុសយេ អនូហតេ,**
**និព្វត្តតី ទុក្ខមិទំ បុនប្បុនំ។**

កាលបើឫសឈើមិនមានសេចក្ដីអន្តរាយ នៅមាំមួនដើមឈើទុកជាគេកាប់ចោលហើយ ក៏ដុះឡើងទៀតបាន មានឧបមាដូចម្ដេចមិញ, កាលបើតណ្ហានុស័យបុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម)នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះដែរ។

**៣៣៩. យស្ស ឆត្តឹសតិ សោតា, មនាបស្សវនា ភុសា;**
**មហា វហន្តិ ទុទ្ទិដ្ឋឹ, សង្កប្បា រាគនិស្សិតា។**

ខ្សែតណ្ហា៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា, តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ។

**៣៤០. សវន្តិ សព្វធិ សោតា, លតា ឧប្បជ្ជ* តិដ្ឋតិ;**
**តញ្ច ទិស្វា លតំ ជាតំ, មូលំ បញ្ញាយ ឆិន្ទថ។**

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួងដូចជាវល្លិ ដែលបែកខ្នែងឡើងតាំងនៅដូច្នោះ បើអ្នក

ទាំងឡាយ ឃើញតណ្ហាដូចជាវល្លិនោះកើតឡើងហើយ ចូរកាត់ឫសចោលចេញដោយកាំបិតគឺបញ្ញា។

**៣៤១. សរិតានិ សិនេហិតានិ ច,**
**សោមនស្សានិ ភវន្តិ ជន្តុនោ;**
**តេ សាតសិតា សុខេសិនោ,**
**តេ វេ ជាតិជរូបគា នរា។**

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយ សេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ, ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីករាយ អ្នកស្វែងរកសេចក្តីសុខ, នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិនិងជរា។

**៣៤២. តសិណាយ បុរក្ខតា បជា,**
**បរិសប្បន្តិ សសោវ ពន្ធិតោ;**
**សំយោជនសង្គសត្តកា,**
**ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ។**

ពួកសត្វដែលតណ្ហាជាទីញុាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ ដូចសត្វទន្សាយដែលនាយព្រានទាក់បានហើយដូច្នោះ, ពួកសត្វដែលជាប់ក្នុងសំយោជនៈ និងសង្គធម៌(ធម៌ជាគ្រឿងជំពាក់) តែងដល់នូវសេចក្តីទុក្ខ

រឿយៗ អស់កាលអង្វែង។

**៣៤៣. តសិណាយ បុរក្ខតា បជា,**
**បរិសប្បន្តិ សសោវ ពន្ធិតោ;**
**តស្មា តសិណំ វិនោទយេ,**
**ភិក្ខុ អាកង្ខំ វិរាគមត្តនោ។**

ពួកសត្វដែលតណ្ហាជាទីញុំាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយតែងរន្ធត់ ដូចសត្វទន្សាយដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន, គប្បីបន្ទោបង់តណ្ហាដែលជាគ្រឿងតក់ស្លុតចោលចេញ។

**៣៤៤. យោ និព្វនថោ វនាធិមុត្តោ, វនមុត្តោ វនមេវ ធាវតិ;**
**តំ បុគ្គលមេថ បស្សថ, មុត្តោ ពន្ធនមេវ ធាវតិ។**

បុគ្គលណា មិនអាស្រ័យក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ; អ្នកទាំងឡាយចូរមើលនូវបុគ្គលនោះឯង, បុគ្គលនោះរួចចាកចំណងគឺឃរាវាសហើយ ស្ទុះទៅរកចំណងគឺឃរាវាសវិញ។

**៣៤៥. តំ ទឡ្ហំ ពន្ធនមាហុ ធីរា,**
**យទាយសំ ទារុជបព្វជញ្ច*;**
**សារត្តរត្តា មណិកុណ្ឌលេសុ,**
**បុត្តេសុ ទារេសុ ច យា អបេក្ខា។**
**៣៤៦. ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា,**
**ឱហារិនំ សិថិលំ ទុប្បមុញ្ចំ;**
**ឯតម្បិ ឆេត្វាន បរិព្វជន្តិ,**
**អនបេក្ខិនោ កាមសុខំ បហាយ។**

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយាប្លងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះថាជាចំណងមាំមួនឡើយ; ពួកជនណា ត្រេកអរក្រៃពេកក្នុងកែវមណីនិងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យកូននិងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយហៅសេចក្តីត្រេកអរនិងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ (ទាញសត្វទម្លាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យលះ បង់កាមសុខហើយចេញបួស។

**៣៤៧. យេ រាគរត្តានុបតន្តិ សោតំ,**
**សយំកតំ មក្កដកោវ ជាលំ;**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា,**
**អនបេក្ខិនោ សព្វទុក្ខំ បហាយ។**

ពួកជនណា ត្រេកអរដោយអំនាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះ កាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង, អ្នកប្រាជ្ញទាំងឡាយ តែងកាត់នូវខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់ទុក្ខទាំងពួងចេញទៅ។

**៣៤៨. មុញ្ច បុរេ មុញ្ច បច្ឆតោ, មជ្ឈេ មុញ្ច ភវស្ស បារគូ;**
**សព្វត្ថ វិមុត្តមានសោ, ន បុនំ ជាតិជរំ ឧបេហិសិ។**

អ្នកចូរដោះ (សេចក្តីអាល័យ) ក្នុងកាលមុនចេញ, ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលខាងក្រោយចេញ, ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលជាបច្ចុប្បន្នចេញ, (កាលបើធ្វើយ៉ាងនេះ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រលះ ចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិនិងជរាទៀតឡើយ។

**៣៤៩. វិតក្កមថិតស្ស ជន្តុនោ, តិព្វរាគស្ស សុភានុបស្សិនោ;**
**ភិយ្យោ តណ្ហា បវឌ្ឍតិ, ឯស ខោ ទឡ្ហំ* ករោតិ ពន្ធនំ។**

**៣៥០. វិតក្កូបសមេ ច* យោ រតោ,**
**អសុភំ ភាវយតេ សទា សតោ;**
**ឯស ខោ ព្យន្តិ កាហិតិ,**
**ឯស ឆេច្ឆតិ មារពន្ធនំ។**

តណ្ហារមែងចម្រើនក្រៃលែងដល់ជន ដែលវិតក្កៈញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ ជននោះឯង ឈ្មោះថាធ្វើចំណងឲ្យមាំមួន។ លុះតែជនណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រំងាប់នូវវិតក្កៈ មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន, ជននោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន ជននោះឯង ទើបឈ្មោះថាកាត់ចំណងមារបាន។

**៣៥១. និដ្ឋង្គតោ អសន្តាសី, វីតតណ្ហោ អនង្គណោ;**
**អច្ឆិន្ទិ ភវសល្លានិ, អន្តិមោយំ សមុស្សយោ។**

បុគ្គលណា ដល់សេចក្តីសម្រេចគឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរគឺកិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់ភពបានហើយ, កាយដែលឆ្អឹង៣០០កំណាត់ផ្គុំគ្នាហើយនេះរបស់បុគ្គលនោះ ឈ្មោះថាតាំងនៅក្នុងទីបំផុត។

**៣៥២. វីតតណ្ហោ អនាទានោ, និរុត្តិបទកោវិទោ;**
**អក្ខរានំ សន្និបាតំ, ជញ្ញា បុព្វាបរានិ ច;**
**ស វេ "អន្តិមសារីរោ, មហាបញ្ញោ មហាបុរិសោ"តិ វុច្ចតិ។**

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្ដីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ (វាចាជាគ្រឿងសម្ដែងចេញ) និងបទដ៏សេសដឹងច្បាស់ នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើមនិងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា "អ្នកមានសរីរៈស្ថិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស"។

**៣៥៣. សព្វាភិភូ សព្វវិទូហមស្មិ,**
**សព្វេសុ ធម្មេសុ អនូបលិត្តោ;**
**សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ,**
**សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ។**

តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ដឹងច្បាស់នូវចតុភូមិកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅក្នុងតេមិកធម៌ទាំងអស់ លះបង់នូវតេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះការអស់ទៅនៃតណ្ហា បើតថាគតត្រាស់ដឹងនូវចតុភូមិកធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត។

**៣៥៤. សព្វទានំ ធម្មទានំ ជិនាតិ,**
**សព្វរសំ ធម្មរសោ ជិនាតិ;**
**សព្វរតឹ ធម្មរតិ ជិនាតិ,**
**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ។**

ធម្មទាន ឈ្នះអាមិសទានទាំងពួង, ធម្មរស ឈ្នះរសទាំងពួង, សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង, ការអស់ទៅនៃតណ្ហា ឈ្នះទុក្ខទាំងពួង។

**៣៥៥. ហនន្តិ ភោគា ទុម្មេធំ, នោ ច បារគវេសិនោ;**
**ភោគតណ្ហាយ ទុម្មេធោ, ហន្តិ អញ្ញេវ អត្តនំ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គល អ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ, ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ។

**៣៥៦. តិណទោសានិ ខេត្តានិ, រាគទោសា អយំ បជា;**
**តស្មា ហិ វីតរាគេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានរាគៈជាទោស; ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន។

**៣៥៧. តិណទោសានិ ខេត្តានិ, ទោសទោសា អយំ បជា;**
**តស្មា ហិ វីតទោសេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានទោសៈជាទោស; ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន។

**៣៥៨. តិណទោសានិ ខេត្តានិ, មោហទោសា អយំ បជា;**
**តស្មា ហិ វីតមោហេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានមោហៈជាទោស; ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន។

**៣៥៩. តិណទោសានិ ខេត្តានិ, ឥច្ឆាទោសា អយំ បជា;**
**តស្មា ហិ វិគតិច្ឆេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានសេចក្តីច្រណែនជាទោស; ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីច្រណែនអស់ហើយ រមែងជាទានមានផលច្រើន។

**(៣៥៩. តិណទោសានិ ខេត្តានិ, តណ្ហាទោសា អយំ បជា;**
**តស្មា ហិ វីតតណ្ហេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានតណ្ហាជាទោស; ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានតណ្ហាអស់ហើយ រមែងជាទានមានផលច្រើន។ គាថាមានក្នុងច្បាប់ឆដ្ឋសង្គាយនា)

**តណ្ហាវគ្គោ ចតុវីសតិមោ និដ្ឋិតោ។**

តណ្ហាវគ្គ ទី២៤ ចប់ ។

## ២៥. ភិក្ខុវគ្គ

**៣៦០. ចក្ខុនា សំវរោ សាធុ, សាធុ សោតេន សំវរោ;**
**ឃានេន សំវរោ សាធុ, សាធុ ជិវ្ហាយ សំវរោ។**
**៣៦១. កាយេន សំវរោ សាធុ, សាធុ វាចាយ សំវរោ;**
**មនសា សំវរោ សាធុ, សាធុ សព្វត្ថ សំវរោ;**
**សព្វត្ថ សំវុតោ ភិក្ខុ, សព្វទុក្ខា បមុច្ចតិ។**

ការសង្រួមភ្នែក ជាការប្រពៃ, ការសង្រួមត្រចៀក ជាការប្រពៃ, ការសង្រួមច្រមុះ ជាការប្រពៃ, ការសង្រួមអណ្តាត ជាការប្រពៃ, ការសង្រួមកាយ ជាការប្រពៃ, ការសង្រួមវាចា ជាការប្រពៃ, ការសង្រួមចិត្ត ជាការប្រពៃ,

ការសង្រួមទាំងអស់ ជាការប្រពៃ, ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន។

**៣៦២. ហត្ថសំយតោ បាទសំយតោ,**
**វាចាសំយតោ សំយតុត្តមោ;**
**អជ្ឈត្តរតោ សមាហិតោ,**
**ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ។**

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាពជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថាភិក្ខុ។

**៣៦៣. យោ មុខសំយតោ ភិក្ខុ, មន្តភាណី អនុទ្ធតោ;**
**អត្ថំ ធម្មញ្ច ទីបេតិ, មធុរំ តស្ស ភាសិតំ។**

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្ដែងអត្ថផង ធម៌ផង ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថាពីរោះ។

**៣៦៤. ធម្មារាមោ ធម្មរតោ, ធម្មំ អនុវិចិន្តយំ;**
**ធម្មំ អនុស្សរំ ភិក្ខុ, សទ្ធម្មា ន បរិហាយតិ។**

ភិក្ខុ មានធម៌ជាទីត្រេកអរ ត្រេកអរហើយ ក្នុងធម៌

ពិចារណាធម៌ រលឹកធម៌រឿយៗ រមែងមិនសាបសូន្យចាក ព្រះសទ្ធម្មឡើយ។

**៣៦៥. សលាភំ នាតិមញ្ញេយ្យ, នាញ្ញេសំ បិហយំ ចរេ;**
**អញ្ញេសំ បិហយំ ភិក្ខុ, សមាធឹ នាធិគច្ឆតិ។**
**៣៦៦. អប្បលាភោបិ ចេ ភិក្ខុ, សលាភំ នាតិមញ្ញតិ;**
**តំ វេ ទេវា បសំសន្តិ, សុទ្ធាជីវឹ អតន្ទិតំ។**
**៣៦៧. សព្វសោ នាមរូបស្មឹ, យស្ស នត្ថិ មមាយិតំ;**
**អសតា ច ន សោចតិ, ស វេ "ភិក្ខូ"តិ វុច្ចតិ។**

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌), មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ, បើចង់បានលាភរបស់ភិក្ខុដទៃ តែងមិនបានសមាធិ។

បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភ របស់ខ្លួន, ទេវតានិងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នករស់នៅដ៏បរិសុទ្ធ មិនខ្ជិលច្រអូស។

**៣៦៨. មេត្តាវិហារី យោ ភិក្ខុ, បសន្នោ ពុទ្ធសាសនេ;**
**អធិគច្ឆេ បទំ សន្តំ, សង្ខារូបសមំ សុខំ។**

ភិក្ខុណា នៅដោយអំនាចនៃមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា, ភិក្ខុនោះ រមែងបាននូវបទដ៏ស្ងប់ ជាទីរំងាប់នូវសង្ខារ ជាបរមសុខ។

**៣៦៩. សិញ្ច ភិក្ខុ ឥមំ នាវំ, សិត្តា តេ លហុមេស្សតិ;**
**ឆេត្វា រាគញ្ច ទោសញ្ច, តតោ និព្វានមេហិសិ។**

ម្នាលភិក្ខុ អ្នកចូរស្ដារទូកគឺអត្តភាពនេះ, ទូកដែលអ្នកស្ដារហើយនឹងដល់ត្រើយឆាប់, អ្នកកាត់រាគៈនិងទោសៈបានហើយ អំពីនោះ នឹងអាចដល់នូវព្រះនិព្វាន។

**៣៧០. បញ្ច ឆិន្ទេ បញ្ច ជហេ, បញ្ច ចុត្តរិ ភាវយេ;**
**បញ្ច សង្គាតិគោ ភិក្ខុ, ឱឃតិណ្ណោតិ វុច្ចតិ។**

ភិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ៥ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ៥ផង គប្បីចម្រើនឥន្ទ្រិយ៥តទៅ ភិក្ខុកន្លងកិលេសជាគ្រឿងជំពាក់៥ (រាគៈទោសៈមោហៈមានៈនិងទិដ្ឋិ)បានហើយ ទើបតថាគតហៅថាអ្នកឆ្លងអន្លង់បាន។

**៣៧១. ឈាយ ភិក្ខុ មា ច បមាទោ,**
**មា តេ កាមគុណេ ភមស្សុ[17] ចិត្តំ;**
**មា លោហគុឡំ គិលី បមត្តោ,**
**មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ។**

ម្នាលភិក្ខុ អ្នកចូរចម្រើនឈាន ចូរកុំប្រមាទ ចូរកុំវិលទៅរកកាមគុណ ចូរកុំប្រមាទទំពាស៊ីនូវដុំលោហៈ ចូរកុំ

17 ឆ. រមេស្សុ, សី.បី. ភវស្សុ, កត្ថចិ រមេស្សុ។

ឲ្យ ខ្លួនអ្នកកាលភ្លើងឆេះ (ក្នុងនរក)ហើយ កន្ទក់កន្ទេញថា (ការរស់បែប)នេះ លំបាកណាស់ហ្ន៎ ដូច្នេះឡើយ។

**៣៧២. នត្ថិ ឈានំ អបញ្ញស្ស, បញ្ញា នត្ថិ អឈាយិនោ;**
**យម្ហិ ឈានញ្ច បញ្ញា ច, ស វេ និព្វានសន្តិកេ។**

ឈាន មិនមានដល់បុគ្គលអ្នកមិនមានបញ្ញា, បញ្ញា មិនមានដល់បុគ្គលអ្នកមិនមានឈាន, ឈាននិងបញ្ញា មានក្នុងបុគ្គលណា, បុគ្គលនោះឯង (ឈ្មោះថាស្ថិតនៅ) ក្នុងទីជិតនៃព្រះនិព្វាន។

**៣៧៣. សុញ្ញាគារំ បវិដ្ឋស្ស, សន្តចិត្តស្ស ភិក្ខុនោ;**
**អមានុសី រតិ ហោតិ, សម្មា ធម្មំ វិបស្សតោ។**

សេចក្ដីត្រេកអរ ដែលមិនមែនជារបស់មនុស្ស (គឺវិបស្សនា) រមែងមានដល់ភិក្ខុអ្នកចូលទៅ កាន់ផ្ទះស្ងាត់ អ្នកមានចិត្តរំងាប់ អ្នកឃើញធម៌តាមហេតុ។

**៣៧៤. យតោ យតោ សម្មសតិ, ខន្ធានំ ឧទយព្វយំ;**
**លភតិ បីតិបាមោជ្ជំ, អមតំ តំ វិជានតំ។**

ភិក្ខុពិចារណាការកើតឡើងនិងការវិនាស នៃខន្ធទាំងឡាយ ក្នុងកាលណា, ក្នុងកាលនោះ ភិក្ខុនោះរមែងបាន បីតិនិងបាមោជ្ជ, បីតិនិងបាមោជ្ជនោះ ឈ្មោះថាជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ។

**៣៧៥. តត្រាយមាទិ ភវតិ, ឥធ បញ្ញស្ស ភិក្ខុនោ;**
**ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ, បាតិមោក្ខេ ច សំវរោ។**

គុណ៣ប្រការនេះ គឺការរក្សាឥន្ទ្រិយ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ១ ជាខាងដើមនៃព្រះនិព្វាន នោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញា ក្នុងសាសនានេះ។

**៣៧៦. មិត្តេ ភជស្សុ កល្យាណេ, សុទ្ធាជីវេ អតន្ទិតេ;**
**បដិសន្ថារវុត្យស្ស, អាចារកុសលោ សិយា;**
**តតោ បាមោជ្ជពហុលោ, ទុក្ខស្សន្តំ ករិស្សតិ[18]។**

អ្នក ចូរគប់រកកល្យាណមិត្ត មានការរស់នៅដ៏បរិសុទ្ធ មិនខ្ជិលច្រអូស, ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំង២នោះ ជាអ្នកច្រើនដោយបាមោជ្ជៈ នឹងធ្វើទីបំផុតទុក្ខបាន។

**៣៧៧. វស្សិកា វិយ បុប្ផានិ, មទ្ទវានិ បមុញ្ចតិ;**
**ឯវំ រាគញ្ច ទោសញ្ច, វិប្បមុញ្ចេថ ភិក្ខវោ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម្លិះជម្រុះផ្កាម្លិះទាំងឡាយ ដែលស្វិតហើយដូច្នោះ។

---

18 ឱ. ស្យា. ករិស្សសិ។

**៣៧៨. សន្តកាយោ សន្តវាចោ, សន្តមនោ សុសមាហិតោ;**
**វន្តលោកាមិសោ ភិក្ខុ, "ឧបសន្តោ"តិ វុច្ចតិ។**

ភិក្ខុអ្នកមានកាយស្ងប់ មានវាចាស្ងប់ មានចិត្តស្ងប់ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រំងាប់។

**៣៧៩. អត្តនា ចោទយត្តានំ, បដិមំសេ តមត្តនា[19];**
**សោ អត្តគុត្តោ សតិមា, សុខំ ភិក្ខុ វិហាហិសិ។**

**៣៨០. អត្តា ហិ អត្តនោ នាថោ, អត្តា ហិ អត្តនោ គតិ;**
**តស្មា សំយមមត្តានំ, អស្សំ ភទ្រំវ វាណិជោ។**

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង, ចូរពិនិត្យខ្លួនដោយខ្លួនឯង, ម្នាលភិក្ខុ អ្នកឯងបើមានស្មារតីរក្សាខ្លួនទុកហើយ នឹងនៅជាសុខ។ មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន, ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួនដូចពាណិជរវាំងសេះដ៏ល្អ។

**៣៨១. បាមោជ្ជពហុលោ ភិក្ខុ, បសន្នោ ពុទ្ធសាសនេ;**
**អធិគច្ឆេ បទំ សន្តំ, សង្ខារូបសមំ សុខំ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា, ភិក្ខុនោះ រមែងបាននូវបទដ៏ស្ងប់ ជាទីរំងាប់

19 ឆ. បដិមំសេថ អត្តនា, សី.បី. បដិមាសេ អត្តមត្តនា ។

នូវសង្ខារ ជាបរមសុខ។

**៣៨២. យោ ហវេ ទហរោ ភិក្ខុ, យុញ្ជតិ ពុទ្ធសាសនេ;**
**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

ភិក្ខុណា នៅក្មេង ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា, ភិក្ខុនោះ រមែងញ៉ាំងលោកឲ្យភ្លឺបាន ដូចព្រះចន្ទដែលរះផុតអំពីពពក។

**ភិក្ខុវគ្គោ បញ្ចវីសតិមោ និដ្ឋិតោ។**

ភិក្ខុវគ្គ ទី២៥ ចប់ ។

## ២៦. ព្រាហ្មណវគ្គ

**៣៨៣. ឆិន្ទ សោតំ បរក្កម្ម, កាមេ បនូទ ព្រាហ្មណ;**
**សង្ខារានំ ខយំ ញត្វា, អកតញ្ញូសិ ព្រាហ្មណ។**

ម្នាលព្រាហ្មណ៍ អ្នកប្រឹងកាត់តណ្ហាដូចខ្សែទឹក, ចូរបន្ទោបង់កាមទាំងឡាយ; ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយ ហើយឈ្មោះថាជាអ្នកដឹងនូវព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន។

**៣៨៤. យទា ទ្វយេសុ ធម្មេសុ, បារគូ ហោតិ ព្រាហ្មណោ;**
**អថស្ស សព្វេ សំយោគា, អត្ថំ គច្ឆន្តិ ជានតោ។**

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយក្នុងធម៌ពីរប្រការ

គឺសមថធម៌និងវិបស្សនាធម៌, ក្នុងកាលនោះ កិលេស គ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន។

**៣៨៥. យស្ស បារំ អបារំ វា, បារាបារំ ន វិជ្ជតិ;**
**វីតទ្ទរំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

ត្រើយ (គឺអាយតនៈខាងក្នុង៦)ក្តី មិនមានត្រើយ (គឺអាយតនៈខាងក្រៅ៦)ក្តី ត្រើយនិងមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា, តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេសថាជាព្រាហ្មណ៍។

**៣៨៦. ឈាយឹ វិរជមាសីនំ, កតកិច្ចមនាសវំ;**
**ឧត្តមត្ថមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មានធូលីគឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍។

**៣៨៧. ទិវា តបតិ អាទិច្ចោ, រត្តិមាភាតិ ចន្ទិមា;**
**សន្នទ្ធោ ខត្តិយោ តបតិ, ឈាយី តបតិ ព្រាហ្មណោ;**
**អថ សព្វមហោរត្តឹ, ពុទ្ធោ តបតិ តេជសា។**

ព្រះអាទិត្យរុងរឿង ក្នុងវេលាថ្ងៃ, ព្រះចន្ទរុងរឿង ក្នុងវេលាយប់, ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង, សមណព្រាហ្មណ៍អ្នកមានឈាន រមែងរុងរឿង, ឯព្រះសម្ពុទ្ធរមែងរុងរឿងដោយតេជះទាំងយប់ទាំងថ្ងៃ។

**៣៨៨. ពាហិតបាបោ ហិ ព្រាហ្មណោ,**
**សមចរិយា សមណោតិ វុច្ចតិ;**
**បព្វាជយមត្តនោ មលំ,**
**តស្មា "បព្វជិតោ"តិ វុច្ចតិ។**

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថាព្រាហ្មណ៍ អ្នកដែលតថាគតហៅថាសមណៈ ព្រោះការប្រព្រឹត្តស្ងប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះទើបតថាគតហៅថាបព្វជិត។

**៣៨៩. ន ព្រាហ្មណស្ស បហរេយ្យ,**
**នាស្ស មុញ្ចេថ ព្រាហ្មណោ;**
**ធិ* ព្រាហ្មណស្ស ហន្តារំ,**
**តតោ ធិ* យស្ស[20] មុញ្ចតិ។**

**៣៩០. ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ,**
**យទា និសេធោ មនសោ បិយេហិ;**

---
20 យោ + អស្ស = យស្ស។ *ឆ. ធី។

**យតោ យតោ ហឹសមនោ និវត្តតិ,**
**តតោ តតោ សម្មតិមេវ ទុក្ខំ។**

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ, (ចំណែក) ព្រាហ្មណ៍ (ដែលត្រូវគេប្រហារហើយ) គប្បីចងពៀរចំពោះព្រាហ្មណ៍នោះ, តថាគតតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍, ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ, តថាគតតិះដៀលព្រាហ្មណ៍នោះក្រៃលែងជាងនោះទៅទៀត។ ការហាមឃាត់ចិត្តចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ, មិនមែនប្រសើរបន្តិចបន្តួចទេ, ចិត្តដែលគិតបៀតបៀនគេងាកចេញចាកវត្ថុណាៗ សេចក្ដីទុក្ខព្រោះវត្ថុនោះៗ ក៏រំងាប់ទៅបាន។

**៣៩១. យស្ស កាយេន វាចាយ, មនសា នត្ថិ ទុក្កដំ;**
**សំវុតំ តីហិ ឋានេហិ, តមហំ ព្រូមិ ព្រាហ្មណំ។**

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណាមិនមានទេ, តថាគតហៅបុគ្គល ដែលបានបិទ(ទ្វារ) ដោយស្ថានទាំង៣នោះ ថាជាព្រាហ្មណ៍។

**៣៩២. យម្ហា ធម្មំ វិជានេយ្យ, សម្មាសម្ពុទ្ធទេសិតំ;**
**សក្កច្ចំ តំ នមស្សេយ្យ, អគ្គិហុត្តំវ ព្រាហ្មណោ។**

បុគ្គល ចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែង ហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយ គោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើងដូច្នោះ។

**៣៩៣. ន ជដាហិ ន គោត្តេន, ន ជច្ចា ហោតិ ព្រាហ្មណោ;**
**យម្ហិ សច្ចញ្ច ធម្មោ ច, សោ សុចី សោ ច ព្រាហ្មណោ។**

បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះផ្នួងសក់ក៏មិន មែន ព្រោះគោត្រក៏មិនមែន ព្រោះជាតិក៏មិនមែន, តែ សច្ចៈផង ធម៌ផងមានក្នុងបុគ្គលណា, បុគ្គលនោះឈ្មោះ ថាអ្នកស្អាតផង បុគ្គលនោះឈ្មោះថាព្រាហ្មណ៍ផង។

**៣៩៤. កិំ តេ ជដាហិ ទុម្មេធ, កិំ តេ អជិនសាដិយា;**
**អព្ភន្តរំ តេ គហនំ, ពាហិរំ បរិមជ្ជសិ។**

នៃអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការ ទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់ សំពត់ស្បែកខ្លា បើសន្ដានខាងក្នុង របស់អ្នកសឹងសាំញ៉ាំ ដោយរាគាទិក្កិលេស អ្នកឈ្មោះថាដុសខាត់តែខាងក្រៅ ទេ។

**៣៩៥. បំសុកូលធរំ ជន្តុំ, កិសំ ធមនិសន្ថតំ;**
**ឯកំ វនស្មិំ ឈាយន្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល អ្នកទ្រទ្រង់សំពត់បំសុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯងចម្រើនឈាន ក្នុងព្រៃនោះ ថាជាព្រាហ្មណ៍។

**៣៩៦. ន ចាហំ ព្រាហ្មណំ ព្រូមិ, យោនិជំ មត្តិសម្ភវំ;**
**ភោវាទិ នាម សោ ហោតិ, សចេ ហោតិ សកិញ្ចនោ;**
**អកិញ្ចនំ អនាទានំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណី ជាមាតាថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះគ្រាន់តែបាននាមថាភោវាទី (អ្នកពោលថាចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសជាគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គល អ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំនោះឯងថាជាព្រាហ្មណ៍។

**៣៩៧. សព្វសំយោជនំ ឆេត្វា, យោ វេ ន បរិតស្សតិ;**
**សង្គាតិគំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាកាត់សំយោជនៈទាំងអស់បាន មិនតក់ស្លុត, តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងជំពាក់ អ្នករួចស្រឡះចាកកិលេស ថាជាព្រាហ្មណ៍។

**៣៩៨. ឆេត្វា នទ្ធឹ វរត្តញ្ច, សន្ទានំ សហានុក្កមំ;**

**ឧក្ខិត្តបលិឃំ ពុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល ដែលកាត់សេចក្តីក្រោធដូចព្ជួរផង កាត់តណ្ហាដូចព្រ័ត្រផង កាត់ទិដ្ឋិ៦២ដូចទីត ព្រមទាំងអនុស័យដូចអ្នកដើរតាមផង អ្នកមានអវិជ្ជាដូចសសរខឿនដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ៤នោះឯងថាជាព្រាហ្មណ៍។

**៣៩៩. អក្កោសំ វធពន្ធញ្ច, អទុដ្ឋោ យោ តិតិក្ខតិ;**
**ខន្តីពលំ ពលានីកំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាមិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និងការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តីជាពលៈ មានខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍។

**៤០០. អក្កោធនំ វតវន្តំ, សីលវន្តំ អនុស្សទំ;**
**ទន្តំ អន្តិមសារីរំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសេរីរៈឋិតនៅក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍។

**៤០១. វារិ បោក្ខរបត្តេវ, អារគ្គេរិវ សាសបោ;**

**យោ ន លិម្បតិ កាមេសុ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

**៤០២. យោ ទុក្ខស្ស បជានាតិ, ឥធេវ ខយមត្តនោ;**
**បន្នភារំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទៅនៃទុក្ខរបស់ខ្លួន, តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈដាក់ចុះហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍។

**៤០៣. គម្ភីរបញ្ញំ មេធាវឹ, មគ្គាមគ្គស្ស កោវិទំ;**
**ឧត្តមត្ថមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស អ្នកឈ្លាសក្នុងផ្លូវនិងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ ខ្ពស់នោះថាជាព្រាហ្មណ៍។

**៤០៤. អសំសដ្ឋំ គហដ្ឋេហិ, អនាគារេហិ ចូភយំ;**
**អនោកសារិមប្បិច្ឆំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គលដែលមិនច្រឡំដោយជនទាំងឡាយ ២ពួក គឺគ្រហស្ថ១ បព្វជិត១ ជាអ្នកត្រាច់ទៅដោយមិន

មានសេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍។

**៤០៥. និធាយ ទណ្ឌំ ភូតេសុ, តសេសុ ថាវរេសុ ច;**
**យោ ន ហន្តិ ន ឃាតេតិ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាដាក់ចោះនូវអាជ្ញាក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួនគឺមិនតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

**៤០៦. អវិរុទ្ធំ វិរុទ្ធេសុ, អត្តទណ្ឌេសុ និព្វុតំ;**
**សាទានេសុ អនាទានំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល អ្នកដែលមិនខឹងចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួនអ្នកមិនមានសេចក្តីប្រកាន់ ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍។

**៤០៧. យស្ស រាគោ ច ទោសោ ច, មានោ មក្ខោ ច បាតិតោ;**
**សាសបោរិវ អារគ្គា, តមហំ ព្រូមិ ព្រាហ្មណំ។**

រាគៈទោសៈមានៈនិងមក្ខៈដែលបុគ្គលណា ជម្រុះចេញហើយ ដូចគ្រាប់ស្ពៃ ដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

**៤០៨. អកក្កសំ វិញ្ញាបនិំ, គិរំ សច្ចមុទីរយេ;**
**យាយ នាភិសជេ កញ្ចិ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិតជាពាក្យដែលមិនធ្វើអ្នកណាឲ្យទាស់ចិត្ត, តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍។

**៤០៩. យោធ ទីឃំ វ រស្សំ វា, អណុំ ថូលំ សុភាសុភំ;**
**លោកេ អទិន្នំ នាទិយតិ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មិនយករបស់វែងឬខ្លី តូចឬធំ អាក្រក់ឬល្អ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

**៤១០. អាសា យស្ស ន វិជ្ជន្តិ, អស្មិំ លោកេ បរម្ហិ ច;**
**និរាសយំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍។

**៤១១. យស្សាលយា ន វិជ្ជន្តិ, អញ្ញាយ អកថំកថី;**
**អមតោគធមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មិនមានសេចក្តីអាល័យគឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌, តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់ កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍។

**៤១២. យោធ បុញ្ញញ្ច បាបញ្ច, ឧភោ សង្គមុបច្ចគា;**
**អសោកំ វិរជំ សុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យនិងបាបទាំងពីរ និងកិលេសជាគ្រឿងជំពាក់ (មានរាគៈជាដើម)ចេញហើយ, តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលីគឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍។

**៤១៣. ចន្ទំវ វិមលំ សុទ្ធំ, វិប្បសន្នមនាវិលំ;**
**នន្ទិភវបរិក្ខីណំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លាមិនកករល្អក់ អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍។

**៤១៤. យោមំ បលិបថំ ទុគ្គំ, សំសារំ មោហមច្ចគា;**

**តិណ្ណោ បារគតោ ឈាយី, អនេជោ អកថំកថី;**
**អនុបាទាយ និព្វុតោ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា បានកន្លងនូវផ្លូវវាងគឺរាគៈ ភក់ឬផ្លូវលំបាកគឺកិលេស សំសារវដ្ដ និងមោហៈទាំងនេះ ជាអ្នកឆ្លងអន្លង់ទាំង៤ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្ដីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

**៤១៥. យោធ កាមេ បហន្ត្វាន, អនាគារោ បរិព្វជេ;**
**កាមភវបរិក្ខីណំ, តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណាក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន, តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍។

**៤១៦. យោធ តណ្ហំ បហន្ត្វាន, អនាគារោ បរិព្វជេ;**
**តណ្ហាភវបរិក្ខីណំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាក្នុងលោកនេះ បានលះបង់តណ្ហា ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន, តថាគតហៅបុគ្គលនោះ ដែលអស់តណ្ហានិងភពហើយ ថាជាព្រាហ្មណ៍។

**៤១៧. ហិត្វា មានុសកំ យោគំ, ទិព្វំ យោគំ ឧបច្ចគា;**

**សព្វយោគវិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាលះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ, តថាគតហៅបុគ្គល ដែលផុតស្រឡះចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះថាជាព្រាហ្មណ។

**៤១៨. ហិត្វា រតិញ្ច អរតិញ្ច, សីតិភូតំ និរូបធឹ;**

**សព្វលោកាភិភុំ វីរំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គល ដែលលះបង់សេចក្តីត្រេកអរ ក្នុងកាមគុណ និងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់ មិនមានឧបធិក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍។

**៤១៩. ចុតឹ យោ វេទិ សត្តានំ, ឧបបត្តិញ្ច សព្វសោ;**

**អសត្តំ សុគតំ ពុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាដឹងច្បាស់ចុតិនិងបដិសន្ធិ របស់ពួកសត្វដោយអាការៈទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំនើរល្អដោយសេចក្តីប្រតិបត្តិអ្នកត្រាស់ដឹងនូវសច្ចៈ៤នោះថាជាព្រាហ្មណ៍។

**៤២០. យស្ស គតឹ ន ជានន្តិ, ទេវា គន្ធព្វមានុសា;**

**ខីណាសវំ អរហន្តំ, តមហំ ព្រូមិ ព្រាហ្មណំ។**

ពួកទេវតា គន្ធព្វនិងមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា, តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍។

**៤២១. យស្ស បុរេ ច បច្ឆា ច, មជ្ឈេ ច នត្ថិ កិញ្ចនំ;**
**អកិញ្ចនំ អនាទានំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍។

**៤២២. ឧសភំ បវរំ វីរំ, មហេសិំ វិជិតាវិនំ;**
**អនេជំ ន្ហាតកំ ពុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅវីរបុរសអ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេសត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍។

**៤២៣. បុព្វេនិវាសំ យោ វេទិ, សគ្គាបាយញ្ច បស្សតិ,**
**អថោ ជាតិក្ខយំ បត្តោ, អភិញ្ញាវោសិតោ មុនិ;**
**សព្វវោសិតវោសានំ, តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា ដឹងច្បាស់នូវខន្ធដែលខ្លួនធ្លាប់នៅអាស្រ័យក្នុងកាលមុនផង ឃើញច្បាស់ឋានសួគ៌ និងអបាយភូមិ

ផង មួយទៀត បានសំរេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គលដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ចប់សព្វគ្រប់ហើយនោះថាជាព្រាហ្មណ៍។

**ព្រាហ្មណវគ្គោ ឆព្វីសតិមោ និដ្ឋិតោ។**

ព្រាហ្មណវគ្គ ទី២៦ ចប់ ។

**ឯត្តាវតា សព្វបឋមេ យមកវគ្គេ ចុទ្ទស វត្ថូនិ, អប្បមាទវគ្គេ នវ, ចិត្តវគ្គេ នវ, បុប្ផវគ្គេ ទ្វាទស, ពាលវគ្គេ បន្នរស, បណ្ឌិតវគ្គេ ឯកាទស, អរហន្តវគ្គេ ទស, សហស្សវគ្គេ ចុទ្ទស, បាបវគ្គេ ទ្វាទស, ទណ្ឌវគ្គេ ឯកាទស, ជរាវគ្គេ នវ, អត្តវគ្គេ ទស, លោកវគ្គេ ឯកាទស, ពុទ្ធវគ្គេ នវ, សុខវគ្គេ អដ្ឋ, បិយវគ្គេ នវ, កោធវគ្គេ អដ្ឋ, មលវគ្គេ ទ្វាទស, ធម្មដ្ឋវគ្គេ ទស, មគ្គវគ្គេ ទ្វាទស, បកិណ្ណកវគ្គេ នវ, និរយវគ្គេ នវ, នាគវគ្គេ អដ្ឋ, តណ្ហាវគ្គេ ទ្វាទស, ភិក្ខុវគ្គេ ទ្វាទស, ព្រាហ្មណវគ្គេ ចត្តាលីសាតិ បញ្ចាធិកានិ តីណិ វត្ថុសតានិ។**

**សតេវីសចតុស្សតា, ចតុសច្ចវិភាវិនា;**
**សតត្តយញ្ច វត្ថូនំ, បញ្ចាធិកំ សមុដ្ឋិតាតិ[21]។**

---

21 បាលីទាំងនេះ មានប្រាកដក្នុងច្បាប់ឆដ្ឋសង្គាយនានិងអដ្ឋកថាទាំងឡាយ។

គាថាធម្មបទមានប្រមាណប៉ុណ្ណោះ វគ្គដំបូងបង្អស់ គឺក្នុងយមកវគ្គ មាន១៤រឿង, អប្បមាទវគ្គ មាន៩រឿង, ចិត្តវគ្គមាន៩រឿង, បុប្ផវគ្គមាន១២រឿង, ពាលវគ្គមាន១៥រឿង, បណ្ឌិត-វគ្គមាន១១រឿង, អរហន្តវគ្គមាន១០រឿង, សហស្សវគ្គមាន១៤រឿង, បាបវគ្គមាន១២រឿង, ទណ្ឌវគ្គមាន១១រឿង, ជរា-វគ្គមាន៩រឿង, អត្តវគ្គមាន១០រឿង, លោកវគ្គមាន១១រឿង, ពុទ្ធវគ្គមាន៩រឿង, សុខវគ្គមាន៨រឿង, បិយវគ្គមាន៩រឿង, កោធវគ្គមាន៨រឿង, មលវគ្គមាន១២រឿង, ធម្មដ្ឋវគ្គមាន១០រឿង, មគ្គវគ្គមាន១២រឿង, បកិណ្ណកវគ្គមាន៩រឿង, និរយវគ្គមាន៩រឿង, នាគវគ្គ មាន៨រឿង, តណ្ហាវគ្គ មាន១២រឿង, ភិក្ខុវគ្គមាន១២រឿង, ព្រាហ្មណវគ្គមាន៤០រឿង ដូច្នេះ ទើបមាន៣០៥រឿង។

គាថា មាន៤៣២គាថា ដែលសម្ដែងសច្ច៤ កើតឡើង ហើយ ដោយរឿងរ៉ាវ មានប្រមាណ៣០៥រឿង ដូច្នេះ។

## ធម្មបទស្ស វគ្គស្សុទ្ទានំ

**យមកំបមាទំ ចិត្តំ, បុប្ផំ ពាលញ្ច បណ្ឌិតំ;**
**អរហន្តំ សហស្សំ បាបំ, ទណ្ឌំ ជរា អត្តលោកំ។**
**ពុទ្ធំ សុខំ បិយំ កោធំ, មលំ ធម្មដ្ឋមគ្គញ្ច;**

**បកិណ្ណកំ និរយំ នាគំ, តណ្ហា ភិក្ខុ ច ព្រាហ្មណោ។**

គាថាធម្មបទ មានឧទ្ទាន នៃវគ្គទាំង២៦(នេះ)គឺ៖

យមកវគ្គ១ អប្បមាទវគ្គ១ ចិត្តវគ្គ១ បុប្ផវគ្គ១ ពាលវគ្គ១ បណ្ឌិតវគ្គ១ អរហន្តវគ្គ១ សហស្សវគ្គ១ បាបវគ្គ១ ទណ្ឌវគ្គ១ ជរាវគ្គ១ អត្តវគ្គ១ លោកវគ្គ១ ពុទ្ធវគ្គ១ សុខវគ្គ១ បិយវគ្គ១ កោធវគ្គ១ មលវគ្គ១ ធម្មដ្ឋវគ្គ១ មគ្គវគ្គ១ រួមជា២០វគ្គ បកិណ្ណកវគ្គ១ និរយវគ្គ១ នាគវគ្គ១ តណ្ហាវគ្គ១ ភិក្ខុវគ្គ១ ព្រាហ្មណវគ្គ១ ។

## គាថាយុទ្ទានំ

**យមកេ វីសគាថាយោ, អប្បមាទលោកម្ហិ ច;**
**បិយេ ទ្វាទសគាថាយោ, ចិត្តេ ជរត្តេកាទស។**
**បុប្ផពាលសហស្សម្ហិ, ពុទ្ធ មគ្គ បកិណ្ណកេ;**
**សោឡស បណ្ឌិតេ កោធេ, និរយេ នាគេ ចតុទ្ទស។**
**អរហន្តេ ទសគ្គាថា, បាបសុខម្ហិ តេរស;**
**សត្តរស ទណ្ឌធម្មដ្ឋេ, មលម្ហិ ឯកវីសតិ។**
**តណ្ហាវគ្គេ សត្តពីស, តេវីស ភិក្ខុវគ្គម្ហិ;**
**ព្រាហ្មណេ ឯកតាលីស, ចតុស្សតា សតេវីស។**

ឧទ្ទាននៃគាថា

ក្នុងយមកវគ្គមាន២០គាថា ក្នុងអប្បមាទវគ្គ លោកវគ្គ និងបិយវគ្គ (វគ្គមួយៗ) មាន១២គាថា ក្នុងចិត្តវគ្គ ជរាវគ្គ មាន១១គាថា ក្នុងបុប្ផវគ្គមាន១៦គាថា ក្នុងពាលវគ្គមាន ១៧គាថា ក្នុងបណ្ឌិតវគ្គមាន១៤គាថា ក្នុងអរហន្តវគ្គ មាន១០គាថា ក្នុងសហស្សវគ្គមាន១៦គាថា ក្នុងបាបវគ្គ មាន១៣គាថា ក្នុងទណ្ឌវគ្គមាន១៧គាថា ក្នុង មាន១១ គាថា ក្នុងអត្តវគ្គមាន១២គាថា ក្នុងលោកវគ្គមាន១២ គាថា ក្នុងពុទ្ធវគ្គមាន១៦គាថា ក្នុងសុខវគ្គមាន១២គាថា ក្នុងកោធវគ្គមាន១៤គាថា ក្នុងមលវគ្គមាន២១គាថា ក្នុងធម្មដ្ឋវគ្គមាន១៧គាថា ក្នុងមគ្គវគ្គមាន ១៦គាថា ក្នុងបកិណ្ណកវគ្គមាន១៦គាថា ក្នុងនិរយវគ្គនិងនាគវគ្គ ក្នុងនីមួយៗមាន១៤គាថា ក្នុងតណ្ហាវគ្គមាន២២គាថា ក្នុងភិក្ខុវគ្គមាន២៣គាថា ក្នុងព្រាហ្មណវគ្គមានដែលជា វគ្គទីបំផុតមាន៤០គាថា។ គាថា៤២៣គាថា ដែល ព្រះពុទ្ធអ្នកជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្ដែងហើយ ទុក ក្នុងនិបាតក្នុងធម្មបទ។

(វគ្គស្សុទាននិងគាថាយុទាននេះ តាមនយលក្ខណៈខ្មែរ អាងគម្ពីរភូមា)

ធម្មបទេ វគ្គានមុទ្ទានំ –

យមកប្បមាទោ ចិត្តំ, បុប្ផំ ពាលេន បណ្ឌិតោ;

អរហន្តោ សហស្សញ្ច, បាបំ ទណ្ឌោន តេ ទស។
ជរា អត្តា ច លោកោ ច, ពុទ្ធោ សុខំ បិយេន ច;
កោធោ មលញ្ច ធម្មដ្ឋោ, មគ្គវគ្គេន វីសតិ។
បកិណ្ណំ និរយោ នាគោ, តណ្ហា ភិក្ខុ ច ព្រាហ្មណោ;
ឯតេ ឆព្វីសតិ វគ្គា, ទេសិតាទិច្ចពន្ធុនា។

ក្នុងគាថាធម្មបទ មានឧទ្ទាន នៃវគ្គទាំង២៦(នេះ)គឺ៖ យមកវគ្គ១ អប្បមាទវគ្គ១ ចិត្តវគ្គ១ បុប្ផវគ្គ១ ពាលវគ្គ១ បណ្ឌិតវគ្គ១ អរហន្តវគ្គ១ សហស្សវគ្គ១ បាបវគ្គ១ ទណ្ឌវគ្គ១ ជរាវគ្គ១ អត្តវគ្គ១ លោកវគ្គ១ ពុទ្ធវគ្គ១ សុខវគ្គ១ បិយវគ្គ១ កោធវគ្គ១ មលវគ្គ១ ធម្មដ្ឋវគ្គ១ មគ្គវគ្គ១ រួមជា២០វគ្គ បកិណ្ណកវគ្គ១ និរយវគ្គ១ នាគវគ្គ ១ តណ្ហាវគ្គ១ ភិក្ខុវគ្គ១ ព្រាហ្មណវគ្គ១ រួមទាំងអស់ នេះជា២៦វគ្គ ដែលព្រះពុទ្ធអ្នកជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ។

**គាថានមុទ្ទានំ –**

**យមកេ វីសតិ គាថា, អប្បមាទម្ហិ ទ្វាទស;**
**ឯកាទស ចិត្តវគ្គេ, បុប្ផវគ្គម្ហិ សោឡស។**
**ពាលេ ច សោឡស គាថា, បណ្ឌិតម្ហិ ចតុទ្ទស;**

អរហន្តេ ទស គាថា, សហស្សេ ហោន្តិ សោឡស។
តេរស បាបវគ្គម្ហិ, ទណ្ឌម្ហិ ទស សត្ត ច;
ឯកាទស ជរា វគ្គេ, អត្តវគ្គម្ហិ តា ទស*។
ទ្វាទស លោកវគ្គម្ហិ, ពុទ្ធវគ្គម្ហិ ឋារស*;
សុខេ ច បិយវគ្គេ ច, គាថាយោ ហោន្តិ ទ្វាទស។
ចុទ្ទស កោធវគ្គម្ហិ, មលវគ្គេកវីសតិ;
សត្តរស ច ធម្មដ្ឋេ, មគ្គវគ្គេ សត្តរស*។
បកិណ្ណេ សោឡស គាថា, និរយេ នាគេ ច ចុទ្ទស;
ឆព្វីស តណ្ហាវគ្គម្ហិ, តេវីស ភិក្ខុវគ្គិកា*។
ឯកតាលីសគាថាយោ*, ព្រាហ្មណេ វគ្គមុត្តមេ;
គាថាសតានិ ចត្តារិ, តេវីស ច បុនាបរេ;
ធម្មបទេ និបាតម្ហិ, ទេសិតាទិច្ចពន្ធុនា´តិ។

ឧទ្ទាន នៃគាថាទាំងឡាយ(នេះ)គឺ៖

ក្នុងយមកវគ្គមាន២០គាថា ក្នុងអប្បមាទវគ្គមាន១២គាថា ក្នុងចិត្តវគ្គមាន១១គាថា ក្នុងបុប្ផវគ្គមាន១៦គាថា ក្នុងពាលវគ្គមាន១៦គាថា ក្នុងបណ្ឌិតវគ្គមាន១៤គាថា ក្នុងអរហន្តវគ្គមាន១០គាថា ក្នុងសហស្សវគ្គមាន១៦គាថា ក្នុងបាបវគ្គមាន១៣គាថា ក្នុងទណ្ឌវគ្គមាន១៧គាថា ក្នុងជរាវគ្គមាន១១គាថា ក្នុងអត្តវគ្គមាន១០*គាថា

ក្នុងលោកវគ្គមាន១២គាថា ក្នុងពុទ្ធវគ្គមាន១៨*គាថា ក្នុងសុខវគ្គមាន១២គាថា ក្នុងបិយវគ្គមាន១២គាថា ក្នុងកោធវគ្គមាន១៤គាថា ក្នុងមលវគ្គមាន២១គាថា ក្នុងធម្មដ្ឋវគ្គមាន១៧គាថា ក្នុងមគ្គវគ្គមាន១៧*គាថា ក្នុងបកិណ្ណកវគ្គមាន១៦គាថា ក្នុងនិរយវគ្គមាន១៤គាថា នាគវគ្គមាន១៤គាថា ក្នុងតណ្ហាវគ្គមាន២៦គាថា ក្នុងភិក្ខុវគ្គមាន២៣គាថា ក្នុងព្រាហ្មណវគ្គមានដែលជាវគ្គទីបំផុតមាន៤១គាថា។ គាថា៤២៣គាថា ដែលព្រះពុទ្ធអ្នកជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយទុក ក្នុងនិបាតក្នុងគាថាធម្មបទ។

នេះឧទ្ទានទាំងពីរក្នុងច្បាប់ឆដ្ឋ, ឯក្នុងច្បាប់ខ្មែរមានបាលីថា៖

## ធម្មបទគាថាយ ឧទ្ទានំ

**យមកំ អប្បមាទំ ចិត្តំ, បុប្ផំ ពាលេន បណ្ឌិតោ;**
**អរហន្តំ សហស្សេន, បាបំ ទណ្ឌេន តេ ទស។**
**ជរា អត្តា ច លោកោ ច, ពុទ្ធំ សុខំ បិយេន ច;**
**កោធំ មលញ្ច ធម្មដ្ឋំ, មគ្គវគ្គេន វីសតិ។**
**បកិណ្ណំ និរយំ នាគោ, តណ្ហា ភិក្ខុ ច ព្រាហ្មណោ;**
**ឯតេ ឆព្វីសតិ វគ្គា, ទេសិតាទិច្ចពន្ធុនា។**

យមកេ វីសតិ គាថា, អប្បមាទម្ហិ ទ្វាទស;
ឯកាទសា ចិត្តវគ្គេ, បុប្ផវគ្គម្ហិ សោឡស។
ពាលេ សត្តរសា គាថា, បណ្ឌិតម្ហិ ចតុទ្ទស;
អរហន្តេ ទសា គាថា, សហស្សេ ហោន្តិ សោឡស។
តេរសា បាបវគ្គម្ហិ, ទណ្ឌម្ហិ ទស សត្ត ច;
ឯកាទសា ជរា វគ្គេ, អត្តវគ្គម្ហិ ទ្វាទស។
ទ្វាទសា លោកវគ្គម្ហិ, ពុទ្ធវគ្គម្ហិ សោឡស;
សុខេ ច បិយវគ្គេ ច, គាថាយោ ហោន្តិ ទ្វាទស។
ចុទ្ទសា កោធវគ្គម្ហិ, មលវគ្គេកវីសតិ;
សត្តរសា ច ធម្មដ្ឋេ, មគ្គវគ្គេ សោឡស។
បកិណ្ណេ សោឡស គាថា, និរយេ នាគេ ចុទ្ទស;
ទ្វាវីស តណ្ហាវគ្គម្ហិ, តេវីស ភិក្ខុវគ្គកា។
ចត្តាឡីស ច គាថាយោ, ព្រាហ្មណេ វគ្គមុត្តមេ;
គាថាសតានិ ចត្តារិ, តេវីស ច បុនាបរេ;
ធម្មបទេ និបាតម្ហិ, ទេសិតាទិច្ចពន្ធុនា។

ឧទ្ទាននៃធម្មបទគាថាគឺ៖

យមកវគ្គ១ អប្បមាទវគ្គ១ ចិត្តវគ្គ១ បុប្ផវគ្គ១ ពាលវគ្គ១ បណ្ឌិតវគ្គ១ អរហន្តវគ្គ១ សហស្សវគ្គ១ បាបវគ្គ១ ទណ្ឌវគ្គ១ ជរាវគ្គ១ អត្តវគ្គ១ លោកវគ្គ១ ពុទ្ធវគ្គ១

សុខវគ្គ១ បិយវគ្គ១ កោធវគ្គ១ មលវគ្គ១ ធម្មដ្ឋវគ្គ១ មគ្គវគ្គ១ រួមជា២០វគ្គ បកិណ្ណកវគ្គ១ និរយវគ្គ១ នាគវគ្គ១ តណ្ហាវគ្គ១ ភិក្ខុវគ្គ១ ព្រាហ្មណវគ្គ១ បូករួមត្រូវជា២៦វគ្គ ដែលព្រះពុទ្ធអង្គកជាអាទិច្ចពន្ធុ ទ្រង់សម្ដែងទុកហើយ។

ក្នុងយមកវគ្គ មាន២០គាថា ក្នុងអប្បមាទវគ្គ មាន១២គាថា ក្នុងចិត្តវគ្គមាន១១គាថា ក្នុងបុប្ផវគ្គមាន១៦គាថា ក្នុងពាលវគ្គមាន១៧គាថា ក្នុងបណ្ឌិតវគ្គមាន១៤គាថា ក្នុងអរហន្តវគ្គមាន១០គាថា ក្នុងសហស្សវគ្គមាន១៦គាថា ក្នុងបាបវគ្គមាន១៣គាថា ក្នុងទណ្ឌវគ្គមាន១៧គាថា ក្នុងជរាវគ្គមាន១១គាថា ក្នុងអត្តវគ្គមាន១២គាថា ក្នុងលោកវគ្គមាន១២គាថា ក្នុងពុទ្ធវគ្គមាន១៦គាថា ក្នុងសុខវគ្គមាន១២គាថា ក្នុងបិយវគ្គមាន១២គាថា ក្នុងកោធវគ្គមាន១៤គាថា ក្នុងមលវគ្គមាន២១គាថា ក្នុងធម្មដ្ឋវគ្គមាន១៧គាថា ក្នុងមគ្គវគ្គមាន១៦គាថា ក្នុងបកិណ្ណកវគ្គមាន១៦គាថា ក្នុងនិរយវគ្គមាន១៤គាថា នាគវគ្គមាន១៤គាថា ក្នុងតណ្ហាវគ្គមាន២២គាថា ក្នុងភិក្ខុវគ្គមាន២៣គាថា ក្នុងព្រាហ្មណវគ្គមានដែលជាវគ្គទីបំផុតមាន៤០គាថា។ គាថា៤២៣គាថា ដែលព្រះពុទ្ធ

អ្នកជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយទុក ក្នុង
ធម្មបទនិបាត ។

**ធម្មបទំ និដ្ឋិតំ។ ៚**

គាថាធម្មបទ ចប់។៚